ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Dec-2012, 10:08
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៥នាទី**

**សវនាការលើកទី១៤០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

លោក ហ្សាស្ពើ ប៉ៅ(*Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោក អេម៉ានួអែល ហ្សាកូមី

*(Mr.Emanuel JACOMY)*

លោកស្រី អ៊ីស្សាបែល ដៀរ៉ង់

*(Ms. Isabelle DURAND)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ហ្វាស្តើ ប៉ៅ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក អេម៉ានូអ៊ែល ហ្សាកូមី | បារាំង |
| លោក ជូល្យាន រីវើ (មេធាវីប្រឹក្សា) | បារាំង |
| លោក ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) | ខ្មែរ |
| លោកស្រី ដេនីស អាហ្វុងសូ (TCCP-01) | បារាំង |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ខាំ ផាន់ ហៅ ផាន វ៉ាន** (TCW-307)


សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ ............ ទំព័រ ២

សួរដោយលោក អេនឌ្រូ អ៊ីនូហ្វី ផ្ដើមពី៖ ............ ទំព័រ ៩

សួរដោយលោក សុន អរុណ ផ្ដើមពី៖ ............ ទំព័រ ៤៦

សួរបន្តដោយលោក សុន អរុណ ផ្ដើមពី៖ ............ ទំព័រ ៧៨

សួរដោយលោក គង់ សំអុន ផ្ដើមពី៖ ............ ទំព័រ ៨៨


**ការសួរសំណួរទៅ ដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ដេនីស អាហ្វុងសូ** (TCCP-01)


សួរដោយលោក ហ្វាស្ដេ ប៉ៅ ផ្ដើមពី៖ ............ ទំព័រ ៥៣

E1/153.1

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅព្រឹកនេះ តាមកាលវិភាគដែលបានគ្រោងទុក គឺអង្គជំនុំជម្រះបន្តស្តាប់ -- ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមាន -- ដែលឈ្មោះ ផាន វ៉ាន។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន នៅក្នុងសវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកឡើងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ នាពេលព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មសាក្សី លោក ខាំ ផាន់ ហើយលោកមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ។ រីឯពេលរសៀល អង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ្វុងសូ ដែលនឹងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។

តាមការបញ្ជាក់ពីផ្នែកសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មពីប្រទេសបារាំងនៅពេលរសៀលនេះ បានរៀបចំរួចរាល់ហើយ។ សូមអរគុណ។

[០៩:០៦:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកចៅក្រម ហ្សង់ម៉ាក មានសំណួរត្រូវសួរសាក្សីរូបនេះទៀតទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរខ្លីៗមួយចំនួនតូច ដើម្បីចោទសួរលោកសាក្សី។

**សួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ជម្រាបសួរលោក ខាំ ផាន់។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីរចនាសម្ព័ន្ធរដ្ឋបាល ហើយនិងទំនាក់ទំនងរវាងតំបន់១០៥ និងតំបន់ -- និងភូមិភាគឦសាន។ លោកបានបញ្ជាក់ថា តំបន់១០៥ ជាតំបន់ស្វ័យត។ តើលោកអាចបញ្ជាក់បានទេថា តើមានទំនាក់ទំនងរវាងតំបន់១០៥ និងភូមិភាគឦសានដែរឬទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** បាទ ការទំនាក់ទំនងរវាងតំបន់១០៥ និងភូមិភាគឦសាន មានដែរបាទ។ មាន កាលហ្នឹងរូបភាព វាសហការគ្នាតាមព្រំដែនបាទ។ ចំណែកឯខាងរដ្ឋបាល អត់មានទេ។ រដ្ឋបាលត្រង់មកខាងលើ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំគិតថា ប្រហែលជាមានបញ្ហាបកប្រែបន្តិចជាភាសាបារាំងនោះ។ លោកនិយាយអំពីភូមិភាគពាយ័ព្យ ខ្ញុំនិយាយអំពីភូមិភាគឦសានទេ។ ប្រហែលជាមានបញ្ហាបកប្រែមើលទៅ ឬក៏យ៉ាងម៉េច? សូមលោកបញ្ជាក់ម្តងទៀត?

**ឆ៖** ភូមិភាគឦសាន បាទ។

[០៩:០៩:១៥]

**ស៖** សូមអរគុណ។ លោកបានបញ្ជាក់ថា ទំនាក់ទំនងរវាងតំបន់១០៥ និងភូមិភាគឦសានត្រូវឆ្លងតាមឋានានុក្រម មានន័យថា រាល់ការទាក់ទងគ្នាទាំងអស់ ត្រូវឆ្លងតាមអ្នកណា? តាមគណៈមជ្ឈិម មន្ទីរ៨៧០ ឬក៏ត្រូវឆ្លងកាត់តាមអ្នកណាឲ្យប្រាកដនោះ?

**ឆ៖** តាមរយៈ៨៧០ តាមខ្ញុំយល់បាទ។ ប៉ុន្តែសហការតាមព្រំដែនហ្នឹង គេមានគណៈកម្មការគេ ជំនាន់ហ្នឹងបាទ។ ដល់គណៈកម្មការហ្នឹងគេរៀបចំពីខាងលើមកជាស្រេច គេមានឈ្មោះ មានអីៗគេ ប៉ុន្តែខ្ញុំអត់ចាំបានលម្អិតទេបាទ ដឹងៗតែមាន។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** តើអ្នកណាជាប្រធាន ឬក៏លេខាភូមិភាគឦសាន លោកនៅចាំទេ?

**ឆ៖** កាលពីជំនាន់ខ្ញុំនៅ កាលហ្នឹង តាយ៉ា គាត់នៅៗធ្វើជាលេខាភូមិភាគនៅឡើយបាទ។

**ស៖** តើលោកចាំថាមានរឿងអ្វីកើតឡើងចំពោះ តាយ៉ា ដែរឬទេ? តើ តាយ៉ា ហ្នឹងមានឈ្មោះថា ណី សារ៉ាន់ មែនទេ?

[០៩:១១:០៩]

**ឆ៖** ខ្ញុំមិនបានដឹងឈ្មោះៗផ្សេងក្រៅពី តាយ៉ា ទេបាទ ព្រោះកាលហ្នឹងគេហៅតែ តាយ៉ាៗ។ ព្រោះ តាយ៉ា ហ្នឹង កាលពីមុនគាត់ ប្រពន្ធគាត់ហ្នឹងជាសាច់ញាតិខាងខ្ញុំដែរ។ បាទ ខាងម្ដាយខ្ញុំ។ ត្រូវជាមីងជីដូនមួយ ខ្ញុំដឹង តែឈ្មោះគាត់ពីមុនទៀតអត់ដឹងទេបាទ។ ព្រោះគាត់ជាលេខាភូមិភាគ កាលជំនាន់ហ្នឹង។ ដឹងតែប៉ុណ្ណឹងបាទ។

**ស៖** តើលោកដឹងទេថា តាយ៉ា នោះត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយបន្ទាប់មកគេបោសសម្អាតគាត់?

**លោក អេនគ្រូ អ៊ីនូហ្សី៖**

អធ្យាស្រ័យលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យើងបានជម្រាបលោករួចហើយ យើងបានសម្រេចពីម្សិលមិញរួចហើយ យើងមិនអនុញ្ញាតឲ្យភាគីណាមួយជំនាន់តវ៉ាទៅនឹងការសួរដេញដោលរបស់ចៅក្រមទេ។ បានហើយយើងបានសម្រេចរួចហើយណ៎ះ យើងមិនអនុញ្ញាតឲ្យធ្វើដូច្នេះទេ។

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សួស្ដីអស់លោក លោកស្រី ខ្ញុំដឹងថាខ្ញុំមិនអាចជំទាស់ ក៏ប៉ុន្តែខ្ញុំសូមធ្វើការសង្កេតថា ការបោសសម្អាត--

[០៩:១២:៥២]

**ប្រធានអង្គជំនុំ៖**

អត់មានការសង្កេតអីទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី តើលោកចង់ឲ្យខ្ញុំសួរសំណួរនេះម្ដងទៀត ឬក៏លោកនៅចាំទេ? សំណួរខ្ញុំគឺថាតើលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះ តាយ៉ា ដែរឬទេ? ហើយបន្ទាប់មក តើមានអ្នកណាជំនួសតាយ៉ា?

**លោក ផាន វ៉ាន៖**

**ឆ៖** កាលជំនាន់ហ្នឹងបានដឹងដែរ ព្រោះគេប្រកាស ក្រោយពីបាត់ខ្លួនទៅ គេប្រកាសជាចំហ។ បាទ ប្រកាសថា “ក្បត់”។

**ស៖** ហេតុអ្វីបានជាគេថាគាត់ក្បត់? បើតាមការប្រកាសនោះថា គេចាត់ទុកគាត់ថាជាជនក្បត់ តើគាត់ក្បត់ហ្នឹងដោយសាររឿងហេតុអ្វីដែរ?

**ឆ៖** កាលជំនាន់ហ្នឹងគេប្រកាសថា "ក្បត់" ថាខ្សែយួន។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់ចោទសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការកំណត់អំពីខ្មាំង។ ដូច្នេះ ខ្ញុំចង់បង្ហាញឯកសារមួយចំនួនជូនលោក។ ឯកសារទី១ គឺឯកសារដែលមានលេខ E3/1111, ERN ជាភាសាបារាំង 00532706, ERN ជាភាសាខ្មែរ 00376671, ERN ជាភាសាអង់គ្លេស 00524192។ ទូរលេខនេះមានចំណងជើងថា "មតិណែនាំទៅ៩២០ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ ផ្ញើជូនសមមិត្ត ឈិន ជាទីស្នេហា"។ ឈិន នេះ ត្រូវបានគេសួររួចមកហើយ ក៏ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់ម្តងទៀត ថាតើ ឈិន នេះឬដែលជាលេខាកងពល ៩២០ នោះ?

**ឆ៖** បាទត្រឹមត្រូវហើយ ឈិន ហ្នឹង។

[០៩:១៦:១៧]

**ស៖** បាទ បើតាមអត្ថបទនោះគឺថា តាមដំណឹងពួកខ្មាំងសេរី ហើយជាភាសាអង់គ្លេសក៏គេប្រើពាក្យថា "ខ្មាំងសេរីនិយម"។ "ជាពិសេសពួក៧ វាធ្វើសកម្មភាពទាក់ទងគ្នាដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុងកងទ័ពយើង និងមូលដ្ឋានយើង។ ព្រមជាមួយនេះ វាមានទាក់ទងជនក្បត់ខ្លះដើម្បីបានបំផុសក្នុងប្រជាជនប្រឆាំងសហករណ៍ ប្រឆាំងមាគ៌ាបដិវត្តន៍សង្គមនិយមរបស់យើង និយាយរួមពិសេសបង្កប់ស៊ីរូងយូរអង្វែង។ ហេតុនេះត្រូវមានវិធានការដូចតទៅនេះ៖ ១) ត្រូវអប់រំគណៈកងពលទាំងមូល ឲ្យជ្រួតជ្រាបបទឧបាយកលខ្មាំងនេះ។ ២) ត្រូវតាមដានសមាសភាពណាដែលទាក់ទងនឹងពួក៧ ឬមាននិន្នាការនិយមពួក៧ ដើម្បីសម្រិតសម្រាំងកុំឲ្យកាន់នាទីដឹកនាំទ័ពទោះថ្នាក់ណាក៏ដោយ។ ចំពោះសមមិត្តដែលជាតំណាងកងពល ហើយមានភារៈនៅក្នុងគណៈទំនាក់ទំនងជាមួយពួក៧ ត្រូវជួយតាមដានសតិ-អារម្មណ៍ឲ្យជាប់ ហើយត្រូវមានការផ្លាស់ប្តូរសមាសភាពឲ្យញឹកញាប់កុំទុកសមមិត្តដដែលៗ។ តាមពិសោធន៍ ពួកអា៧ វាតែងអូសទាញគណៈទាក់ទងយើងឲ្យបំរើនយោបាយឈ្លានពានកម្ពុជារបស់វា។ កន្លែងខ្លះវាមានទាក់ទងបានអ្នកខ្លះ។ ហេតុនេះត្រូវប្រុងប្រយ័ត្ន កុំឲ្យវាស៊ីរូងកងទ័ពយើងបានដាច់ខាតតាំងពីកម្មាភិបាលដល់យុទ្ធជន។ ពិសេស កុំឲ្យមានការទាក់ទងឲ្យសោះចំពោះកងពលនៅតាមព្រំដែន។ ហត្ថលេខា ខៀវ"។ បាទ ខៀវ នេះខ្ញុំគិតថា ជា សុន សេន ហើយ "ចម្លងជូនបង៨១, បងសោម, បងណាត, បងវ៉ែន, ឯកសារ"។ តើចំពោះលោកផ្ទាល់នោះ តើលោកធ្លាប់ឮគេនិយាយអំពីថា ពាក្យថា

"ពួក៧" ទេ?

**ឆ៖** អត់ដែលបានឮទេបាទ "ពួក៧" នោះ។

**ស៖** ខ្ញុំនឹងអានឯកសារមួយទៀត គឺឯកសារ E3/1196, ERN ជាភាសាបារាំង 00597060, ERN ជាភាសាខ្មែរ 00000879, ERN ជាភាសាអង់គ្លេស 00506647។ ឯកសារនេះគឺជាទូរលេខ ៣៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ចុះហត្ថលេខាដោយឈ្មោះ ឆាន។

[០៩:២០:៥២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមមន្ត្រីតុលាការផ្តល់ជូនឯកសារនេះជូនសាក្សី។ លោកប្រធាន សូមអនុញ្ញាត!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ទូរលេខនេះចុះហត្ថលេខាដោយឈ្មោះ ឆាន ផ្ញើជូន ម-៨៧០។ តើលោកស្គាល់ទេអ្នកណាឈ្មោះថា ឆាន នេះ?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់បានស្គាល់ច្បាស់ទេបាទ ឈ្មោះ ឆាន នេះ។

**ស៖** តើលោកគិតថា ឆាន នេះមានទំនាក់ទំនងជាមួយឈ្មោះ ឡាំង ទេ? ព្រោះថាឈ្មោះ ឡាំង នេះគឺជាឪពុករបស់លោក។

**ឆ៖** អត់ដែលឮដែរបាទ។

**ស៖** បាទ ដូច្នេះសូមដកឯកសារនេះចេញពីដៃរបស់សាក្សី ហើយខ្ញុំនឹងអានសម្រង់នៅក្នុងឯកសារនេះ។ "ទូរលេខ៣៣ ជូន ម-៨៧០ ជាទីស្នេហា និងរឭក។ យើងសូមជូនដំណឹងសភាពការណ៍នៅតាមមូលដ្ឋាន សកម្មភាពដូចឆ្នាំ៧៤ ទៀត មានគប់នឹងដុំថ្មដាក់លើផ្ទះជាច្រើនកន្លែងទៀត ហើយឃើញមនុស្សពេលយប់ តែបាញ់វាមិនទាន់។ ២) អំពីសភាពការណ៍ពួក៧ នៅដដែល។ យើងលើកវិធានការឃោឃា បានឯកភាពទាំងកងពល និងកងតំបន់ហើយ"។ ខ្ញុំសូមបញ្ជាក់ថា ទូរលេខនេះត្រូវបានផ្ញើជូនបងនួន បាទគឺ នួន ជា នេះហើយ, បង ខៀវ ជា សុន សេន, មន្ទីរឯកសារ។

[០៩:២៣:៤០]

ឥឡូវនេះ ខ្ញុំចូលទៅឯកសារមួយផ្សេងទៀត។ ឯកសារនោះត្រូវបានផ្ញើ -- បង្ហាញជូនកាលពីម្សិលមិញដោយការិយាល័យសហព្រះរាជអាជ្ញារួចមកហើយ គឺឯកសារលេខ E3/877 ដែលមានលេខ

ERN ជាភាសាបារាំង 00283109, ERN ជាភាសាខ្មែរ 00021513, ជាភាសាអង់គ្លេស 00185 226។ ឯកសារនេះគឺជាទូរលេខដែលផ្ញើដោយឈ្មោះ "ឆាន, ជូនម-៨៧០ ជាទីស្នេហា នឹករឭក"។ លើកលែងតែខ្ញុំភ័ន្តច្រឡំ កាលពីម្សិលមិញលោកឆ្លើយថា "ឆាន នៅក្នុងទូរលេខនេះ គឺត្រូវបានផ្ញើដោយឪពុកលោក" គឺលោកឆ្លើយច្បាស់ណាស់ម្សិលមិញ។

[០៩:២៤:៤៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ សូមមន្ត្រីតុលាការផ្តល់ជូនឯកសារនេះទៅសាក្សី ដើម្បីឲ្យគាត់បញ្ជាក់ឲ្យបានច្បាស់។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:២៥:២៥]

**ស៖** លោកមាននឹកឃើញអំពីទូរលេខនេះទេ លោកសាក្សី?

**ឆ៖** ខ្ញុំសូមបញ្ជាក់លើឈ្មោះ ឆាន ហ្នឹងនៅក្នុងសារទូរលេខហ្នឹង។ ក្នុងចន្លោះឆ្នាំហ្នឹង បងខ្ញុំអ្នកធ្វើការ។ នេះចង់ឲ្យច្បាស់ប្រាកដហ្នឹង គឺទាល់សួរបងស្រីខ្ញុំបង្កើតហ្នឹង គាត់ច្បាស់។ ក្នុងចន្លោះឆ្នាំហ្នឹង។ ប៉ុន្តែតាមសារទូរលេខហ្នឹង តាមការសន្និដ្ឋានរបស់ខ្ញុំទេ គឺថាអាចគេដាក់ឈ្មោះ សម្ងាត់។ ព្រោះចំហអត់មាននិយាយឈ្មោះ អត់មានហៅឈ្មោះ ឆាន អីហ្នឹងក្រៅទេ ចំពោះឪពុកខ្ញុំ ហៅតែឈ្មោះ ឡាំងទេជំនាន់ហ្នឹង។ ឯក្នុងសារទូរលេខអាច ពីព្រោះវារបៀបរបរខាងខ្មែរក្រហមជំនាន់ហ្នឹងដូរ អត់មានក្រឹត្យក្រមទេ បន្តិចដូរៗ បន្តិចដូរពីនេះ បន្តិចដូរពីនោះ។ វាអ៊ីចឹង បាទសូមជម្រាប ឲ្យជ្រាបបាទ។

[០៩:២៦:៣៩]

**ស៖** ចំពោះខ្លឹមសារនៃឯកសារនេះ គេនិយាយអំពីការសង្ស័យចំពោះ អាសោម, អាឈិន ហើយកាលពីម្សិលមិញ មានការបញ្ជាក់ច្បាស់ហើយថា ឈិន នេះជាលេខាតំបន់ -- ជាលេខាកងពល ៩២០ ហើយគេរាយការណ៍ទៅដល់សមមិត្ត សាន។ តើលោកអាចប្រាប់បានទេថា អ្នកណាជាសមមិត្ត សាន នៅក្នុងទូរលេខនេះ?

**ឆ៖** សាន ហ្នឹងក្រោយមកគាត់ទទួល មកទទួលជំនួស ពូឈិន ជំនួសកងពល៩២០។

**ស៖** នៅក្នុងឯកសារនេះបានបញ្ជាក់ថា ពួកកង៩២០ ចាប់នៅធ្វើសកម្មភាពបន្តបន្ទាប់ទៀត តែយើងចាប់បន្តបន្ទាប់ដែរ។ តើលោកដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅកងពល៩២០ ដែរឬទេ?

**ឆ៖** កាលជំនាន់ហ្នឹងបាត់តែខ្លួនបន្តបន្ទាប់ដែរបាទ។ គ្រាន់តែដឹង ដឹងថាគេចាប់។

**ស៖** ខ្ញុំសូមចូលទៅឯកសារចុងក្រោយ គឺឯកសារ E3/1030 ERN ជាភាសាបារាំង 00623 150, ERN ជាភាសាខ្មែរ 00033312, ERN ជាភាសាអង់គ្លេស 00324806។ ទូរលេខនេះ ផ្ញើដោយឈ្មោះ "សុភា ជូនបង ឆាន ជាទីស្នេហានិងនឹករឭក"។ តើលោកស្គាល់ឈ្មោះ សុភា នេះទេ? អ្នកណាជា សុភា នៅក្នុងទូរលេខនេះ?

[០៩:២៩:១៩]

**ឆ៖** អាហ្នឹងអត់ប្រាកដទេ ព្រោះសុភា ហ្នឹងមាន សុភា អនុលេខាតំបន់ គាត់ទទួលខាងយោធាជំនាន់ហ្នឹងបាទ។

**ស៖** បាទ ខ្ញុំសូមអានឯកសារនេះ ហើយសូមលោកជួយផ្ដល់យោបល់ "យើងខ្ញុំសូមរាយ-ការណ៍សភាពការណ៍ពួក៧ ដូចតទៅនេះ៖ មុខព្រួញអូរផ្ដាយ -- (ខ្ញុំសូមអភ័យទោសផង ប្រសិនបើខ្ញុំអានឈ្មោះមិនត្រូវ) វាបានចូលដីយើងចំនួន ២០ម៉ែត្រ ហើយវាមកកាប់ឫស្សី ហើយយើងបានវាយពួកវាស្លាប់ និងរបួសមួយចំនួន"។ ដូច្នេះនៅទីនេះគឺមានពន្យល់ថា មានការវាយប្រហារគ្នា។ ហើយនៅកថាខណ្ឌ២ បញ្ជាក់ថា "ពួក៧ ដែលវាវាយយើងនៅពេជ្រចិន្ដានោះ ឥឡូវដានវាចូលមកទិសភូមិពូជ្រីចាស់"។ តើឥឡូវនេះលោកមាននឹកឃើញហើយឬនៅថា ពួក៧នេះជាអ្នកណា?

**ឆ៖** បើតាមខ្ញុំស្ដាប់ខ្លឹមសារនៃសារហ្នឹង សន្និដ្ឋានថា ពួក៧។ បានកំណត់ថាពួកយួនជំនាន់ហ្នឹងអាចៗអ៊ីចឹងបាទ ពីព្រោះសារហ្នឹងពីព្រំប្រទល់មកៗតំបន់។ ហ្នឹងតាមការយល់របស់ខ្ញុំទេ ជាតាមរបៀបរបរធ្វើការហ្នឹងវាៗរបៀបហ្នឹងបាទ កាលជំនាន់ហ្នឹង។ ហ្នឹងខ្ញុំក៏អាចសន្មតថាប្រាកដដែរ អារឿងហ្នឹងបាទ "ពួក៧"ហ្នឹងកំណត់ថាពួកៗយួន។ មានប៉ុណ្ណឹង។

[០៩:៣១:៤១]

**ស៖** បើតាមលោកដឹង តើពួកទាហានដែលនៅក្នុងពេលប្រយុទ្ធតស៊ូបដិវត្តន៍នោះ ស្ថិតនៅក្នុងក្រុមដែលដឹកនាំដោយពួកវៀតណាមដែរឬទេ? ហើយបន្ទាប់មកត្រូវ -- បន្ទាប់មក គេចាត់ទុកពួកនុ៎ងថាជា "ខ្មាំង"?

**ឆ៖** អត់ ស្ដាប់សំណួរអត់បាន។ សូមលោកៗបញ្ជាក់ម្ដងទៀតបាទ។

**ស៖** ក្នុងចំណោមកងទ័ពដែលជាកងកម្លាំងរបស់ខ្មែរក្រហមនោះ មានទាហានខ្លះនោះ ដែលកាលពីមុននោះគឺស្ថិតនៅក្រោមការបញ្ជារបស់ពួកវៀតណាម។ តើលោកដឹងអំពីហេតុការណ៍ហ្នឹងដែរឬទេ?

**ឆ៖** ដឹងបាទ កាលជំនាន់ហ្នឹង កាលដំបូងឡើយហ្នឹងនៅជាមួយវៀតណាមដែរកាលហ្នឹងបាទ។ ពួកនៅមណ្ឌលគិរីនៅការពារទុយោសាំង ល្បាត ការពារទុយោសាំងឲ្យខាងវៀតណាមអង្កាល់ជំនាន់មិនទាន់ៗឈ្លោះគ្នាបាទ។

**ស៖** គឺប្រហែលជាចាប់ពីឆ្នាំ៧៣ មានកិច្ចព្រមព្រៀងមួយដើម្បីកុំឲ្យទាហានទាំងអស់នោះនៅក្រោមការដឹកនាំរបស់វៀតណាម គឺមកស្ថិតនៅក្រោមការបញ្ជារបស់ខ្មែរក្រហមវិញ។ តើលោកមានចាំអំពីហេតុការណ៍ហ្នឹងទេ?

[០៩:៣៣:៤៨]

**ឆ៖** ចាំៗបានខ្លះ។ បាទ ប៉ុន្តែគ្រាន់តែថាអត់មានទាហានវៀតណាមមកធ្វើមេអីនៅហ្នឹង អត់មានទេ គ្រាន់តែថាសហការគ្នាជំនាន់ហ្នឹង។ ហើយក្រោយមកក៏អត់សហការគ្នាហ្នឹង វ៉ៃគ្នាបណ្តោយដឹងតែវ៉ៃគ្នាក្រោយមកវ៉ៃគ្នារហូតតាំងពីចុងចិត -- ពាក់កណ្តាល៧៥។ រំដោះភ្នំពេញហើយវ៉ៃគ្នា គេឲ្យទៅវ៉ៃនៅព្រំដែន ខ្ញុំអីក៏ទៅដែរបាទ នៅក្មេងៗ ទៅដឹកជញ្ជូន ទៅអីឲ្យកងទ័ពអ៊ីចឹងបាទ។ ចង់បញ្ជាក់ប៉ុណ្ណឹង។

**ស៖** ហើយចុះគេសហការគ្នារវាងខ្មែរក្រហមនិងវៀតណាមហ្នឹង គេសហការគ្នាលើបញ្ហាអ្វីដែរ?

**ឆ៖** កាលដំបូងឡើយ សហការគ្នាវ៉ៃពួកធីវគីនៅតាមព្រំដែនហ្នឹងបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណ លោកសាក្សីដែលបានឆ្លើយចំពោះសំណួររបស់ខ្ញុំ។ លោកប្រធានខ្ញុំ អស់សំណួរហើយ។

[០៩:៣៥:៣២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ លោកសាក្សី ហើយសូមអរគុណដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្ម។ ហើយខ្ញុំជាមេធាវីរបស់

លោក នួន ជា ជាមួយលោកសហសេវិករបស់ខ្ញុំ សុន អរុណ យើងនឹងមានសំណួរសួរទៅលោកមួយចំនួនថ្ងៃនេះ។ ខ្ញុំសូមចាប់ផ្ដើមសួរ។ ខ្ញុំសូមបញ្ជាក់ជូនអំពីផ្នែកដែលខ្ញុំនឹងសួរលោក។ ជាបឋមខ្ញុំចាប់ផ្ដើមសំណួរមួយចំនួនទាក់ទងពីការយល់ដឹងរបស់លោកអំពី តាសារុន ដែលលោកបាននិយាយ។ បន្ទាប់មក ខ្ញុំនឹងនិយាយអំពីអ្វីដែលដែលលោកនិយាយអំពីប្រព័ន្ធទំនាក់ទំនងនៅក-១៧ តំបន់១០៥ ហើយនៅចំណុចបញ្ចប់គឺថាខ្ញុំនឹងសួរអំពីបញ្ហាផ្សេងៗទាក់ទងទៅនឹងបទពិសោធន៍របស់លោកមុនឆ្នាំ១៩៧៥។

[០៩:៣៦:៥៦]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក អេនឌ្រូ អ៊ីនួហ្វ៊ី៖**

**ស៖** មុននឹងចាប់ផ្ដើមខ្ញុំសូមបញ្ជាក់ជាមួយលោកអំពីអាសយដ្ឋានបច្ចុប្បន្នរបស់លោកគឺថានៅក្នុងស្រុកម៉ាឡៃ បើសិនជាលោកមិនប្រកាន់ទេ សូមលោកប្រាប់ខ្ញុំជាថ្មីម្ដងទៀតឲ្យច្បាស់ថាតើផ្ទះរបស់លោកជាក់លាក់ នៅកន្លែងណាភូមិអី ស្រុកអីនៅក្នុងកម្ពុជានោះបាទ?

**លោក ផាន វ៉ាន់៖**

**ផ៖** បាទខ្ញុំនៅស្រុកម៉ាឡៃ ឃុំ -- នៅឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ហើយផ្ទះអត់ដឹងលេខផ្ទះ០១ ផ្លូវផ្សារតាព្រហ្មបាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកនៅតំបន់នោះរយៈពេលប៉ុនណាហើយ?

**ផ៖** ខ្ញុំទៅនៅម៉ាឡៃ ក្រោយអ៊ុនតាក់ ក្រោយអ៊ុនតាក់ចូល ទៅនៅម៉ាឡៃ។

**ស៖** សូមអរគុណ។ ចុះមុនពេលដែល អ៊ុនតាក់ មកដល់ តើលោករស់នៅឯណា?

**ផ៖** មុនអ៊ុនតាក់ មកដល់ ខ្ញុំនៅច្រក៥០៥។

[០៩:៣៨:៤៣]

**ស៖** នៅក្នុងទីប្រជុំជនណា? ឬក៏នៅស្រុកណា?

**ផ៖** ជំនាន់នោះអត់មានទីប្រជុំជនទេ គេហៅច្រក ៥០៥ តែម្ដង តែបច្ចុប្បន្ននេះ គេហៅច្រកច្រកហ្នឹង ច្រកថ្មដាវ។ ច្រក ៥០៥ ជំនាន់ហ្នឹង កន្លែងមន្ទីររបស់អ៊ំ នួន ជា, ហើយអ៊ំ ខៀវ សំផន, តាប៉ុល ពត នៅហ្នឹងទាំងអស់ ទីបញ្ជាការរួមនៅហ្នឹង។

**ស៖** សូមអរគុណ។ ថាតើនៅក្នុងភូមិភាគពាយ័ព្យ នៅភាគពាយ័ព្យនៃប្រទេសកម្ពុជាឬកន្លែងនោះៗ?

**ឆ៖** នៅហ្នឹងវាព្រំប្រទល់ពោធិ៍សាត់ និងកោះកុង។ កន្លែងហ្នឹងមិនដឹងឥឡូវគេហៅភូមិភាគពាយ័ព្យ ឬស្អី ឥឡូវខ្ញុំអត់ច្បាស់ដែរ តែវាទល់នឹងខេត្តត្រាត ប្រទេសថៃបាទ។

**ស៖** សូមអរគុណ។ ដូច្នេះដើម្បីយើងច្បាស់នោះ លោកនិយាយអំពីព្រំដែន គឺៗជាព្រំប្រទល់រវាងថៃ និងខ្មែរ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ពីបញ្ហាខ្លឹមសារ ដូចដែលខ្ញុំបញ្ជាក់ខាងដើម ខ្ញុំចាប់ផ្តើមអំពី សៅ សារុន។ លោកបានប្រាប់តុលាការថា ឪពុករបស់លោកជាលេខាទទួលបន្ទុកនៅក-១៧ ហើយគាត់ -- តាសារុន មកជំនួសគាត់ ជាអ្នកទទួលតំណែងបន្តពីលោក ឪពុកលោកបានស្លាប់ទៅ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[០៩:៤១:១៣]

**ស៖** សូមអរគុណ។ អនុលោមតាមចម្លើយដែលលោកបានឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ អ្នកស៊ើបអង្កេតមកពីការិយាល័យនោះ គេបានសួរលោកថា "តើលោកស្គាល់ ដឹងពីការសម្លាប់នៅតំបន់១០៥ ដែរឬទេ?" ហើយលោកបានឆ្លើយដូចខាងក្រោមនេះ, ខ្ញុំដកស្រង់ "នៅក្នុងពេលដែលឪពុកខ្ញុំធ្វើការនៅទីនោះ គឺមិនមានការសម្លាប់មនុស្សទេ ប៉ុន្តែនៅក្នុងសម័យ តាសារុន មានការសម្លាប់ -- ការចាប់មនុស្សទាំងគ្រួសារ ប៉ុន្តែខ្ញុំមិនដឹងថាគេយកគ្រួសារទាំងអស់នោះទៅសម្លាប់នៅកន្លែងណាទេ"។ ហើយខ្ញុំនឹងសួរសំណួរបញ្ហានេះ ដើម្បីឲ្យតុលាការបានជ្រាប ដើម្បីឯកសារយោងនោះ គឺលោកបានឃើញឯកសារនេះរួចហើយ គឺ E327 គឺកំណត់ហេតុសួរចម្លើយលោក គឺអ្នកស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេត គឺថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩។ ផ្នែកដែលខ្ញុំបានអានអំមិញនេះ គឺនៅក្នុងទំព័រ៦ អង់គ្លេសគឺ ERN 002920508, ហើយខ្មែរ 00287705, ហើយបារាំង 00353104។ បាទ ដូច្នេះ "ក្នុងសម័យឪពុករបស់ខ្ញុំ គឺមិនមានការសម្លាប់ទេ ប៉ុន្តែក្នុងសម័យតា សារុន គឺមានការចាប់ខ្លួនមនុស្សទាំងមូល ដើម្បីយកទៅសម្លាប់ ប៉ុន្តែមិនដឹងថាគេសម្លាប់នៅកន្លែងណាទេ"។ សំណួររបស់ខ្ញុំ ខ្ញុំសួរថា តើនេះជាចម្លើយត្រឹមត្រូវដែលថា "នៅពេលដែលតា សារុន កាន់តំបន់១០៥ នោះ គឺថាមានគ្រួសារខ្លះត្រូវបានគេចាប់ទាំងស្រុង ហើយយកទៅសម្លាប់ ប៉ុន្តែខ្ញុំមិនដឹងសម្លាប់នៅកន្លែងណា"។ នេះនៅក្នុងឯកសារ E3/57 ដែលខ្ញុំបានសួរលោកនេះបាទ។

 

[០៩:៤៣:២២]

**ឆ៖** បាទ ត្រឹមត្រូវ។ ការចាប់ហ្នឹង ខ្ញុំក៏មិនបានដឹងថាគេចាប់ គេអីទេ គ្រាន់តែជំនាន់ហ្នឹង គេហៅមកធ្វើការបាត់ តែថាជំនាន់ តាសារុន មានការសម្លាប់ទាំងគ្រួសារៗហ្នឹង ក៏បាត់អីចឹងដូចតែគ្នាដែរ បាទ។ ព្រោះកាលជំនាន់ឪពុកខ្ញុំនៅបាត់តែមួយស្រកក្រុមគ្រួសារខាងៗ ពូជូន ទេ ជំនាន់ហ្នឹង។ គេហៅមកធ្វើការមកបាត់អីចឹង។ ហើយក្រោយមកទៀតហ្នឹង ក្រុមនីរសារខាងឪពុកខ្ញុំនោះ ក៏បាត់ទាំងអស់ៗតែគ្នា អត់មានអ្នកណានៅសល់អីមួយទេ។ មករហូតដល់កាលសម័យរត់យួនហ្នឹង បានដឹង សួរនាំទៅថាអត់មានអ្នកណានៅមួយទេ បាត់ខ្លួនអស់ហើយ។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង ត្រឹមត្រូវតាមដែលលោកសួរបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងចូលទៅដល់មួយទៀត ប៉ុន្តែថាឯកសារមួយទៀត ឯកសារនេះគឺៗបានដាក់ជូនអង្គជំនុំជម្រះហើយ គឺថាលេខត្រូវបានប្រើនៅក្នុងតុលាការរួចហើយ គឺ E3/1664។ គឺជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហៅថា ឌី.ស៊ី.ខេម គឺមានចំណងជើងថា “ការបោសសម្អាតខ្មែរក្រហមនៅមណ្ឌលគិរី” គឺឯកសាររបស់ ឌី.ស៊ី.ខេម នេះគឺឯកសារ ERN គឺជាភាសាខ្មែរ 003968 (ស៊ីក) រហូតទៅដល់ --

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យមេធាវី គាត់អាន ERN លឿនបន្តិច។ អ្នកបកប្រែ ថាមិនទាន់ទេបាទ។

[០៩:៤៥:១៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអានចាប់ពីលេខឯកសារ លេខ ERN ជាភាសាផ្សេងៗហ្នឹង គឺអានសាឡើងវិញ ព្រោះលោកអានលឿនពេក អ្នកបកប្រែ បកមិនទាន់ទេ។ អានឲ្យយឺតបន្តិចដើម្បីឲ្យ ទុកលទ្ធភាពឲ្យអ្នកបកប្រែអាចបកប្រែបាន។

**លោក អេនគ្រូ អ៊ីទ្ធហ្ស៊ី៖**

សូមអភ័យទោស លោកប្រធាន អ្នកបកប្រែផងដែរ។

**សួរដោយលោក អេនគ្រូ អ៊ីទ្ធហ្ស៊ី៖**

**ស៖** ខ្មែរ ERN 00397566 រហូតដល់ 00397749, បារាំង ERN 00742838 រហូតដល់

00742889។ ខ្ញុំចាប់អារម្មណ៍នៅក្នុងចំណុចពីរ នៅក្នុងឯកសារនេះ។ ខ្ញុំមិនដឹងថា ERN ជាភាសាអង់គ្លេសនោះទេ ប៉ុន្តែមានការបកប្រែ ប៉ុន្តែខ្ញុំមិនបាន ERN ទេ។ ទំព័រទី១ អង់គ្លេស គឺ00397653។

លោកសាក្សី ខ្ញុំនឹងអានផ្នែកមួយចេញពីឯកសារនេះ ហើយខ្ញុំនឹងសួរលោកសំណួរមួយចំនួនអំពីខ្លឹមសារនោះ។ ខ្ញុំនឹងប្រែបីចំណុច ប៉ុន្តែខ្ញុំសួរម្ដងមួយម្ដង។ ជាថ្មីម្ដងទៀត មួយមុនគេនេះ ខ្ញុំដកស្រង់ចេញពី "ដោយមាន ខាំ ស្លាប់ទៅ គឺសារុន ជាជនជាតិឡាវ ក្លាយជាលេខាតំបន់១០៥ ជំនួសរវាង ខាំ ភូន ហើយនិង ហាម ហើយនិងការបន្តុប សារុន ជាលេខាតំបន់។ នាំឲ្យមានការអនុវត្តវិន័យតឹងតែង ហើយនិងធ្វើឲ្យមានមនុស្សស្លាប់កាន់តែច្រើននៅក្នុងតំបន់ផង"។ សំណួរទី១ ទៅលោកសាក្សីនោះ គឺសូមលោកបញ្ជាក់ថា តើ ហាម នេះគឺជាឈ្មោះរបស់ឪពុកហៅក្រៅរបស់លោកដែរឬទេ?

**លោក ផាន វ៉ាន៖**

**ផ៖** បាទ ឈ្មោះ ហាម ហ្នឹងជាឈ្មោះហៅក្រៅរបស់ឪពុកខ្ញុំដែរ។ អានេះឈ្មោះភាសាឡាវគេហៅ ហាម។

**ស៖** សូមអរគុណ។ សំណួរមួយទៀត តើត្រូវដែរឬទេ តាមអ្វីដែលលោកដឹងនោះ អ្នកណាជាអ្នកដាក់វិន័យឲ្យតឹងជាងមុននៅក្នុងតំបន់១០៥ គឺថា បាទនៅក្រោមសម័យលោក សារុន ហើយនិងបន្ទាប់ពីឪពុករបស់លោកស្លាប់ទៅនោះ?

**ផ៖** ខ្ញុំមិនបានដែរ ព្រោះខ្ញុំអត់នៅតំបន់នោះបាទ ជំនាន់ហ្នឹង។ ព្រោះដោយសារការយល់របស់ខ្ញុំ ព្រោះថ្នាក់ដឹកនាំក្រោមៗ គឺថាអត់បទបញ្ជាពីខាងលើទេ អត់មានអ្នកប៊ានទេ ជំនាន់ហ្នឹងបាទ។ អាហ្នឹងជាទម្លាប់ទូទៅអ៊ីចឹងម្ដង គឺគ្មានអ្នកណាប៊ានទេ។ នេះសូមបញ្ជាក់លោកមេធាវីអ៊ីចឹងបាទ។ ព្រោះជំនាន់ហ្នឹង មនុស្សវិន័យណាស់បាទ។

[០៩:៤៩:០៥]

**ស៖** សូមអរគុណ។ ហើយលោកបានប្រាប់តុលាការថា តាមពិតនោះ គឺមានការចាប់មនុស្សកាន់តែច្រើន ហើយមានការកាប់សម្លាប់ក្រោមការដឹកនាំរបស់ សារុន តើលោកយល់ស្របជាមួយផ្នែកនេះទេ នៅក្រោមការដឹកនាំរបស់ សារុន នៅសម័យកាលនោះ គឺពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្សច្រើនជាងកាលសម័យដែលឪពុកលោកកាន់កាប់? បាទ តើអ៊ីចឹងដែរឬទេ?

**ផ៖** តាមដឹង ក្រោយមកដែលតាមមិត្តភក្តិស្គាល់មក កាលរត់យួនមកហ្នឹង គឺឃើញបាត់គ្នាច្រើន បាទ គ្នាច្រើនមែនបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកមួយទៀត។ នៅក្នុងឯកសារដដែលនេះ នៅបន្ទាប់ ទំព័របន្ទាប់ភាសាអង់គ្លេស គឺៗ 00397654 ខ្ញុំដកស្រង់ពីឯកសារនេះគឺថា "អ្នកផ្តល់ព័ត៌មានជាច្រើនបានកត់សម្គាល់អំពីការកែប្រែដ៏ធ្ងន់ធ្ងរនៅមណ្ឌលគិរី ដល់ចុងឆ្នាំ១៩៧៧ ហើយនិងឆ្នាំ១៩៧៨ នៅពេលដែល សារុន ចូលមកកាន់អំណាច"។ ដូច្នេះម្តងទៀត គឺផ្អែកតាមអ្វីដែលលោកដឹងផ្ទាល់ ឬក៏លោកឮពីអ្នកដទៃ តើលោកយល់ស្របជាមួយការវាយតម្លៃបែបនេះទេ គឺមានការកែប្រែធ្ងន់ធ្ងរនៅក្នុងមណ្ឌលគិរី បន្ទាប់ពី សារុន កាន់តំណែងនៅក្នុងតំបន់១០៥?

**ឆ៖** តាមការឃើញ បាទ ឃើញបាត់មនុស្សអីចឹងមក សួរគេអ្នកនេះនៅអត់? អ្នកនោះនៅអត់? ឧបមាសួរ "បងក" អ៊ីចឹង គាត់នៅឯណា ឥឡូវធ្វើអីៗអ៊ីចឹងទៅសួរទៅ។ ដល់អ៊ីចឹងគេថាបាត់អស់ហើយ។ តែដឹងនោះដឹងក្រោយដែលរត់ចូលព្រៃនេះហើយទេបានដឹងបាទ ខ្ញុំ។ ពីព្រោះមិនបានទំនាក់ទំនងអីជាមួយខាងតំបន់ទេជំនាន់ហ្នឹង។

[០៩:៥១:២៣]

**ស៖** សូមអរគុណលោកច្រើន។ ហើយផ្នែកទី៣ នៅក្នុងឯកសារដដែលទំព័រដដែល ខ្ញុំសូមដកស្រង់ "បន្ទាប់ពី សារុន ក្លាយទៅជាលេខាតំបន់ គេចាប់មនុស្សជារៀងរាល់ថ្ងៃ គឺបួនប្រាំនាក់រៀងរាល់ថ្ងៃ។ ប្រធានសហករណ៍បានព្យាយាមបំភិតបំភ័យកាន់តែខ្លាំង ហើយប្រាប់ថា សារុន នឹងសម្លាប់អ្នកណាដែលខ្ជិល"។ ជាថ្មីម្តងទៀត តើលោកបានដឹងដែរឬទេ តាមបទពិសោធន៍ និងការដឹងរបស់លោក តើនេះជាការត្រឹមត្រូវដែរឬទេដែលគេនិយាយបែបនេះនៅក្នុងតំបន់១០៥ បន្ទាប់ពី សារុន ឡើងកាន់អំណាចមកនោះ?

**ឆ៖** នេះបញ្ហាហ្នឹងដូចខ្ញុំមិនយល់ស្របទេបាទ ដូចគ្មានអ៊ីចឹងទេតាមមើល៍។ ជំនាន់ហ្នឹងវាមិនមែនដល់ថ្នាក់មនុស្សខ្ជិលក៏សម្លាប់ដែរ អត់មានទេ លុះត្រាតែកំណត់ថា "ខ្មាំង" បានគេចាប់បាទ។ អាហ្នឹងបើចង់ប្រាកដនោះទាល់តែសួរគាត់ខ្លួនឯង បានៗច្បាស់។ ព្រោះ តាសារុន គាត់នៅរស់នៅឡើយបាទ។ ហើយអ្នកនៅជិតខាង ក៏យើងអាចស៊ើបអង្កេត សួរនាំដឹងការពិតថែមទៀត ព្រោះអ្នកនៅមណ្ឌលគិរីមកនៅអន្លង់វែងច្រើនបាទ កាលពីជំនាន់ហ្នឹង។ សំខាន់ពួកនៅជុំវិញគាត់បណ្តោយ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង។

[០៩:៥៣:០៣]

**ស៖** សូមអរគុណលោកសាក្សី។ អ្វីដែលខ្ញុំយល់ច្បាស់នោះ គឺថាលោកមិនយល់ស្របជាមួយ

ផ្នែកដែលចង្អុលបង្ហាញថា "គេសម្លាប់មនុស្សអ្នកដែលខ្ជិលនោះទេ"។ តើជាគំនិតលោកអ៊ីចឹងដែរឬទេ?

**ឆ៖** ជាគំនិតខ្ញុំ ខ្ញុំដូចអត់ ដូចៗមិនជឿថា មនុស្សខ្ជិលក៏យកទៅសម្លាប់ អត់ៗដូចអត់ដល់ថ្នាក់ហ្នឹងទេ។ នេះខ្ញុំបញ្ជាក់ប៉ុណ្ណឹងបាទ។ ពីព្រោះគេមានហេតុផលរបស់គេដែរបាទ ពិតមែនថាជំនាន់ហ្នឹងវាៗខុសមែន ប៉ុន្តែអាកំប៉ិកកំប៉ុកអ៊ីចឹង ដូចមិនដល់ថ្នាក់សម្លាប់ទេបាទ។ និយាយរួម លុះត្រាតែគេចោទថា "ខ្មាំង" អាហ្នឹងបានៗគេបញ្ជូនមកខាងក្រោមអ៊ីចឹង។ អាចអ៊ីចឹង។ ព្រោះតាមការសួរ ការនាំអីទៅ គេមានៗតែអ៊ីចឹងមានបញ្ជូនមកក្រោមទាំងអស់។ បាទ មានប៉ុណ្ណឹង។

[០៩:៥៤:១៣]

**ស៖** សូមអរគុណដែលលោកបានឆ្លើយ ខ្ញុំយល់។ កាលពីម្សិលមិញ ឬក៏ថ្ងៃម្សិលម្ង៉ៃលោកបានពិភាក្សាជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ ដែលហៅថាគឺ "វិន័យ១២ប្រការ" ហើយខ្ញុំជឿថាលោកមិនហៅថា "វិន័យជាក់លាក់" នោះទេ ប៉ុន្តែលោកចាំខ្លឹមសារសំខាន់ៗនៃវិន័យនោះដែលលោកបាននិយាយ។ គឺត្រូវគោរពមនុស្ស ទី១ ដែលលោកចាំ។ តើត្រូវដែរឬទេ?

**ឆ៖** ត្រូវបាទ ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ហើយលោកបានបន្តនិយាយថា នៅក្នុងការឆ្លើយឆ្លងជាមួយសហព្រះរាជអាជ្ញានោះ ដែលលោកចង្អុលបង្ហាញថា ក្រោយមកនៅក្នុងកម្ពុជាប្រជាធិបតេយ្យគឺមនុស្សបាន មិនសូវអនុវត្តទៅតាមវិន័យនោះទេ គឺងាកចេញ ហើយលោកបាននិយាយថា គេប្រើវិន័យផ្ទាល់ខ្លួនរបស់ក្រុមគេ។ តើលោកបាននិយាយបែបនោះដែរឬទេ?

[០៩:៥៥:៣៤]

**ឆ៖** មិនបាននិយាយទេ ដូចមិនបាននិយាយទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំអាចនឹងអានជូនលោកស្តាប់វិញនូវអ្វីដែលប្រតិចារឹកតុលាការបានកត់ត្រា ប្រសិនបើ ខ្ញុំសូមដកស្រង់អំពីប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី១១ ខែធ្នូ គឺ២ថ្ងៃកន្លងទៅនេះទំព័រ៨៣ បន្ទាប់ ១ ដល់១២ គឺចំណុច១២។ វិន័យ១២ប្រការដែលលោកបាននិយាយនោះ គឺថាលោកនិយាយថា "វិន័យ១២ប្រការហ្នឹង សំខាន់នោះគឺខ្ញុំមិនចាំទេ គឺថា គឺត្រូវសីលធម៌និងរស់--ពីដើមនោះ គឺត្រូវប្រកាន់គោរពវិន័យនេះ។ ប៉ុន្តែក្រោយមកគឺថា មានការចោទប្រកាន់ថា គេមិនគោរពតាមមាគ៌ាបក្ស ហើយក៏គេមិនគោរពវិន័យសីលធម៌នេះទេ ប៉ុន្តែការពិតគេត្រូវគោរពគ្នាទៅវិញទៅមក គឺថាក្រោយ មកគេមិនគោរពតាមសីលធម៌១២ប្រការទេ គេប្រើសីលធម៌របស់គេវិញ"។ នេះជាប្រតិចារឹក

របស់តុលាការ តាមចម្លើយរបស់លោកឆ្លើយប្រាប់តុលាការ។ តើអ្វីដែលខ្ញុំអាននេះជាផ្ទុះបញ្ចាំងពីចម្លើយជាភស្តុតាង ជាសក្ខីកម្មរបស់លោកប្រាប់តុលាការដែរឬទេ?

[០៩:៥៧:១១]

**ឆ៖** ខ្ញុំបានប្រាប់តុលាការអ៊ីចឹងមែន។ អាហ្នឹងជាការពិតខ្ញុំឧទាហរណ៍ប៉ុណ្ណោះ ចង់ឲ្យខាងហ្នឹងយល់ ព្រោះអីអាសីលធម៌ ១២ប្រការហ្នឹងកាលពីជំនាន់សង្គ្រាមគឺអនុវត្តតឹងរ៉ឹងណាស់ ជំនាន់នៅចាយលុយ ចាយកាក់ ហ្នឹងដូចនៅមណ្ឌលគិរីអ៊ីចឹងវាមានលោកមានបុណ្យមានទានមានអី សូម្បីតែម្ទេសមួយផ្លែ យករបស់ប្រជាជនក៏ត្រូវតែចាយលុយឲ្យគេដែរ។ អត់មានយកទទេទេ។ តែក្រោយមកអត់មានអ៊ីចឹងទេ។ អត់មានយកអាហ្នឹងមកអនុវត្តទេ គឺថា របៀបបំបិទទាំងអស់តែម្តង អត់មានស្អី ស្អីក៏យកបើគ្នាអស់ហើយ យករបស់ប្រជាជនទាំងអស់។ ហើយស្អីៗក៏ដាក់រួម ខ្ញុំចង់ឧទាហរណ៍ឲ្យឃើញអ៊ីចឹង។ ហ្នឹងជំនាន់ហ្នឹងវាអ៊ីចឹងមែន។ លោកក៏អត់មាន ស្អីក៏អត់មាន ដូច្នេះវានៅជាសម្ភារសហភាពទាំងអស់តែម្តងជំនាន់ហ្នឹងក្រោយពីឈប់ចាយលុយ ក្រោយពីឈប់ហូបបាយឯកជនមកបាទ។

[០៩:៥៨:២៤]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកយល់ស្របដែរឬទេថា លោក -- ថាពុករបស់លោកគោរពទៅតាមសីលធម៌នេះ ហើយគាត់បានគោរពតាមអស់ពីលទ្ធភាពតាំងពីដំបូងមកនៃរបបកម្ពុជាប្រជាធិបតេយ្យនោះបាទ?

**ឆ៖** ជំនាន់ហ្នឹងក្រោយមកតាមខ្ញុំយល់ការរស់នៅស្អីៗហ្នឹងឪពុកខ្ញុំគាត់ក៏អត់ឯកភាពតាមហ្នឹងទេ ពីព្រោះគាត់ម្នាក់ៗចង់ជំទាស់ដែរតែវាមិនប៉ានជំនាន់នោះ គេនិយាយអ៊ីចឹង ឮតែគេ ឮចាស់ៗនិយាយទេ ខ្ញុំវានៅក្មេងជំនាន់ហ្នឹងវាមិនទាន់យល់ពីរឿងនយោបាយជ្រៅជ្រះចង់ដឹង ចង់ឮ ការប្រព្រឹត្តស្អីៗ ខាងនយោបាយអត់ដឹងទេជំនាន់នុ៎ង ដឹងតែពីធ្វើ តែឮគេនិយាយ។ ដល់អ៊ីចឹង អ្នកណាក៏អត់ពេញចិត្តដែរជំនាន់នុ៎ងរកតែគ្រាប់ស្គរហូបមួយគ្រាប់ក៏គ្មានផង ចង់និយាយអ៊ីចឹង។

**ស៖** ដើម្បីឲ្យខ្ញុំយល់ច្បាស់តើលោកនិយាយថាឪពុករបស់លោក ហើយនិងអ្នកដទៃទៀតគឺ មិនយល់ស្របអំពីការអនុវត្តរបស់កម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែគេជឿជាក់លើសីលធម៌នេះ។ ប៉ុន្តែគេមិនពេញចិត្ត ប៉ុន្តែគេមិនប៉ាននិយាយ តើនេះជាគំនិតដែលលោកចង់ជម្រាបតុលាការបែបនេះឬ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១០:០០:០៥]

**ប្រធានអង្គជំនុំ៖**

ចាំៗក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណ៎ះ!

**លោក ផាន វ៉ាន៖**

**ផ៖** បាទ ដូចខ្ញុំបានបញ្ជាក់អំមិញហ្នឹងហើយ ម្នាក់ៗអត់ពេញចិត្តទេ ប៉ុន្តែអត់ប៊ាន អត់ប៊ាន តវ៉ា។ តវ៉ាគេថាក្បត់ទៀតហើយ។ អាហ្នឹងចូលក្បត់ធំហើយជំនាន់ហ្នឹង។

**សួរដោយលោក អេនគ្រូ អ៊ីទួហ្ស៊ី៖**

**ស៖** សូមអរគុណ។ ចុះតា សារុន វិញ តើលោកយល់ស្របដែរឬទេ ដែលលោកបានប្រាប់រួចហើយថា អំពីការកើនឡើងនៃការកាប់សម្លាប់មនុស្សនៅពេលដែលគាត់កាន់អំណាច ហើយនិងការកែប្រែការគ្រប់គ្រង។ ថាតើលោកដឹងទេថាតាសារុន គ្រប់គ្រងខុសពីឪពុករបស់លោកដែរឬទេ? ប្រហែលថា តាសារុន ខ្លួនឯងនោះ អាចនឹងងាកចេញ មិនគោរពតាមសីលធម៌១២ប្រការនេះដោយខ្លួនគាត់? តើលោកយល់ស្របអ៊ីចឹងដែរឬទេបាទ?

[១០:០១:១៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ជម្រាបសួរលោកប្រធាន សំណួរនេះសូមឲ្យសាក្សីឆ្លើយព្រាវៗអ៊ីចឹង ព្រោះសាក្សីបាននិយាយហើយថា គាត់មិនមានវត្តមាននៅទីនោះទេ។ ហើយអ៊ីចឹងសំណួរនេះហាក់ដូចជាជំរុញឲ្យសាក្សីកំណត់ពីការអនុវត្តនៅក្រោមរបប តាសារុន ហើយពេលនោះៗ គាត់មិនមែននៅតំបន់១០៥ទេ គាត់នៅភ្នំពេញណោះ។ ដូច្នេះជាសំណួរជំរុញឲ្យគាត់ឆ្លើយព្រាវៗនៅពេលដែលគាត់អវត្តមាននៅតំបន់១០៥នោះ គាត់នៅភ្នំពេញឯណោះទេ។

[១០:០២:១៥]

**លោក អេនគ្រូ អ៊ីទួហ្ស៊ី៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំមិនបានសុំឲ្យសាក្សីស្មាននោះទេ គឺគ្រាន់តែឲ្យគាត់លើកឡើងដោយផ្ទាល់តែប៉ុណ្ណោះ។ ខ្ញុំគ្រាន់តែចង់លើកឡើងថា ស្ទើរតែសាក្សីទាំងអស់បានមកផ្តល់សក្ខីកម្មនៅទីនេះ គឺក្នុងកម្រិតណាក៏ដោយ គឺពួកគេបានផ្តល់ចម្លើយជាពាក្យចចាមអារ៉ាម គឺមិនមែនអ្វីដែលគាត់ឮ

គាត់ស្តាប់ដោយខ្លួនឯងនោះទេ គឺគាត់មកផ្តល់សក្ខីកម្មថា ស្តាប់ឮពីគេ គេជាអ្នកឃើញ។ ដូច្នេះ ខ្ញុំសូមឆ្លើយតបថា ភស្តុតាងដែលជាពាក្យចចាមអារ៉ាមនោះ គឺអាចទទួលយកបាន ហើយមានសារៈសំខាន់។ ហើយចំណុចទី២ សាក្សីបានបញ្ជាក់ហើយថា គាត់បានប្រាប់ទៅតាមអ្វីដែលគាត់ឆ្លងកាត់ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់នៅក្នុងពេលនេះ នៅពេលនោះ។ ហើយគាត់ក៏មានដឹងឮផងដែរ បញ្ហាមួយចំនួនផងដែរនៅក្នុងពេល តាសារុន នោះគ្រប់គ្រង។ ដូច្នេះ ខ្ញុំអាចធ្វើការបំបែកសំណួរនេះដោយដាច់ចេញពីគ្នា កុំឲ្យវាសួរច្របូកច្របល់គ្នាដូច្នេះ។

[១០:០៣:១៨]

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** លោកសាក្សី លោកបានជម្រាបយើងខ្ញុំអំពីឪពុករបស់លោក ហើយឪពុករបស់លោកនោះគឺថាជឿជាក់ទៅលើសីលធម៌ទាំង១២ប្រការ ក៏ប៉ុន្តែគឺថាមិនអាចអនុវត្តទៅបាននោះទេ។ លោកក៏បានជម្រាបយើងខ្ញុំផងដែរ អំពីភាពខុសគ្នាមួយចំនួននៅក្នុងរបៀបដឹកនាំរបស់ឪពុក របស់លោក និងការដឹកនាំរបស់ តាសារុន។ ដូច្នេះសំណួររបស់ខ្ញុំនោះ សួរដោយសាមញ្ញតែប៉ុណ្ណោះ។ តើលោកប្រៀបធៀបការដឹកនាំរបស់ តាសារុន និងការដឹកនាំរបស់ឪពុករបស់លោកនោះ វាមានភាពខុសគ្នាយ៉ាងម៉េចដែរ?

**លោក ផាន វ៉ាន៖**

**ឆ៖** ខ្ញុំមិនអាចប្រៀបធៀបបានទេ ព្រោះកាលខ្ញុំនៅៗស្រុក ឯក្រោយមកខ្ញុំអត់បាននៅទេ គ្រាន់ទៅប្រៀបធៀបម៉េចបាន បើខ្ញុំនៅឯមកនៅក្រោមហើយ អារឿងបាត់អ្នកនេះបាត់អ្នកនោះហ្នឹង ខ្ញុំសួរក្រោយពេលដែលរត់ចូលព្រៃហើយនេះទេ ក្រោយពី៧៩ទៅនេះ។ ខ្ញុំសួរថា អ្នកណានៅណា ហើយអ្នកណានៅណាអីចឹងទៅ សួរអ្នកស្គាល់អីគ្នាអីចឹងទៅ។ បាត់គ្នីគ្នាអស់ ហើយក្រោយរំដោះនេះទៀត ខ្ញុំក៏ទៅស្រុក ទៅភូមិហ្នឹងក៏ឃើញបាត់អីចឹង ជាក់ស្តែងហ្នឹងឃើញបាត់អីចឹងមែន។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនលោកប៉ុណ្ណឹងបាទ។ ហើយការប្រៀបធៀបហ្នឹង វាប្រៀបធៀបអត់បានទេ ព្រោះមិនបាននៅហ្នឹង វាមិនបានឃើញជាក់ស្តែង។

[១០:០៤:៤៧]

**ស៖** សូមអរគុណច្រើនលោកសាក្សី ខ្ញុំនឹងផ្តោតលើប្រធានបទនេះឲ្យបានបន្ថែមទៀត។ លោកប្រហែលជាដឹង ឬក៏ប្រហែលជាមិនដឹងថា តាសារុន មកផ្តល់សក្ខីកម្មនៅទីនេះរួចហើយ។ ហើយគាត់អង្គុយនៅកន្លែងដែលលោកអង្គុយនេះផងដែរ។ គាត់មកផ្តល់សក្ខីកម្ម ឆ្លើយតបសំណួរចំនួនមកកាន់អង្គ

ជំនុំជម្រះ និងភាគីទាំងអស់ ហើយ តាសារុន ត្រូវបានលើកចម្លើយរបស់លោកដែលឆ្លើយនៅក្នុងកំណត់ហេតុចៅក្រមស៊ើបអង្កេតនោះ យកមកធ្វើការតទល់ផងដែរនៅទីនេះ ហើយគាត់បានតវ៉ាទៅលើចំណុចមួយចំនួនដូចដែលលោកបានបញ្ជាក់កាលពីព្រឹកមិញ។ នៅក្នុងអំឡុងឪពុករបស់ -- "អំឡុងពេលឪពុករបស់ខ្ញុំកាន់កាប់នោះ គឺមិនមានការកាប់សម្លាប់ទេ តែអំឡុងពេល តាសារុន នោះ គឺមានការកាប់សម្លាប់ហើយគ្រួសារមានការបាត់ខ្លួន"។ សំណួរទាំងអស់នេះ ក៏បានសួរទៅកាន់តាសារុន ផងដែរ។ ហើយគាត់ តាសារុន នេះបានច្រានចោលការឆ្លើយចម្លើយរបស់លោក ហើយគាត់បានឆ្លើយថា "គ្មានគ្រួសារទាំងអស់ ត្រូវបានគេចាប់ខ្លួននោះទេ។ អ្នកដែលនិយាយដូច្នេះគឺពន្លើសតែប៉ុណ្ណោះ" គឺគាត់និយាយនេះសំដៅទៅលើលោក គឺគ្មានការចាប់ខ្លួនអ្នកភូមិយកទៅសម្លាប់ចោលនោះទេ ក្នុងអំឡុងពេលគាត់កាន់កាប់។

[១០:០៦:១៥]

តាសារុន នេះបានច្រានចោលចម្លើយរបស់លោក ហើយសំណួររបស់ខ្ញុំចង់សួរទៅកាន់លោកនោះ គឺថាចម្លើយដែលលោកឆ្លើយទៅកាន់ចៅក្រមស៊ើបអង្កេតនោះ គឺលោកឆ្លើយពន្លើសតែប៉ុណ្ណោះដែលថានៅក្នុងអំឡុងពេល តាសារុន កាន់កាប់នោះ គឺអ្នកភូមិត្រូវបានគេចាប់ខ្លួនទាំងអស់។ ដូច្នេះសូមឲ្យលោកបញ្ជាក់ថា តើចម្លើយដែលលោកឆ្លើយនៅព្រឹកនេះត្រឹមត្រូវដែរឬទេ ហើយលោកមានឆ្លើយពន្លើសនៅក្នុងផ្តល់ចម្លើយទៅកាន់ចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បញ្ហាហ្នឹងបន្តិច បញ្ហា អ៊ំសារុន គាត់ឡើងសវនាការ ខ្ញុំអត់បានតាមដានទេ អត់បានដឹងថាគាត់មកសវនាការនៅតុលាការទេ។ តែគ្រាន់តែខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់មានពន្លើសទេ ពីព្រោះអ្នកដែលបាត់ខ្លួនហ្នឹង មិនដឹងគាត់យកទៅសម្លាប់ ឬក៏ពីណាបញ្ជាគាត់ ខ្ញុំអត់ដឹងទេ ប៉ុន្តែវាបាត់មែន ដូចខ្ញុំឧទាហរណ៍ ដូចជាឈ្មោះ ពូធិន១ ប្រធានមន្ទីរ១០៥ ដែលជាអ្នកស្និទ្ធជាមួយឪពុកនៅហ្នឹង ក៏បាត់ខ្លួនដែរ ទាំងគ្រួសារ។ មិនមែនត្រឹមតែគាត់ម្នាក់ឯងទេ ហើយ ពូកាឡយ១ ហ្នឹង គឺមនុស្សដែលថាត្រង់មែនទែន គឺមនុស្សជនជាតិ ១ភាគតិច។

[១០:០៧:៣០]

ហើយក្រៅពីហ្នឹងទៀត មានអ្នកខាងក្រោម១ហ្នឹងច្រើនទៀត។ ខ្ញុំចាំឈ្មោះមិនអស់ ប៉ុន្តែមេ១ពីរនាក់ដែលជានីរសារផ្ទាល់របស់ឪពុកខ្ញុំ គឺបាត់ខ្លួន។ នេះខ្ញុំសូមបញ្ជាក់ជូនលោកអ៊ីចឹង។ អត់មានថាខ្ញុំចេះតែចោទគាត់ទេ។ ហ្នឹងបានខ្ញុំជួបគាត់ក្រៅផ្លូវ នៅស្រុក នៅនឹងភូមិហ្នឹង ខ្ញុំក៏ទៅសួរគាត់ដែរដែលសមាហរណកម្មហើយហ្នឹង ខ្ញុំថា "រឿងស្អីបានទៅចាប់ ពូកាឡយ?"។ អាហ្នឹងខ្ញុំសូមបញ្ជាក់ជូន

តុលាការអ៊ីចឹង។ ខ្ញុំមិនមែនចេះតែចោទទេ។ ខ្ញុំសួរមនុស្សបាត់ហ្នឹងតែម្តង។ នេះសូមបញ្ជាក់អ៊ីចឹងបាទ។

**ស៖** សូមអរគុណ ដែលលោកបានឆ្លើយចំណុចនេះ។ តើលោកបានដឹងផ្ទាល់ដែរឬទេ ហេតុអ្វីបានជា សៅ សារុន នេះបានច្រានចោលចម្លើយរបស់លោកដែលបានឆ្លើយ? គឺការដែលគាត់ច្រានដូច្នេះគឺដើម្បីកុំឱ្យនេះ កុំឱ្យគាត់ហ្នឹងទទួលខុសត្រូវធ្ងន់ពេក ឬក៏យ៉ាងម៉េច? លោកសាក្សីកុំអាលទាន់ឆ្លើយសិនដូចជាមានការជំទាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សំណួរនេះនាំឱ្យសាក្សីធ្វើការសន្និដ្ឋាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះតំណាងសហព្រះរាជអាជ្ញា!

[១០:០៩:០៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ ខ្ញុំគិតដូចដើមបណ្តឹងរដ្ឋប្បវេណីដែរ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែរ គឺថា ហើយអង្គជំនុំជម្រះបានជម្រាបជូនហើយ ថាកុំឱ្យចោទសំណួរឱ្យសាក្សីស្មាន។ អ៊ីចឹង ហើយតាំងខ្លួនជាអ្នកដទៃ ហើយបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនជំនួសអ្នកដទៃនោះ ហើយអ៊ីចឹង ខ្ញុំមានគំនិតដូច។

**លោក អេនគ្រូ អ៊ុំនួហ្ស៊ី៖**

ខ្ញុំសូមឆ្លើយតប។ ខ្ញុំទទួលទាំងស្រុងដែលថា យើងមិនអាចសួរឱ្យសាក្សីស្មាន ឬក៏ធ្វើការសន្មតនោះទេ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមជំទាស់ចំពោះការលើកឡើងថា សាក្សីនោះមិនអាចដឹងចំណុចមួយចំនួន ដោយសារតែគាត់ -- អត់មាននរណាប្រាប់គាត់។

ខ្ញុំដឹងហើយថា ខ្ញុំដឹងបញ្ហាមួយចំនួន ដោយសារគេប្រាប់ខ្ញុំ។ ហើយទោះបីជាខ្ញុំមិនឃើញដោយផ្ទាល់ភ្នែកតាមវិញ្ញាណរបស់ខ្ញុំដោយផ្ទាល់ក៏ដោយ គឺខ្ញុំក៏អាចដឹងដែរ ។ ដូច្នេះបទពិសោធន៍របស់យើងក៏អាចដឹងតាមរយៈការប្រាស្រ័យទាក់ទងគ្នាជាមួយនឹងបុគ្គលមួយចំនួន។ ដូច្នេះ ក្នុងករណីនេះសាក្សីរូប

នេះគឺទំនងប្រហែលជាអាចដឹងដោយផ្ទាល់ ដឹងព័ត៌មានដោយផ្ទាល់ផងដែរ។ ដូច្នេះហើយសាក្សីនេះក៏មានលទ្ធភាព ហើយគាត់មានភាពឆ្លាតវៃអាចដឹងទៅលើចំណុចនេះផងដែរ។ ដូច្នេះគួរតែអនុញ្ញាតឲ្យខ្ញុំសួរសំណួរទាំងអស់នេះ។ ខ្ញុំជឿថាខាងមេធាវីការពារក្ដីផ្សេងទៀតនោះ ចង់លើកឡើងយោបល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ខ្ញុំរង់ចាំឲ្យចប់សិនទៅ ពីព្រោះវាហាក់ដូចជាបង្កើតនូវស្ថានភាពច្របូកច្របល់មួយ។

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[១០:១០:៥៤]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្ដីលោក លោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីជាទីគោរព! សំណួរដែលបានសួរនោះ គឺមិនត្រឹមតែពាក់ព័ន្ធប៉ុណ្ណោះទេ វាសមស្របផងដែរ។ នៅពេលដែលយើងមើលទៅលើសំណួរដែលបានសួរ ហើយនិងការរៀបចំសំណួរនេះ គឺគ្មានខុសពីអ្វីដែលសំណួរដែលចៅក្រម ឡាវ៉ែន៍ សួរនោះទេ។ ដូច្នេះយើងមិនសួរឲ្យសាក្សីនេះស្មាននោះទេ អ្វីដែលយើងសួរឲ្យសាក្សីឆ្លើយនោះគឺថាឲ្យគាត់ប្រៀបធៀបតាមការសង្កេតរបស់គាត់ និងបទពិសោធន៍របស់គាត់ដែលធ្លាប់ឆ្លងកាត់។ ហើយប្រសិនបើអង្គជំនុំជម្រះកំណត់សម្រេចទៅលើតម្លៃនៃភស្តុតាងនេះប៉ុនណានោះ គឺវាអាស្រ័យទៅលើអង្គជំនុំជម្រះ។ ដូច្នេះហើយគឺសាក្សីបានឃើញហេតុការណ៍ពីមុន និងក្រោយមកដែលបុគ្គលមួយចំនួនមានការកាន់កាប់ទៅលើតួនាទីជាក់លាក់។ ដូច្នេះហើយក្រោយការសង្កេតរបស់គាត់នោះគឺគាត់អាចទាញការសន្និដ្ឋានបាន។ ដូច្នេះហើយនេះគឺជាអ្វីដែលយើងសួរតែប៉ុណ្ណោះ។ យើងធ្លាប់សួរអ៊ីចឹងរួចមកហើយ។ ហើយយើងដឹងហើយថា យើងគ្មានសូចនករណ៍ចង្អុលបញ្ជាក់អ្វីដែលសាក្សីនេះប្រាប់នោះទេ ក៏ប៉ុន្តែសំណួរដែលបានសួរមកទល់ពេលនេះ គឺមិនមានការសួរឲ្យស្មាននោះទេ គឺគ្រាន់តែឲ្យសាក្សីនេះធ្វើការប្រៀបធៀបតាមការសង្កេតរបស់គាត់តែប៉ុណ្ណោះ។

ដូច្នេះរបៀបសួរសំណួរនេះគឺមានភាពពាក់ព័ន្ធ ហើយជាពិសេសគឺដោយសារតែនៅពេលនេះសាក្សីនេះកំពុងតែតទល់ទៅនឹងចម្លើយរបស់សាក្សីមួយទៀតដែលបានឆ្លើយ ហើយគ្រាន់តែឲ្យសួរធ្វើការប្រៀបធៀបតែប៉ុណ្ណោះ។

[១០:១២:២៦]

ក្នុងនាមជាមេធាវីការពារក្ដីនោះគឺថា យើងគួរតែមានសិទ្ធិសួរឲ្យប្រៀបធៀបដូច្នេះ។ ហើយយើងដឹងហើយថា ចៅក្រមនោះក៏គាត់បានសួរសំណួរប្រភេទហ្នឹងរួចមកហើយ។ ដូច្នេះយើងជាមេធាវីការពារក្ដីក៏មានអាចមានសិទ្ធិសួរសំណួរទម្រង់បែបនេះផងដែរ។ សូមអរគុណ។

[១០:១២:៤៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៤:៤១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំសំណួរចុងក្រោយនេះសាជាថ្មីម្ដងទៀត ហើយសូមរំឭកថា សំណួរសូមជៀសវាងធ្វើយ៉ាងណាកុំឲ្យសាក្សីផ្ដល់ចម្លើយជាសេចក្ដីសន្និដ្ឋាន។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំនឹងគោរពតាមលោកប្រធាន។ សូមអរគុណច្រើន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី ដើម្បីយើងជជែកគ្នានូវអ្វីដែលបានលើកឡើង ខ្ញុំសូមជម្រាបលោកជាថ្មីថា សៅ សារុន បានមកអង្គជំនុំជម្រះនេះដើម្បីផ្ដល់សក្ខីកម្មរួចហើយ ហើយគាត់បានច្រានចោលបដិសេធមិនទទួលស្គាល់នូវអ្វីដែលលោកបានឆ្លើយ ហើយបញ្ជាក់ជូនយើងខ្ញុំនៅថ្ងៃនេះនោះទេ។ ដូច្នេះសំណួរដែលខ្ញុំសួរសាមញ្ញទៅកាន់លោកនោះគឺថា តើលោកបានដឹងដោយផ្ទាល់ដែរឬទេ ហេតុអ្វីបានជា សៅ សារុន ច្រានចោល បដិសេធចម្លើយរបស់គាត់? តើលោកដឹងដោយផ្ទាល់អាចបញ្ជាក់បានដែរឬទេ ថាអ្វីដែលគាត់ឆ្លើយដូច្នោះបដិសេធចោល ដើម្បីបន្ថយការទទួលខុសត្រូវរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះតែប៉ុណ្ណោះ? ប្រសិនបើលោកមិនដឹងដោយផ្ទាល់នោះទេ លោកគ្រាន់តែឆ្លើយបញ្ជាក់មកបានហើយ គឺខ្ញុំមិនចង់ឲ្យលោកឆ្លើយនូវអ្វីដែលលោកមិនដឹងនោះទេ។

**ឆ៖** ខ្ញុំមិនដឹងទេ។ មិនដឹងគាត់បញ្ជាក់រឿងអីទេ។ គាត់មិនទទួលរឿងស្អីបាទ។

**ស៖** សូមអរគុណច្រើន។ លោកសាក្សី ខ្ញុំនៅមានសំណួរមួយទៀតទាក់ទងនឹង សៅ សារុន ខ្ញុំចង់សួរលោក។ សល់តែមួយសំណួរទៀតប៉ុណ្ណោះទាក់ទងនឹងប្រធានបទនេះ។ ដើម្បីឲ្យលោកនឹកឃើញឡើងវិញ ខ្ញុំបានអានអត្ថបទចំនួនបី ទៅកាន់លោកដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកបានជជែកជាមួយខ្ញុំអំពីអត្ថបទនេះផងដែរ។ អត្ថបទនៅទាំងបីនេះ គឺខ្ញុំសូមលើក

ឡើងថា លោកឯកភាពទាំងស្រុង ឬក៏មួយផ្នែក? ក៏ប៉ុន្តែខ្ញុំនិយាយជាទូទៅថាលោកឯកភាពជាមួយអ្វីសរសេរនៅក្នុងបីអត្ថបទហ្នឹង។ ហើយអត្ថបទទាំងបីនេះក៏បានយកទៅសួរលោក សៅ សារុន ផងដែរ។ លោក សៅ សារុន នោះគឺថាបដិសេធដាច់អហង្ការតែម្តង។ ហើយគាត់បានឆ្លើយថា បញ្ហាដែលលើកឡើងក្នុងអត្ថបទទាំងបីនោះមិនត្រឹមត្រូវនោះទេ។ អ្នកដែលនិយាយដូច្នេះគឺបំផ្លើសតែប៉ុណ្ណោះ។ "ខ្ញុំមិនទទួលស្គាល់ការគ្រប់គ្រងរបស់ខ្ញុំកាប់សម្លាប់មនុស្សនោះទេ។ ខ្ញុំ នៅពេលដែលខ្ញុំកាន់កាប់នោះ ខ្ញុំមិនមានអំណាចអ្វីចាប់មនុស្សនោះទេ។ ហើយខ្ញុំបដិសេធចោលការលើកឡើងដូច្នេះដោយសារជាការចោទប្រកាន់មកលើខ្ញុំមិនត្រឹមត្រូវ"។ ដូច្នេះខ្ញុំសូមសួរលោក តើលោកដឹងដោយផ្ទាល់ដែរឬទេ ហេតុអ្វី បានជាលោក សៅ សារុន មកតុលាការនេះផ្តល់ចម្លើយ ក៏ប៉ុន្តែគាត់ច្រានចោលបដិសេធចំណុចទាំងបី អត្ថបទទាំងបីនោះ ច្រានចោលការទទួលខុសត្រូវរបស់គាត់? តើលោកដឹងដែរឬទេ? ប្រសិនមិនដឹងក៏មិនអីដែរ? តើលោកដឹងដែរឬទេ គាត់ធ្វើអ៊ីចឹងដើម្បីព្យាយាមបន្ថយការទទួលខុសត្រូវរបស់គាត់នៅក្នុងតុលាការនេះតែប៉ុណ្ណោះ?

[១០:១៨:២៨]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ។ ប្រភេទសំណួរនេះ ជាសំណួរនាំឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋាន។

យើងរំលឹកហើយប្រុងប្រយ័ត្ននូវសំណួរដែលសួរនាំឲ្យសាក្សីផ្តល់នូវគំនិតអត្តនោម័តិ ការយល់ឃើញរបស់គាត់ ព្រោះគាត់មិនមែនជាអ្នកជំនាញទេ។

**លោក អេនត្រូ អ៊ីន្នូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តទៅមុខទៀត ក៏ប៉ុន្តែខ្ញុំសូមលើកឡើងប្រតិចារឹកថា វាគឺជាសំណួរសមស្របមួយ គឺការសួរដើម្បីស្វែងរកព័ត៌មាន--

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តទៀតណា៎។ សំណួរនាំឲ្យសាក្សីផ្តល់ចម្លើយជាសេចក្តីសន្និដ្ឋានជាការយល់ដឹងអត្តនោម័តិរបស់ខ្លួន យើងបានសម្រេចរួចហើយ។

**លោក អេនត្រូ អ៊ីន្នូហ្វ៊ី៖**

ខ្ញុំសូមបញ្ជាក់ថា ការមិនឲ្យសាក្សីធ្វើការសន្និដ្ឋាន ឬក៏យ៉ាងម៉េច? ឬក៏មិនឲ្យទាយស្មាន? ដូច្នេះ--

**ប្រធានអង្គជំនុំ៖**

មិនឲ្យសាក្សីទាយស្មាន មិនឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋានទេ។ ការអនុវត្តនេះ យើងអនុវត្តតាំងពីដើមឆ្នាំរហូតដល់ចុងឆ្នាំនេះ ជាង១ឆ្នាំកន្លងមកហើយ។ សំណួរដែលឲ្យធ្វើសន្និដ្ឋានបាន លុះត្រាតែជាអ្នកជំនាញ ពាក់ព័ន្ធនឹងភាពជំនាញរបស់គាត់។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:២០:៤៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ដើម្បីជាប្រតិចារឹក ដើម្បីកុំឲ្យមានបញ្ហាយល់គ្នាទៀតនោះ គឺថាមានការបកប្រែជាភាសាបារាំងអំមិញនោះ គឺការទាញសន្និដ្ឋាន ហើយដល់តែចេញទៅ -- ការបកប្រែជាភាសាបារាំងនេះ បកចេញពីអង់គ្លេសទេ។ អ៊ីចឹងមិនមែនជាការសន្និដ្ឋានដោយផ្ទាល់ខ្លួនទេ គឺតាមពិតទៅ គឺហៅថាការចោទសំណួរតាមឧបមានវិធី អ្វីដែលបកចេញទៅអំមិញនេះ។

**លោក អេនឌ្រូ អ៊ីនូហ្សី៖**

ខ្ញុំគិតថាបញ្ហាជាច្រើននៅទីនេះ ពាក់ព័ន្ធនឹងការបកប្រែ។ សំណួររបស់ខ្ញុំនេះមិនមែនសំណួរឧបមានវិធីឲ្យទាយស្មាននោះទេ។ ខ្ញុំគ្រាន់តែសួរទៅកាន់សាក្សី ថាតើសាក្សីបានដឹងដែរឬទេ ថាមានករណីមួយចំនួនបានកើតឡើង ហើយតើសាក្សីនេះបានដឹងដោយផ្ទាល់ដែរឬទេ ថាលោក សៅ សារុន នេះបានច្រានចោល និងបន្ថយការទទួលខុសត្រូវរបស់គាត់នៅក្នុងតុលាការនេះ។ ដូច្នេះខ្ញុំគ្រាន់តែចង់សួរទៅកាន់សាក្សីថាតើសាក្សីនេះបានដឹងដោយផ្ទាល់ថាហេតុអ្វីបានជាគាត់ច្រានចោលចំណុចហ្នឹង។ ដូច្នេះសាក្សីបានឆ្លើយហើយ គឺថាគាត់អត់ដឹង។ ដូច្នេះ ខ្ញុំមិនអាចសួរបន្តទៅទៀតទេ ដោយសារសាក្សីមិនដឹងរួចទៅហើយ។ ដោយសារតែបានលើកឡើងអំពីការសន្និដ្ឋាន មិនអាចធ្វើទៅបាន មានតែអ្នកជំនាញនោះអាចសន្និដ្ឋានទៅបាននោះ គឺខ្ញុំគិតថា--

[១០:២២:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តទៀត យើងផ្ដល់ឱកាសឲ្យលោកតាំងសំណួរដេញដោលចំពោះសាក្សី។ យើងដូចមិនឲ្យលោកបង្រៀនយើងទេ។

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

ខ្ញុំមិនប៉ានបង្រៀនលោកប្រធានទេ លោកប្រធាន។ ខ្ញុំសូមបន្តទៅមុខទៀត សួរសំណួរបន្ទាប់របស់ខ្ញុំ។

**សួរដោយលោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

**ស៖** សំណួរទាំងអស់នេះលោកសាក្សី គឺពាក់ព័ន្ធទៅនឹងក-១៧។ ដូច្នេះ ខ្ញុំសូមសួរលោកនូវសំណួរមួយចំនួន ហើយសំណួរនេះគឺមិនច្រើននោះទេ ហើយខ្ញុំអាចបញ្ចប់មុនពេលសម្រាក។ កាលពីម្សិលមិញ និងម្សិលម្ង៉ៃ លោកបានឆ្លើយសំណួររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការ -- ប្រព័ន្ធទំនាក់ទំនងរវាងមន្ទីរក-១៧ ជាមួយនឹងលោក នួន ជា។ ហើយបញ្ហាដែលលើកឡើងនោះ គឺថាលើបញ្ហាសន្តិសុខ និងការប្រជុំនៅទីក្រុងភ្នំពេញ។ ពាក់ព័ន្ធទៅនឹងចំណុចទី២ គឺការអញ្ជើញមកប្រជុំនោះ គឺថាលោកបានលើកឡើងអំពីការអញ្ជើញទៅប្រជុំមួយចំនួនដែលគេបានអញ្ជើញមុនពេលឪពុករបស់លោកស្លាប់។

[១០:២៣:៥០]

ដូច្នេះ ពាក់ព័ន្ធទៅនឹងការពិភាក្សារបស់លោកកាលពីម្សិលមិញជាមួយនឹងចៅក្រម ឡាវែន៍ ជាចៅក្រមបារាំង។ លោកប្រាកដជាយល់ហើយថា អ្វីដែលខ្ញុំចង់លើកឡើងនោះ គឺថាអ្វីដែលសួរកាលពីម្សិលមិញនោះ គឺមិនពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងចំពោះឪពុករបស់លោកនៅក្នុងទីក្រុងភ្នំពេញនោះទេ។ ក៏ប៉ុន្តែដោយសារតែក្រុមប្រឹក្សាជំនុំជម្រះនោះ ចាប់អារម្មណ៍សួរសំណួរទាំងអស់នេះ ដូច្នេះខ្ញុំសូមសួរលោកសំណួរមួយពីរពាក់ព័ន្ធទៅនឹងចំណុចហ្នឹង។

**ប្រធានអង្គជំនុំ៖**

លោក១១តាំងសំណួរជាក់លាក់ទៅ លោកមិនធ្វើអត្ថាធិប្បាយយ៉ាងវែង ពន្យល់សាក្សីរួចទើបសួរទេ។ លោកចង់ដឹងអង្គហេតុអី លោកសួរទៅ។ លោកមិនសំណួរប្រភេទបន្ថំ ដើម្បីទៅជាប្រភេទសំណួរនាំមុខទេ។ លោកសួរអង្គហេតុអី ចង់ដឹងអង្គហេតុអី សួរជាក់លាក់ទៅ។ ហើយគួរតែសម្រួមកាត់សំណួរឲ្យខ្លី១ទៅ ជៀសវាងស្តាប់ទៅមិនយល់សំណួរ ហើយឆ្លើយហ្នឹងមិនចំសំណួរ អាចសួរឡើងវិញច្រំដែល១ ខាតពេលវេលា។ ទី២ វាអាចឆ្លើយតបទៅមិនត្រឹមត្រូវទេ ប្រសិនបើស្តាប់សំណួរមិនយល់។ យើងជឿថាសំណួរវែងគឺមិនអាចយល់បានទេ។

[១០:២៤:១២]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់និយាយថា នៅពេលនេះគឺគ្រាន់តែបង្ហាញអំពីបរិបទឲ្យសាក្សី ឲ្យភាគីបានយល់មុនពេលដែលយើងធ្វើការសួរសំណួរ។

**ប្រធានអង្គជំនុំ៖**

លោក លោកតាំងសំណួរ! យើងដូចមិនផ្តល់វេទិកាឲ្យលោកធ្វើអត្ថាធិប្បាយអីទេ។ យើងបានប្រាប់តាំងពីដើមទីឲ្យលោកផ្តល់វេទិកាឲ្យលោកមានឱកាសក្នុងការសួរដេញដោលសាក្សី។

[១០:២៥:៥០]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំនឹងគោរពតាមភ្លាម លោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី លោកបានជជែកពិភាក្សាជាមួយនឹង អំពីការស្លាប់ឪពុករបស់លោកជាមួយចៅក្រម ឡាវ៉ែន៍ ហើយចៅក្រម ឡាវ៉ែន៍ សួរថា តើឪពុករបស់លោកស្លាប់នៅពេលណា? ហើយលោកបានឆ្លើយថា មិនដឹងកាលបរិច្ឆេទ ថ្ងៃខែច្បាស់លាស់នោះទេ។ ដូច្នេះខ្ញុំសូមសួរលោក ហើយលើកឡើងនូវអ្វីដែលលោកបានឆ្លើយ។ គឺប្រតិចារឹកកំណត់ហេតុស្តាប់ចម្លើយដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេត ការិយាល័យចៅក្រមស៊ើបអង្កេត។ កំណត់ហេតុនេះគឺលេខ E3/57។ ខ្ញុំគិតថាវាជាកំណត់ហេតុមួយដែលខ្ញុំបានលើកឡើងម្តងរួចមកហើយ។ ដូច្នេះហើយ ខ្ញុំមិនចាំបាច់អាន ERN ឡើងវិញនោះទេ។ សូមមើលទំព័រ៦ គេបានសួរលោកនូវសំណួរនេះថា "តើលោកមកភ្នំពេញនៅក្នុងឆ្នាំណាដែរជាមួយនឹងឪពុករបស់លោក?"។ លោកបានឆ្លើយថា "នៅចុងឆ្នាំ១៩៧៧"។ លោកឆ្លើយប្រាប់ចៅក្រម ឡាវ៉ែន៍ដូច្នេះផងដែរ។ តើលោកនឹក -- ធ្វើឲ្យលោកនឹកឃើញដែរឬទេ? តើនៅពេលណាដែលលោកធ្វើដំណើរចុងក្រោយជាមួយឪពុករបស់លោកមកទីក្រុងភ្នំពេញ តើនៅចុងឆ្នាំ៧៧ ឬក៏យ៉ាងម៉េច? តើវាដូចទៅនឹងអ្វីដែលលោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេតដែរឬទេ ថាមកនៅក្នុងចុងឆ្នាំ៧៧នោះ?

[១០:២៧:៤០]

**លោក ផាន វ៉ាន៖**

**ផ៖** បាទ ខ្ញុំបានបញ្ជាក់ហើយថា ខ្ញុំចាំអត់ច្បាស់ដែលគ្រាន់តែប្រហែលបាទ។

**ស៖** មិនអ្វីទេលោកសាក្សី បើលោកមិនចាំច្បាស់។ តើលោកនៅតែរក្សាចម្លើយនេះដែរឬទេ?

**ឆ៖** អាហ្នឹងអត់ប្រាកដទេ ប៉ុន្តែដូចខ្ញុំបានបញ្ជាក់អ៊ីចឹងថា ខ្ញុំរក្សាចម្លើយៗហ្នឹងបាទ។ អត់ប្រាកដ បើចង់ច្បាស់ ទាល់តែខ្ញុំ ដូចខ្ញុំបានបញ្ជាក់កាលពីម្សិលមិញអ៊ីចឹង។

[១០:២៨:២០]

**ស៖** សូមអរគុណ។ ប្រហែលជាយើងអាចធ្វើការបញ្ជាក់គ្នាទៅវិញទៅមក។ លោកបានជម្រាបថា លោក និងឪពុករបស់លោកបានធ្វើដំណើរមកទីក្រុងភ្នំពេញនេះច្រើនលើកផងដែរ ហើយលោកបានមកជាមួយគាត់។ តើត្រឹមត្រូវដែរឬទេ លោកមកទីក្រុងភ្នំពេញនេះជាមួយនឹងឪពុករបស់លោក ហើយពេលដែលគាត់ហ្នឹង គឺលោកមកអមជាមួយគាត់ច្រើនលើកច្រើនសាដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** អ៊ីចឹងហើយបាទ។

**ស៖** តើលោកនៅចាំដែរឬទេៗ លោកមកជាមួយឪពុករបស់លោកនោះពីរដង បីដង ប្រាំដងឬក៏១០ដង ឲ្យចំនួនប្រហែលមក? ឬប្រហែលៗមក តើប៉ុន្មានដង? តើលោកមកជាមួយនឹងឪពុកលោកមកទីក្រុងភ្នំពេញនេះ ប្រហែលជាប៉ុន្មានដងដែរ?

**ឆ៖** ចាំមិនបានទេ ប្រហែល អត់ដឹង។

[១០:២៩:៣២]

**ស៖** សូមអរគុណ។ តើច្រើនជាង១០ដង ក្រោម១០ដង តើលោកអាចបញ្ជាក់ដែរឬទេ?

**ឆ៖** អត់យល់សំណួររបស់លោក ចង់សួរថាក្នុងរយៈ១ឆ្នាំ ឬក៏១ខែ ឬក៏យ៉ាងណាបាទ?

**ស៖** ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំសួរមិនច្បាស់។ ខ្ញុំគ្រាន់តែធ្វើការសួរដើម្បីឲ្យលោកបញ្ជាក់ថាប្រហែលប៉ុន្មានដងដែលលោកមកទីក្រុងភ្នំពេញនេះ? តើជាសរុបមក លោកមកទីក្រុងភ្នំពេញជាមួយឪពុករបស់លោកនេះប្រហែលជាប៉ុន្មានដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? តើជាង១០ដង ឬក៏ក្រោម១០ដង?

**ឆ៖** ជំនាន់ហ្នឹងដូចអត់ដល់ ១០ទេបាទ។

**ស៖** សូមអរគុណ សូមអរគុណលោកច្រើន។ នៅពេលនេះខ្ញុំសូមសួរសំណួរទី២ ពាក់ព័ន្ធទៅនឹងការលើកឡើងចោទប្រកាន់អំពីការដែលលោកធ្វើដំណើរមកជាមួយនឹងឪពុករបស់លោកនៅទីក្រុងភ្នំពេញដែលលោកចៅក្រម ឡាវែន៍ បានសួរលោកទៅលើចំណុចនេះផងដែរ?

**ប្រធានអង្គជំនុំ៖**

មេធាវី អធ្យាស្រ័យដែលដល់ពេលសមល្មមសម្រាកហើយ ព្រោះប្រធានបទថ្មីផង ចាំពេលចូលវិញទៅ ចាំបន្តសំណួរដែលសួរ ព្រោះចូលប្រធានបទថ្មី។

បាទ ឥឡូវដល់ពេលវេលាសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ឈប់សម្រាកក្នុងពេលសម្រាកនេះ។ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៣៨]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិការជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាត សូមជម្រាបជូនថា ខ្ញុំមកដល់ចំណុចណាហើយនៅចំពោះសាក្សីនេះ ហើយខ្ញុំជឿថា ខ្ញុំបានប្រើពេលមួយចំនួន ហើយខ្ញុំត្រូវការ៣០នាទីទៀត សហ-

សេរិកខ្ញុំ សុន អរុណ ប្រហែលជាគាត់ ប្រហែលជាប្រើពេល៤០នាទី ហើយខ្ញុំសូមជម្រាបថាមេធាវីការពារយើងមានពេល១ថ្ងៃ ហើយយើងអាចនឹងមានការបត់បែនខ្លះទៅតាមក្រុមមេធាវីផ្សេងៗទៀត។ ហើយដើម្បីយើងនឹងប្រើពេលដែលអង្គជំនុំជម្រះចែកជូនដើម្បីនឹងសួរសំណួរនេះ។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្សិ៍៖**

**ស៖** លោកសាក្សីយើងត្រឡប់មកវិញ យើងនិយាយពីសំណួរដែលខ្ញុំបានចង់សួរមុនពេលសម្រាកនេះ។ លោកបានពិភាក្សានិយាយអំពីដំណើរចុងក្រោយដែលលោក-- ឪពុករបស់លោកទៅភ្នំពេញ -- បានពិភាក្សាជាមួយថៅក្រម ឡាវ៉ែន៍ ហើយខ្ញុំបានសួរសំណួរនេះផងដែរ ហើយខ្ញុំមានសំណួរមួយអំពីបញ្ហានេះ។ តើលោកដឹងដែរឬទេ តើឪពុករបស់លោកបានប្រាប់លោក ឬអ្នកណាបានប្រាប់លោកថាតើមានមូលហេតុអ្វីដែលត្រូវធ្វើដំណើរមកភ្នំពេញតើគោលបំណងអី? ហេតុអីបានត្រូវធ្វើដំណើរមកភ្នំពេញនេះ? តើមានការកោះហៅអ្វីខ្លះនៅក្នុងឱកាសនោះ ដើម្បីឲ្យគាត់អញ្ជើញមកនោះ?

**លោក ផាន វ៉ាន៖**

**ផ៖** ខ្ញុំអត់ដឹងទេបាទ ដឹងតែមកជាមួយគាត់តែប៉ុណ្ណឹង។ គាត់ថាខាងលើហៅមក មក។ តួនាទីខ្ញុំដឹងតែតាមគាត់តែប៉ុណ្ណឹងឯង គាត់ថាមកៗអ៊ីចឹងទៅបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់សួរលោកមួយចំនួនអំពីបញ្ហាដែលខ្ញុំនឹងលើកឡើង គឺថាយោងទៅរកកំណត់ហេតុសួរចម្លើយរបស់ អ្វ.ស៊ី.អាយ.ជេ គឺថាឯកសារ E3/58។ ខ្ញុំពិនិត្យមើលទំព័រទី៤ នៃឯកសារនោះជាភាសាអង់គ្លេស ហើយជា ERN នោះ គឺ 00250089, ខ្មែរ ERN គឺ 00239937, ERN បារាំង 00288915។ ឥឡូវនេះ នៅក្នុងឯកសារនេះ គឺមើលឃើញទៅ គឺភាគីទាំងអស់បានពិនិត្យឃើញថា យើងបានសួរដេញដោលរវាងរូបលោក ហើយនិងអ្នកស៊ើបអង្កេត ហើយមានអ្នករៀបចំកំណត់ហេតុនេះទាក់ទងទៅនឹងហេតុការណ៍ដែលយើងបានពិភាក្សានេះ។ ក៏ប៉ុន្តែមានចំណុចមួយចំនួន ដែលមិនបានកត់ត្រាចម្លើយដែលលោកបានឆ្លើយ។ ហើយយើងដឹងដោយសារតែយើងមានខ្សែអាត់ថតសំឡេងអំពីការសម្ភាសនេះ។ ជាអកុសលនោះ គឺលោកបានឃើញ គឺថានៅក្នុងដំណើរការជំនុំជម្រះនេះ គឺថាញឹកញាប់ណាស់កំណត់ ខ្សែៗអាត់សំឡេងនោះ គឺថាមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកំណត់ហេតុនេះទាំងស្រុងទេ។ និយាយដោយត្រង់គឺថាជា អាចជាបញ្ហាដ៏សំខាន់នៅក្នុងដំណើរការនេះ។

[១០:៥៧:១០]

ថៅក្រមដូចជាមិនមានការព្រួយបារម្ភទេ ហើយគឺមិនយកចិត្តទុកដាក់លើបញ្ហានេះខ្លាំងទេ។

ប៉ុន្តែសំខាន់ណាស់ដែលយើងចាប់អារម្មណ៍ជាមេធាវីការពារនោះ ដើម្បីមានលទ្ធភាពនឹងសួរតទល់ជាមួយលោក។ អ្វីដែលលោកបាននិយាយ ហើយមិនមែនជាអ្វីដែលថាពេលខ្លះមិនបានកត់ត្រានៅក្នុងកំណត់ហេតុនេះទេ។ ដូច្នេះតាមពិត ដែលត្រឡប់មកសំណួររបស់ខ្ញុំវិញ គឺលោកបានប្រាប់ទៅអ្នកអង្កេតថា ប្រហែលជាលោកនៅចាំ ថា “ឪពុករបស់លោក គេកោះមកឲ្យភ្នំពេញ មកភ្នំពេញនៅឱកាសនោះ ដើម្បីពិភាក្សាបញ្ហាមួយចំនួនអំពីស្ថានភាពនៅវៀតណាម”។ ហើយផ្នែកនោះគឺមិនបានកត់ត្រានៅក្នុងកំណត់ហេតុនេះទេ ប៉ុន្តែនៅក្នុងខ្សែអាត់មានឮសំឡេងរបស់លោក។ តើលោកនៅចាំទេ ថាលោកបានឆ្លើយបែបនោះ? ថាដំណើរមកភ្នំពេញរបស់ឪពុករបស់លោកនោះ គឺមកពិភាក្សាអំពីស្ថានភាព អំពីជម្លោះរវាងកម្ពុជា និងវៀតណាម? ហើយ -- លោកកុំទាន់ឆ្លើយ មានការជំទាស់ពីសហព្រះរាជអាជ្ញាបាទ។

[១០:៥៨:១៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទៅនឹងសំណួរដែលសួរទេ ក៏ប៉ុន្តែខ្ញុំជំទាស់ទៅនឹងការអត្ថាធិប្បាយបន្ទាប់ពីការសួរសំណួរនោះ ដែលធ្វើឲ្យជះឥទ្ធិពលទៅលើចម្លើយរបស់សាក្សី ដែលថាចម្លើយនៅក្នុងខ្សែអាត់នោះមិនដូចទៅនឹងចម្លើយរបស់លោកនោះ។ ដូច្នេះវាមិនសមស្របទេ ដែលយើងចាប់ផ្ដើមបញ្ចូលប្រធានបទដោយមានការអត្ថាធិប្បាយបន្ថែមពីលើសំណួរនោះ។ សូមឲ្យមេធាវីការពារក្ដីកុំធ្វើបែបនេះ។ ហើយដើម្បីឲ្យភាគីតាមទាន់នូវអ្វីដែលលើកឡើងនោះ មេធាវីការពារក្ដីគួរតែប្រាប់ឲ្យបានច្បាស់ថា សម្រង់នៃខ្សែអាត់មួយណា? ឯកសារមួយណា? ឯកសារលេខប៉ុន្មាន? ERN ក្នុងភាសាទាំងបីនោះយ៉ាងម៉េច ដើម្បីកុំឲ្យភាគីវង្វេងវង្វាន់មិនដឹងថានិយាយពីឯកសារណាមួយនោះ ហើយអាចភាគីអាចផ្ទៀងផ្ទាត់មើលផង ថាតើត្រឹមត្រូវដែរឬទេ ដែលមេធាវីការពារក្ដីលើកឡើងថា សម្ដីរបស់សាក្សីក្នុងខ្សែអាត់មិនមាននៅក្នុងកំណត់ហេតុនោះ។

[១០:៥៩:៣២]

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ ជាគោលបំណងនៃការសួរនេះ គឺថាការដែលយើងធ្វើ

សេចក្តីផ្តើមនេះ គឺថាយើងៗមិនប៉ុនប៉ងឲ្យមានអានុភាពទៅលើសាក្សីទេ។ ម្តងទៀត គឺថាយើងត្រូវយើងពិនិត្យមើលបញ្ហាកង្វះខាតនៅក្នុងការស៊ើបអង្កេត។ ដូច្នេះហើយបានយើងធ្វើសេចក្តីប្រារព្ធដំបូងដើម្បីនឹងសួរ។ ដូច្នេះប្រតិចារឹកដែលខ្ញុំបានមើលនោះគឺដែលរៀបចំឡើងដោយបុគ្គលិកនៅក្នុងក្រុមរបស់យើងខ្ញុំ បន្ទាប់ពីបានស្តាប់ខ្សែអាត់សំឡេង។ ខ្ញុំសួរសាក្សីម្តងទៀត លោកសាក្សី តើលោកនៅចាំដែរឬទេ? បើលោកចាំថាចាំ បើមិនចាំ ថាមិនចាំ ថាគោលបំណងនៃដំណើរចុងក្រោយរបស់ឪពុកលោកនោះ គឺនិយាយអំពីបញ្ហាជម្លោះនៅវៀតណាម ហើយខ្ញុំសូម -- សូមលោកកុំទាន់អាលឆ្លើយ គឺថាមានការជំទាស់ពីភាគីមួយផ្សេងទៀត ហើយ សូមលោកចាំសិន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១១:០០:៤៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំត្រូវការលេខនៃខ្សែអាត់ដែលមេធាវីការពារក្តីបានលើកឡើងនោះ។ ខ្ញុំសូមឲ្យមានលេខយោងច្បាស់លាស់។ ដូច្នេះសូមឲ្យមេធាវីការពារក្តីផ្តល់លេខយោង។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីផ្តល់លេខយោងឯកសារដែលលោកសំអាងនេះដល់អង្គជំនុំជម្រះ និងភាគី ទី១។ ទី២ លោកបន្តការតាំងសំណួរជាក់លាក់ ជៀសវាងការចំណាយពេលធ្វើអត្ថាធិប្បាយវែងអន្លាយអាចប៉ះពាល់ ឬមានឥទ្ធិពលទៅលើសាក្សី ដូចយើងបានជម្រាបជូនលោករួចហើយម្តងហើយ។ ហើយអំមិញនេះ គឺមានការកត់សម្គាល់ពីតំណាងសហព្រះរាជអាជ្ញាទៀត។ ការធ្វើដូច្នេះម្តងហើយ ម្តងទៀតនាំឲ្យបាត់បង់ពេលវេលា ការប្រើប្រាស់ពេលវេលាក្នុងការគ្រប់គ្រងដំណើរការប្រព្រឹត្តទៅឲ្យឆាប់រហ័សរបស់អង្គជំនុំជម្រះហ្នឹង គឺមិនមានប្រសិទ្ធភាព។

[១១:០១:៥៨]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបញ្ជាក់ដោយសង្ខេបទេ គឺការចង្អុលបង្ហាញឯកសារនោះ គឺ E3/58។ ដូចដែលយើងបានដឹងហើយនៅក្នុងខ្សែអាត់នៃឯកសារទាំងអស់នោះ គឺស្ថិតនៅក្នុង D125/160 ជាឯកសារ លេខឯកសារដើមរបស់ការិយាល័យសហចៅក្រមសស៊ើបអង្កេត 160R នេះគឺជា

លេខខ្សែអាត់បាទ។

ដើម្បីជម្រាបឱ្យច្បាស់ គឺថាខ្សែអាត់នោះ គឺថាដែលខ្ញុំបានអាននោះ គឺលេខ 160R។ ខ្ញុំចាប់អារម្មណ៍ណាស់ ខ្ញុំឱ្យសាក្សីរំឭកឡើងវិញបើតាមដែលអាចធ្វើបាន បើសិនជាគាត់ចាំៗ បើមិនចាំមិនអ្វីទេ។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សីខ្ញុំសួរលោកឡើងវិញ តើលោកចាំដែរឬទេថា បានប្រាប់អ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតថា គោលបំណងនៃការធ្វើដំណើរ និងមូលហេតុនៃការធ្វើដំណើរចុងក្រោយរបស់ឪពុកលោកនោះ គឺពិភាក្សាអំពីបញ្ហាជម្លោះរវាងកម្ពុជានិងវៀតណាម។ បើសិនជាលោកដឹងថា ដឹងបើមិនដឹងក៏មិនជាបញ្ហាដែរ?

[១១:០៣:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំមិនដឹងថា តើជាចេតនារបស់មេធាវីការពារក្តី ឬយ៉ាងម៉េចទេ។ គាត់ផ្តល់នូវលេខកំណត់ហេតុស្តាប់ចម្លើយហើយ គាត់ប្រាប់ថាមានភាពមិនស៊ីសង្វាក់គ្នារវាងចម្លើយ និងខ្សែអាត់។ ខ្ញុំចង់ឱ្យគាត់ផ្តល់នូវលេខយោងខ្សែអាត់ដើម្បីឱ្យគេ -- ឱ្យយើងអាចពិនិត្យមើលថា មានភាពមិនស៊ីសង្វាក់គ្នា ឬក៏អត់។ ខ្ញុំយល់ថា គាត់ដឹងហើយ ប៉ុន្តែគាត់នៅតែបន្តផ្តល់លេខយោងនៃកំណត់ហេតុដែលយើងដឹង ដែលយើងមានលេខទៅហើយនោះ។ មិនព្រមឱ្យលេខខ្សែអាត់ទេ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំសូមបន្ថែមថា អ្វីដែលខ្ញុំធ្វើឡើងនៅទីនេះ គឺដោយចេតនាតែប៉ុណ្ណោះ។ យោងនុំង គឺថាទំព័រទី៤ត្រង់ទំព័រទី៤ ខ្ញុំអានលេខ ERN ពាក់ព័ន្ធទៅនឹងសំណួរពាក់ព័ន្ធ ហើយយើងបានដឹងទាំងអស់គ្នាហើយសាធារណជនក៏បានដឹង។ ប្រហែលជាសាធារណជននិងអ្នកផ្សេងគាត់មិនបានដឹង។ សំណួរ និងចម្លើយនោះ គឺវាជាការច្របាច់ចូលគ្នាទៅនឹងសំណួរ-ចម្លើយដែលបានសួរច្រើន។ ដូច្នេះហើយមានចំណុចមួយចំនួនដែលមានចំណុចសង្ស័យលុបចោល ហើយយើងបានដឹងទៅលើចំណុចទាំងនេះ។ វាពិបាកណាស់ខ្ញុំត្រូវតែចំណាយពេល២០នាទី --

[១១:០៤:៥៥]

**ប្រធានអង្គជំនុំ៖**

ឈប់សិន!

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៦:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យមេធាវីការពារក្ដីយល់ -- មេធាវី នួន ជា យល់ច្បាស់នោះ គឺថានៅក្នុងតុលាការយើងនេះ យើងមិនត្រឹមតែឲ្យលេខកូដ មុនលេខ R ទេ យើងត្រូវតែផ្ដល់ម៉ោង នាទី វិនាទីនៃខ្សែអាត់ដែលមានការនិយាយបែបនេះនោះ។ មេធាវីការពារក្ដី នួន ជា គួរតែយកតាមគំរូរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលគាត់បានដកស្រង់ប្រតិចារឹកដោយផ្នែកនៃឯកសារខ្សែអាត់នោះ ដែលកាលពីពាក់ព័ន្ធទៅនឹងការស្ដាប់ចម្លើយ ខាំ ផាន់ នោះ។ ហើយក្នុងឯកសារនោះយើងមានការបកប្រែជាភាសាបារាំង ភាសាអង់គ្លេស ហើយយើងមានលេខកូដត្រឹមត្រូវ យើងអាចមានឃើញលេខទំព័រ ហើយយើងមានម៉ោង នាទី មានវិនាទី នៃខ្សែអាត់នោះ។

[១១:០៧:៣៥]

ទី២ លោកប្រធាន ខ្ញុំសូមកត់សម្គាល់ជាថ្មីម្ដងទៀតថា ក្នុងការលើកឡើងរបស់មេធាវី នួន ជា គាត់បន្តធ្វើការអត្ថាធិប្បាយទៅលើគុណភាពនៃកំណត់ហេតុ។ ហើយការធ្វើបែបនេះនោះ គឺថាត្រូវបានហាមឃាត់ដោយអង្គជំនុំជម្រះតាំងពីដើមមកហើយ។ ដូច្នេះសូមមេធាវីការពារក្ដី នួន ជា មេត្តាឈប់ធ្វើការអត្ថាធិប្បាយតទៅទៀត ដើម្បីកុំឲ្យជះឥទ្ធិពលទៅលើចម្លើយរបស់សាក្សី។

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណចំពោះចំណុចនេះ ខ្ញុំសូមឆ្លើយតបដោយខ្លី។ ទី១ គឺយើងឃើញថា អ្វីដែលកើតឡើងនៅទីនេះ គឺថាអ្វីដែលធ្វើនៅទីនេះ គឺវាមានលក្ខណៈសាមញ្ញនោះទេ។ យើងឃើញនីតិវិធីជាច្រើនមានភាពខុសៗគ្នាទៅតាមសាក្សី។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងបន្តទៅមុខ។ ខ្ញុំទទួលស្គាល់ថា ខាងមេធាវីការពារក្ដី ខៀវ សំផន នោះបានដាក់ប្រតិចារឹក ហើយមានកំណត់សម្គាល់យោងត្រឹមត្រូវ។ វាជាការ

អនុវត្តមួយសមស្រប ក៏ប៉ុន្តែនៅពេលដែលយើងតទល់នេះ ការផ្លាស់ប្តូរហ្នឹងវាកើតឡើងខ្លាំង -- ខុសគ្នាខ្លាំងណាស់។ ដូច្នេះហើយកាលពីយប់មិញ និងព្រឹកមិញនេះ គឺយើងខ្ញុំត្រៀមដើម្បីតទល់ទៅនឹងសាក្សីរូបនេះ ក្រោយពីយើងស្តាប់នូវសំណួរសួរពីចៅក្រម ឡាវែន៍ កាលពីម្សិលមិញ។

[១១:០៩:០៣]

ដូច្នេះហើយ យើងមិនអាចផលិត និងដាក់ជូនប្រតិចារឹកត្រង់ចំណុចជាក់លាក់នោះទេ។ ចំណុចនេះគឺថា វាមិនសមស្របនោះទេ។ ខ្ញុំមិនបានដឹងរហូតដល់កាលពីម្សិលមិញនេះ ពេលដែលចៅក្រមសួរហើយទើបខ្ញុំអាចដឹងថា តើត្រូវសួរសំណួរណា? ដូច្នេះហើយ សំណើរបស់ខ្ញុំហ្នឹង គ្រាន់តែស្នើសុំទៅអាយ.ធី.យូ ដើម្បីឱ្យធ្វើប្រតិចារឹកទៅលើខ្សែអាត់ត្រង់ចំណុចហ្នឹង។ នៅពេលនេះ ខ្ញុំគ្រាន់តែសួរទៅកាន់សាក្សី ហើយជម្រាបទៅកាន់សាក្សីក្នុងន័យល្អតែប៉ុណ្ណោះ ទៅតាមក្រុមការងាររបស់ខ្ញុំនៅក្នុងក្រុមនេះប្រាប់ខ្ញុំថា នៅក្នុងខ្សែអាត់នោះ គឺថាបានលើកឡើងអំពីបញ្ហាជម្លោះវៀតណាម ប៉ុន្តែបើសិនជាសាក្សីមិនដឹងទេ មិនបានឆ្លើយទេ មិនអ្វីនោះទេ។ ចំណុចនេះ គឺខ្ញុំធ្វើឡើងដើម្បីធ្វើការគ្រប់គ្រងទៅលើការដេញដោលសំណួររបស់ខ្ញុំ។ ហេតុដូច្នេះ គឺខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះឱ្យសាក្សីនោះឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ហើយខ្ញុំនឹងដាក់សំណើឱ្យសុំធ្វើប្រតិចារឹកទៅលើត្រង់ផ្នែកនៃខ្សែអាត់នេះ។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** លោកសាក្សី ជាថ្មីម្តងទៀត គឺកុំយកអ្វីដែលខ្ញុំនិយាយនេះឱ្យជះឥទ្ធិពលទៅដល់លោក ក៏ប៉ុន្តែតើលោកចាំដែរឬទេ បានប្រាប់អ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេតដែលថាការអញ្ជើញឱ្យមកប្រជុំចុងក្រោយនោះនៅក្នុងទីក្រុងភ្នំពេញ គឺដើម្បីមកពិភាក្សាទៅលើបញ្ហាជម្លោះជាមួយនឹងវៀតណាមនិងកម្ពុជា? តើអីចឹងដែរឬទេ លោកចាំទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់ចាំទេបាទ។

[១១:១០:៥០]

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំនឹងបន្តទៅមុខទៀត។ ចូលទៅដល់ប្រធានបទមួយដែលពាក់-ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនង។ ខ្ញុំសូមធ្វើការពិភាក្សាបន្តិចទៅលើបញ្ហាប្រព័ន្ធទំនាក់ទំនងក្នុងសម័យនោះវាមិនមានអ្វីជាទូទៅ និងអរូបីនោះទេ ការទំនាក់ទំនងនោះរួមទាំងការឆ្លើយឆ្លងលិខិត ទូរលេខ លិខិតឆ្លើយឆ្លង ហើយដែលលោកនោះក៏បានធ្វើទំនាក់ទំនង ហើយលោកក៏បានឆ្លងកាត់ដោយផ្ទាល់ផងដែរ។

ក្នុងអំឡុងពេលប៉ុន្មានថ្ងៃនេះ លោកបានជម្រាបអំពីប្រព័ន្ធទំនាក់ទំនងនេះ ហើយលោកក៏បានជម្រាបផងដែរថា "គ្រួសាររបស់លោក បងប្អូនរបស់លោក ឪពុករបស់លោក គឺបានធ្វើការពាក់ព័ន្ធទៅនឹងប្រព័ន្ធទាក់ទងនេះផងដែរ"។ ហើយលោកក៏បានមើលឃើញនូវសារទូរលេខមួយចំនួនដែលចៅក្រម ឡាវែន៍ និងខាងសហព្រះរាជអាជ្ញាបង្ហាញឲ្យលោកមើល។ ដូច្នេះ ខ្ញុំសូមសួរលោកអំពីប្រព័ន្ធទំនាក់ទំនងជាក់លាក់ជាថ្មីម្តងទៀត គឺថាសូមឲ្យលោកកម្រិតការឆ្លើយរបស់លោក តាមអ្វីដែលលោកបានដឹង ឆ្លងកាត់ឬក៏បទពិសោធន៍របស់លោកដែលធ្វើការងារជាមួយនឹងក្រុមគ្រួសាររបស់លោក មិនមែនអ្វីដែលគេប្រាប់លោកនោះទេ ដូច្នេះសូមលោកឆ្លើយទៅតាមបទពិសោធន៍ និងការយល់ដឹងរបស់លោក។ ខ្ញុំសូមធ្វើការចាប់ផ្តើមសួរសំណួរ ផ្នែកដែលសំណួររបស់ខ្ញុំនោះ គឺខ្ញុំនឹងកម្រិតសំណួររបស់ខ្ញុំទៅលើប្រភព និងភាពពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង០០២/០១។ ជាពិសេស លើការជម្លៀសទីក្រុងភ្នំពេញ។ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ នោះ គឺថាឃើញមានការធ្វើឡើងក្រោយចុងឆ្នាំ១៩៧៥ និង៧៦។ ដូច្នេះនេះគឺជាសាវតារខ្លះៗឲ្យលោកបានជ្រាប។ ខ្ញុំសូមលើកឡើងនូវចំណុចចម្បងៗនៅក្នុងរឿងក្តីនេះសួរទៅកាន់លោក។

[១១:១៣:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក អ៊ីនូហ្សី អង្គជំនុំជម្រះបានស្នើសុំឲ្យលោកកុំឲ្យធ្វើអត្ថាធិប្បាយ ឬក៏លើកឡើងសេចក្តីផ្តើមបរិបទទូទៅរបស់លោកនេះ។ សូមឲ្យលោកសួរសំណួរជាក់លាក់តែម្តង ហើយសំណួររបស់លោកសួរខ្លីៗ និងយឺតៗ ដោយសារតែយើងដូចជាមិនយល់នូវអ្វីដែលលោកសួរទៅកាន់សាក្សីនោះទេ ប្រសិនបើមិនមានការបកប្រែឲ្យបានត្រឹមត្រូវនោះ។

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំសូមអធ្យាស្រ័យចំពោះអ្នកបកប្រែ ប្រសិនបើខ្ញុំនិយាយលឿន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្សី៖**

**ស៖** ជាថ្មីម្តងទៀតលោកសាក្សី ខ្ញុំនឹងសួរលោកទៅតាមការណែនាំរបស់អង្គជំនុំជម្រះ។ សំណួរ

របស់ខ្ញុំគឺខ្លី ហើយខ្ញុំសួរពាក់ព័ន្ធទៅនឹងអង្គហេតុចម្បងនៅក្នុងរឿងក្ដីនេះ។ សំណួររបស់ខ្ញុំគឺថា តាមដែលលោកដឹងគ្រួសាររបស់លោក ឪពុករបស់លោក បងប្អូនរបស់លោកនេះ មានធ្លាប់ទាក់ទងជាមួយនឹង នួន ជា អំពីការជម្លៀសទីក្រុងភ្នំពេញដែរឬទេ?

**លោក ផាន វ៉ាន៖**

**ផ៖** មិនបានដឹងទេបាទ ពីការ -- ទាក់ទងនឹងការជម្លៀសប្រជាជន តែដឹងថាមានការទាក់ទងជាមួយគាត់បាទ។ មានប៉ុណ្ណឹង។

**ស៖** សូមឱ្យលោកបញ្ជាក់មើលថា តើទាក់ទងហ្នឹងគឺទាក់ទងអ្វីដែរ? សូមលោកជួយបញ្ជាក់។

**ផ៖** ខ្ញុំមិនបានដឹងទេ ព្រោះគាត់ខាងលើមិនដឹងគាត់និយាយរឿងអី ដឹងត្រឹមតែគាត់បានទាក់ទងគ្នាតែប៉ុណ្ណឹងឯង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមបញ្ជាក់បំភ្លឺ លោកនិយាយថា លោកមិនដឹងថាទាក់ទងលើបញ្ហាអ្វីនោះទេ ដូច្នេះ ខ្ញុំសួរលោកថាតើបានទាក់ទងអំពីការជម្លៀសទីក្រុងភ្នំពេញដែរឬទេ? ហើយលោកនិយាយថា គាត់បានទាក់ទងគ្នាតែមិនដឹងរឿងអ្វី។ ដូច្នេះ ខ្ញុំសូមសួរឱ្យលោកបញ្ជាក់ឱ្យច្បាស់តាមអ្វីដែលលោកដឹងនោះគឺថា ឪពុករបស់លោកជាមួយនឹង នួន ជា នេះបានធ្វើការទាក់ទងគ្នា អំពីបញ្ហាជម្លៀសទីក្រុងភ្នំពេញដែរឬទេ? បើសិនជាលោកដឹងនោះលោកដឹងតាមណាដែរ?

**ផ៖** អត់បានដឹងទេបាទ។

[១១:១៦:១៣]

**ស៖** នៅពេលនេះ ខ្ញុំសូមចូលសួរលោកពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។ ដំណាក់កាលទី២ នេះគឺគ្មានការចោទអំពីហេតុការជម្លៀសផ្លាស់ទីលំនៅប្រជាជន គឺអំឡុងខែកញ្ញាឆ្នាំ១៩៧៥ រហូតដល់ទៅ ឆ្នាំ១៩៧៦ និងរហូតដល់ ៧៧។ តើឪពុករបស់លោក លោក បងប្អូនរបស់លោកនេះ មានបានធ្វើការទាក់ទងជាមួយ លោក នួន ជា អំពីការផ្លាស់ទីលំនៅប្រជាជន ជាពិសេសការជម្លៀសប្រជាជននៅខាងផ្នែកនិរតី ឬក៏ខាងផ្នែកបស្ចិមបាទ។

**ផ៖** បាទអត់បានដឹងទេ បាទ ខ្ញុំនៅក្មេងៗម៉េចដឹងជំនាន់នោះ។

**ស៖** សូមអរគុណ។ ចុះការជម្លៀសទៅកាន់បូព៌ា ឬក៏បស្ចិម តើលោកដឹងទេឪពុករបស់លោក ឬក៏សមាជិកគ្រួសាររបស់លោកបានធ្វើការទាក់ទងជាមួយនឹងលោក នួន ជា អំពីការផ្លាស់ទីលំនៅប្រជាជនទៅកាន់ភូមិភាគបូព៌ា ឬក៏ភូមិភាគបស្ចិម?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ចំពោះសំណួរចុងក្រោយនេះ ខ្ញុំសូមធ្វើការជំទាស់សុំឲ្យគាត់ធ្វើរបៀបផ្សេង។ គាត់សួរនិយាយអំពីបងប្អូន ឪពុក ហើយនិងនិយាយអំពីសាក្សី ដូច្នេះសាក្សីគាត់ឆ្លើយអម្បាញ់មិញតែឈ្មោះតែម្នាក់ទេ ហើយសុំឲ្យសួរតែពាក់ព័ន្ធតែនឹងគាត់ទៅបានហើយ កុំឲ្យពាក់ព័ន្ធនឹងក្រុមគ្រួសាររបស់គាត់។ ការសួរបែបនេះធ្វើឲ្យមានការភ័ន្តច្រឡំ។

[១១:១៨:២៨]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំនឹងធ្វើតាមការស្នើដូច្នេះពីខាងសហមេធាវីនាំមុខ។ តាមអ្វីដែលខ្ញុំដឹងគឺថា ៨0ភាគរយនៃចម្លើយរបស់សាក្សីរូបនេះ គឺពាក់ព័ន្ធនឹងការងាររបស់គាត់ធ្វើការងារជាមួយឪពុករបស់លោក។ ហើយការងារមួយចំនួននោះ គឺថាគាត់បានដឹងពីឪពុករបស់គាត់ ឪពុករបស់គាត់ប្រាប់។ ដូច្នេះ ខ្ញុំគិតថាវាមិនមានអ្វីខុសសួរទៅកាន់សាក្សីរូបនេះបែបនេះឡើយ។ សាក្សីនៅទីនេះមកឆ្លើយសក្ខីកម្មដោយសារគាត់ជាភ្នាក់ងារ ឬក៏អ្នកធ្វើការងារជាមួយឪពុករបស់គាត់។ ដូច្នេះខ្ញុំសូមសួរទៅកាន់សាក្សី ថាតើលោកសាក្សី នេះតាមដែលលោកដឹងដោយផ្ទាល់នោះ តើលោកបានដឹងថា ឪពុករបស់លោកបានទាក់ទងជាមួយនឹងលោក នួន ជា អំពីការជម្លៀសប្រជាជនទៅកាន់ភូមិភាគបូព៌ា ឬក៏បស្ចិមដែរឬទេ?

**ឆ៖** អត់ដឹងទេបាទ។

**ស៖** ចុះឪពុករបស់លោកឬក៏បងប្អូនរបស់លោកនោះធ្លាប់បានប្រាប់លោកថា ពួកគាត់ធ្លាប់បានទាក់ទងជាមួយលោក នួន ជា អំពីបញ្ហាជម្លៀសប្រជាជនទៅកាន់ភូមិភាគបូព៌ា និងបស្ចិមដែរឬទេ?

**ឆ៖** អត់ដឹងទេបាទ។

[១១:២០:០៣]

**ស៖** សូមអរគុណ។ ចុះចំណែកតំបន់១០៦ តំបន់នៅឯសៀមរាបឯណោះ តើលោកធ្លាប់ចូលរួម ឬក៏លោកធ្លាប់ទាក់ទងជាមួយនឹងលោក នួន ជា ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនទៅតំបន់១០៦ ឬចេញពីតំបន់១០៦នៅក្នុងខេត្តសៀមរាបដែរឬទេ?

**ធ៖** អត់យល់ពីសំណួរទេ មិនដឹងសួរអី។ មិនដឹងន័យយ៉ាងម៉េច ពីព្រោះខ្ញុំមិនទិនទៅខាងសៀមរាប សៀមអី ខ្ញុំនៅមណ្ឌលជំនាន់ហ្នឹង។ អត់មានបានដឹងរឿងគេទេបាទ។

**ស៖** មិនជាអ្វីទេ ខ្ញុំទទួលយកចម្លើយនេះ។ ចុះចំពោះការងារនៅខាងពាយ័ព្យ គឺនៅក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ។ តើលោកធ្លាប់ធ្វើការទាក់ទងជាមួយនឹងលោក នួន ជា អំពីខាងប៉ែកពាយព្យនេះដែរឬទេ? គឺខាងបញ្ហាបន្ទាយមានជ័យ ពោធិ៍សាត់ និងបាត់ដំបង។

**ធ៖** ជំនាន់ហ្នឹងអត់មានទេបាទ ខ្ញុំនៅក្មេង ខ្ញុំអត់មានដែលបានស្គាល់ដឹងរឿងអីអ៊ីចឹងៗទេបាទ។

[១១:២១:៣២]

**ស៖** សូមអរគុណ។ ចុះចំណែកកំពង់ធំ និងកំពង់ចាម តើលោកធ្លាប់ទាក់ទងជាមួយនឹងលោក នួន ជា អំពីខេត្តកំពង់ចាម និងកំពង់ធំនោះដែរឬទេ?

**ធ៖** អត់ទេបាទ អត់ធ្លាប់ទេ។

**ស៖** សូមអរគុណលោកសាក្សី។ ដើម្បីឲ្យចម្លើយមានលក្ខណៈពេញលេញ តើលោកធ្លាប់ចូលរួមធ្វើការទាក់ទងជាមួយនឹងលោក នួន ជា ពីចុងឆ្នាំ១៩៧៧ រហូតទៅដល់ឆ្នាំ១៩៧៨ ដែរឬទេ? ដែលទាក់ទងអំពីបញ្ហាជម្លៀសប្រជាជន ឬផ្លាស់ទីលំនៅប្រជាជនទៅកាន់ភូមិភាគបូព៌ានោះ?

**ធ៖** អត់មានទេបាទ។

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមសួរលោកអំពីទូរលេខដែលបានយកមកឲ្យលោកពិនិត្យមើល ហើយខ្ញុំជឿថាប្រសិនបើខ្ញុំចាំមិនខុសនោះទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខ្ញុំជឿថាគាត់បានយកសារទូរលេខចំនួនប្រាំមកសួរលោក។ ខ្ញុំគិតថា ខ្ញុំដូចជាចាំមិនខុសនោះទេ ហើយចៅក្រម ឡាវែន៍ នោះខ្ញុំមិនដឹងគាត់យកប៉ុន្មានមកសួរលោកនោះទេ។ ហើយខ្ញុំនឹងសួរលោក ឲ្យលោកឆ្លើយ ប្រសិនបើលោកមិនអាចឆ្លើយបានក៏មិនអ្វីដែរ។ តើលោកចាំទេ សារទូរលេខទាំងអស់នោះ ដែលបានបង្ហាញជូនលោកពិនិត្យមើលនោះ តើមានពាក់ព័ន្ធទៅនឹងបញ្ហានៃការផ្លាស់ទីលំនៅប្រជាជនដែរឬទេ?

[១១:២៣:២៩]

**ធ៖** ខ្ញុំអត់យល់ទេបាទ ព្រោះតាមខ្លឹមសារសារហ្នឹង វាគ្មានទាក់ទិនអីទេបាទ។

**ស៖** សូមអរគុណ។ លោកសាក្សី ខ្ញុំនៅឆ្ងល់ តើលោកភ្ញាក់ផ្អើលដែរឬទេ មានការចោទប្រកាន់មួយ គឺមិនមានការចោទប្រកាន់អំពីការផ្លាស់ទីលំនៅប្រជាជនទៅកាន់តំបន់១០៦ ឬចេញមកពីតំបន់១០៦ នៅក្នុងខេត្តសៀមរាបនោះទេ។ តើលោកៗមានការភ្ញាក់ផ្អើលដែរឬទេ ដែលនៅក្នុងដីកាដំណោះស្រាយ

មិនមានលើកឡើងអំពីបញ្ហាផ្លាស់ទីលំនៅប្រជាជនទៅកាន់តំបន់១០៦ ឬចេញពីតំបន់១០៦នោះ?

លោកសាក្សីសូមចាំបន្តិចសិន។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ -- មិន -- កុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន ឃើញសំណួរជាច្រើនដែលបានលើកដោយលោកមេធាវីអន្តរជាតិរបស់លោក នួន ជា។ ហើយជាពិសេសសំណួរចុងក្រោយនេះ ឃើញថាជាសំណួរដែលថា មុនៗជាសំណួរដែលថាសាក្សីភាគច្រើនមិនអាចមានយោបល់ពាក់ព័ន្ធបញ្ហានេះទេ ក៏ប៉ុន្តែត្រូវបានលើក ហើយអាចធ្វើឲ្យមានការភ័ន្តច្រឡំក្នុងចំណោមសាធារណជន។ ចំណែកសំណួរចុងក្រោយ គឺថាឲ្យសាក្សី ឲ្យយោបល់ទៅលើនីតិវិធី។ ហើយចំណុចនេះជាចំណុចដែលមិនពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ ហើយជាសំណួរដែលមិនសមហេតុផល។ សូមអរគុណ។

[១១:២៥:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ ខ្ញុំគិតថាពិតណាស់លោកប្រធាន។ សំណួរចុងក្រោយនេះគួរតែរៀបចំសួរឡើងវិញ ដើម្បីកុំឲ្យមានការធ្វើការអត្ថាធិប្បាយទៅលើខ្លឹមសារនៃដីកាដំណោះស្រាយនោះ។ ពាក់ព័ន្ធទៅនឹងតំបន់១០៥ ហើយយើងគួរតែសួរថាតើសាក្សីដឹងអំពីប្រធានបទនេះដែរឬទេ? ប្រសិនបើមេធាវីការពារក្តីចង់សួរនោះ ក៏ប៉ុន្តែការឲ្យអត្ថាធិប្បាយទៅលើដីកាដំណោះស្រាយនោះ មិនសមស្របទេ។ សូមសួរនូវអ្វីដែលគាត់បានឮ គាត់បានឃើញនៅតំបន់១០៥ ឬក៏នៅភ្នំពេញ នៅពេលដែលគាត់មកធ្វើការនៅភ្នំពេញនោះ? សូមអរគុណ។

[១១:២៦:០៤]

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

ជាដំបូងខ្ញុំសូមឆ្លើយតបទៅនឹងសហមេធាវីនាំមុខ។ ខ្ញុំមិនមានបំណងឲ្យសាធារណជនយល់ច្រឡំនោះទេ អ្វីដែលខ្ញុំធ្វើឡើងនេះ គឺដោយស្មោះត្រង់តែប៉ុណ្ណោះ គឺឲ្យសាធារណជនបានដឹងអំពីសក្ខីកម្មដែល

យើងបានស្តាប់ឮនេះ គឺថាសក្ខីកម្មដែលយើងស្តាប់ឮនេះ មិនពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលកំពុងចោទប្រកាន់នៅក្នុងនេះនោះទេ។ ដូច្នេះខ្ញុំគិតថា វាចម្លែកណាស់ ខ្ញុំគ្រាន់តែចង់ដឹងពីសាក្សីនេះដោយផ្ទាល់តែប៉ុណ្ណោះ។ ចំពោះខ្ញុំ ខ្ញុំទំនងជាយល់ឃើញថា យើងចាប់អារម្មណ៍ទៅលើប្រព័ន្ធទំនាក់ទំនង ឬក៏របនាសម្ព័ន្ធរដ្ឋបាល។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ត្រូវតែមានទំនាក់ទំនងរវាងរចនាសម្ព័ន្ធប្រព័ន្ធទាំងអស់នោះទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ហើយយើងមិនអាចធ្វើការជំនុំជម្រះទៅតាមទ្រឹស្តីអ្វីដែលកើតឡើងនៅទីនោះ និងទីនេះនោះឡើយ។ អ្វីដែលយកមកដាក់ចោទប្រកាន់នៅក្នុងតុលាការនេះ គឺថាត្រូវតែពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម។ ឧក្រិដ្ឋកម្មនោះ គឺថា គឺ--

[១១:២៧:១១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះស្តាប់អស់ហើយ។ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មានប្រសិទ្ធភាព។ សេចក្តីជំទាស់ហ្នឹងមានមូលហេតុត្រឹមត្រូវ សាក្សីមិនមានកាតព្វកិច្ចផ្តល់យោបល់ទៅលើនីតិវិធីនៃដីកាដំណោះស្រាយ ថាចោទប្រកាន់អង្គហេតុណា អង្គហេតុណាមិនចោទប្រកាន់នោះទេ។ ទី២ គឺការសួរដេញដោលសុំឲ្យធ្វើនៅក្នុងកម្រិតវិសាលភាពនៃអង្គហេតុ ដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការដែលបានចែងរួចហើយនៅក្នុងដីកាដំណោះស្រាយ ដកស្រង់ គឺនៅក្នុងសំណុំរឿង ០០២/០១។

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរទៅលើប្រធានបទមួយចំនួនដែលយើងខ្ញុំគិតថា វាពាក់ព័ន្ធទៅនឹងរឿងក្តីនេះ ហើយសាក្សីនេះបានដឹង។

[១១:២៨:១០]

**សួរដោយលោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** លោកសាក្សី លោកបានជម្រាបយើងខ្ញុំអំពីទីតាំងមួយចំនួនដែលលោករស់នៅក្នុងសម័យនោះ។ ខ្ញុំសូមសួរលោកអំពីរយៈកាល ពីឆ្នាំ១៩៦៩ ទៅដល់៧៣ លោកបានឆ្លើយរួចមកហើយជូនអង្គជំនុំជម្រះអំពីអំឡុងពេលនេះដែលលោករស់នៅ។ ក្នុងអំឡុងពេលនោះ តើលោកខ្លួនឯងនេះ តើលោកធ្លាប់ឃើញដោយផ្ទាល់ភ្នែកចំពោះការទម្លាក់គ្រាប់បែកដោយអាមេរិកដែរឬទេ មកលើទឹកដីប្រទេសកម្ពុជានោះ?

[១១:២៨:៤៩]

**លោក ផាន វ៉ាន៖**

**ផ៖** ធ្លាប់ឃើញបាទ ទម្លាក់គ្រាប់បែក។ អ្នកណាក៏ឃើញដែរ ឃើញគ្រប់តែគ្នាហ្នឹង។ មានប៉ុណ្ណឹងបាទ។

**ស៖** តើនៅពេលដែលលោកនិយាយថា នរណាក៏ឃើញគ្រប់គ្នាហ្នឹង លោកនិយាយថា អ្នកទាំងអស់គ្នានៅក្នុងប្រទេសកម្ពុជា ឬក៏យ៉ាងម៉េច?

**ផ៖** បាទ ចង់សន្និដ្ឋាន -- សន្មតថាអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ តើលោកអាចពិពណ៌នារៀបរាប់អំពីការទម្លាក់គ្រាប់បែកនេះដែរឬទេ ផ្អែកតាមអ្វីដែលលោកបានធ្លាប់ឆ្លងកាត់ និងឃើញ កើតមាននៅទូទាំងប្រទេសនោះ? តើលោកអាចជួយជម្រាបអំពីទំហំ ឬការទម្លាក់គ្រាប់បែកនោះ តើវាមានលក្ខណៈយ៉ាងម៉េចដែរ?

[១១:២៩:៤៦]

**ផ៖** អត់ៗយល់ពីអត្ថន័យសំណួរ លក្ខណៈយ៉ាងម៉េចបាទ?

**ស៖** សូមអធ្យាស្រ័យលោកសាក្សី តើលោកឃើញការទម្លាក់គ្រាប់បែកនោះប៉ុន្មានដងដែរ នៅក្នុងប្រទេសកម្ពុជា បើលោកចាំនោះ?

**ផ៖** ខ្ញុំដឹងតែនៅស្រុកខ្ញុំទេ នៅមណ្ឌលនោះ គឺវាសឹងតែរាល់ថ្ងៃជំនាន់ហ្នឹងបាទ។ មានបាញ់ផងមានទម្លាក់ផង។

**ស៖** លោកអម្បាញ់មិញឆ្លើយថាគឺ រាល់ថ្ងៃ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ។

**ស៖** សូមអរគុណ។ តើលោកបានដឹង តាមបទពិសោធន៍ដែលលោកឆ្លងកាត់ តាមអ្វីដែលលោកបានដឹង ឬក៏ពីការប្រាប់របស់សមាជិកគ្រួសាររបស់លោក តើលោកបានដឹងថាការទម្លាក់គ្រាប់បែករបស់អាមេរិកនេះ មានបានកម្ទេចបំផ្លាញវាលស្រែស្រូវនៅក្នុងមណ្ឌលរបស់លោកនៅក្នុងប្រទេសកម្ពុជាដែរឬទេ?

**ផ៖** មានបាទ។

**ស៖** សូមអរគុណ។

**ផ៖** មិនមែនឮគេថាទេ អាហ្នឹងគឺជាក់ស្តែងតែម្តងបាទ។ ពីជំនាន់ហ្នឹងត្រង់សេមានតែគ្រប់ៗផ្ទះតែថ្ងៃឡើងនៅនឹងដំបូក។ ដាំបាយពីល្ងាចអ៊ីចឹងទៅ ពីយប់ហ្នឹង យប់ដាំបាយ បិទគម្របផ្សែងអីៗអ៊ីចឹង

ទៅ សម្រាប់មួយថ្ងៃអ៊ីចឹង។ យើងដាំបាយទុកមួយថ្ងៃនាំគ្នាទៅនៅតាមរន្ធដំបូក ជីកត្រង់សេ បាទ។ ដឹងគ្រប់តែគ្នាអ៊ីចឹងបាទ។

**ស៖** ខ្ញុំចង់ឲ្យច្បាស់ ថាហើយលោកត្រូវចូលត្រង់សេ ដើម្បីគេចផុតពីការទម្លាក់គ្រាប់បែកក្រែងលោត្រូវស្លាប់។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងហើយបាទ។

[១១:៣២:០១]

**ស៖** សូមអរគុណ ខ្ញុំនៅមានសំណួរមួយទៀត។ តាមអ្វីដែលលោកដឹងផ្ទាល់ តើមានពលរដ្ឋកម្ពុជាណាស្លាប់ទេ នៅក្នុងពេលដែលមានការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិកនោះ?

**ឆ៖** មានដែរបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតត្រឡប់ទៅចំណុចមួយដែលលោកបានឆ្លើយ លោកបាននិយាយថា នៅថ្ងៃទី១ដែលលោកបានមកបំភ្លឺ គឺថាថ្ងៃទី -- ថ្ងៃអង្គារ គឺថាលោកបានជួប តាម៉ុក នៅប-២០។ តើត្រឹមត្រូវដែរទេដែលលោកបានជួប តាម៉ុក នៅពេលដែលលោកនៅមន្ទីរប-២០នោះ?

**ឆ៖** អត់ទេ អត់ត្រឹមត្រូវទេ។ ខ្ញុំអត់បានថា ជួប តាម៉ុក ទេ។

**ស៖** តើលោកបានជួប តាម៉ុក ដែរឬទេ?

**ឆ៖** អត់ទេបាទ។

[១១:៣៣:១៩]

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅដល់ចំណុចមួយដែលពេលថា ចំណុចចុងក្រោយនៅក្នុងចម្លើយរបស់លោកផ្នែកមួយ។ ខ្ញុំជឿថា ជាចម្លើយចុងក្រោយដែលឆ្លើយទៅសហចៅក្រមស៊ើបអង្កេតដែលដើមបណ្ដឹងរដ្ឋប្បវេណីបានយោងទៅហើយ គឺមានព័ត៌មានជាច្រើនទាក់ទងទៅនឹង អៀង ធីរិទ្ធ។ ប៉ុន្តែនៅទំព័រមួយនៅក្នុងឯកសារនេះ គឺE3/447។ សូមអភ័យទោស ខ្ញុំមានតែភាសាអង់គ្លេស ERN ទេ ខ្ញុំមានសំណួរសាមញ្ញទេ។ ទំព័រដែលខ្ញុំមើលនោះ គឺថា ERN 00486512 បាទ។ លោកបាននិយាយនៅក្នុងចម្លើយនោះថា "នៅថ្ងៃទី២០ ខែ២ ឆ្នាំ២០១០ ថា សតឹម ល្អុត, គាត ឈន់ ក៏បានធ្វើការជាមួយលោក អៀង សារី"។ សំណួរសួរថា តើ គាត ឈន់ ជាអ្នកណា?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេថា គាត ឈន់ ជាអ្នកណា។ ប៉ុន្តែកាល ខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះកាល

គេទៅសួរនាំហ្នឹង គឺថារបៀបសួរព្រោកប្រាជ្ញគ្នា សួរថាស្គាល់អ្នកនេះ ស្គាល់អ្នកនោះអីអ៊ីចឹងទៅ។ ហើយខ្ញុំថា ខ្ញុំមិនស្គាល់ទេ ឮតែឈ្មោះ ខ្ញុំប្រាប់អ៊ីចឹង។ ឮតែឈ្មោះទេ មិនមែនទៅស្គាល់ជិតស្និទ្ធអីទេ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** តើលោកចាំដែរឬទេថាលោកបានប្រាប់អ្នកអង្កេតថា "គាត ឈន់ ហើយពីរនាក់ទៀតបានធ្វើការជាមួយ អៀង សារី" តើលោកនៅចាំទេ? តើលោកចាំថាបានពិភាក្សាអំពីឈ្មោះ គាត ឈន់ នេះជាមួយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** ចាំអត់បានទេបាទ ។

**ស៖** សូមអរគុណ។ ប្រហែលជាខ្ញុំអានឈ្មោះខុស គឺថាដើម្បីឲ្យច្បាស់បុគ្គលនោះគឺគាត់បច្ចុប្បន្ននេះជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា តើលោកនៅនឹកឃើញពីបញ្ហាហ្នឹងដែរទេ?

**ឆ៖** ដូចនឹកមិនឃើញ។

[១១:៣៦:១៦]

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយទៀត។ តើលោកដឹង តើលោកដឹងថារដ្ឋមន្ត្រីក្រសួងព័ត៌មានគឺបានបដិសេធមិនសហការជាមួយសាលាក្ដីនេះទេ? តើលោកបានដឹងទេ ថ្មីៗនេះនោះ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ ឥតមានពាក់ព័ន្ធទេណ៎ះ សំណួរហ្នឹង អត់មានពាក់ព័ន្ធទេ សាក្សីមិនបាច់ឆ្លើយតបទេ។

**លោក អេនគ្រូ អ៊ីទ្ធហ្ស៊ឺ៖**

បាទ ខ្ញុំៗដឹងពីមូលហេតុ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅទៀត។

**សួរដោយលោក អេនគ្រូ អ៊ីទ្ធហ្ស៊ឺ៖**

**ស៖** សំណួរមួយពីរទៀតទេ លោកសាក្សី ហើយខ្ញុំនឹងផ្ដល់វេទិកាទៅមេធាវីការពារជាតិ។ ឥឡូវនេះ យើងចូលទៅដល់បញ្ហាអំពីការជម្លៀសដោយបង្ខំរបស់ -- ទៅលើប្រជាពលរដ្ឋកម្ពុជា ហើយលោកបានប្រាប់ខ្ញុំបន្តិចហើយអំពីបទពិសោធន៍នៅក-១៧។ បាទ ដែលថាភាសាខ្មែរគឺថា ក-១៧។ តើលោកអាចប្រាប់ខ្ញុំអំពីការជម្លៀសប្រជាជនទាក់ទងទៅថា ភ្នំក្រោល ឬភ្នំក្រោលនោះ--

[១១:៣៧:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្លាងឈេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសាក្សី សូមទោស គឺមេធាវីគាត់ព្យាយាមនិយាយភាសាខ្មែរអម្បាញ់មិញនេះ។ ហើយយើងអត់មានការបកប្រែទេ គឺថា -- មិនដឹងថា “ក” ប៉ុន្មានទេ អំមិញនេះ យើងអត់មានបកប្រែជាខ្មែរ ជាអង់គ្លេស -- ជាភាសាបារាំង ជាភាសាអង់គ្លេស នៅពេលដែលមេធាវីនិយាយជាភាសាខ្មែរនោះ។ សូមឲ្យគាត់និយាយម្តងទៀតជាភាសាអង់គ្លេស ដើម្បីឲ្យយើងយល់បានទាំងអស់គ្នា។

**លោក អេនឌ្រូ អ៊ីនួហ្សុី៖**

បាទ ខ្ញុំរីករាយនឹងធ្វើបែបនោះ។ ក៥ គឺ K5 ហើយខ្ញុំជឿថា យើងទាំងអស់គ្នាដឹងហើយ។

**សួរដោយលោក អេនឌ្រូ អ៊ីនួហ្សុី៖**

**ស៖** សាក្សី តើលោកនៅចាំទេទាក់ទងទៅនឹងការជម្លៀសប្រជាជន ឬក៏ការបញ្ជូនប្រជាជនទាក់ទងទៅនឹង ក៥ ដែលកើតឡើងនៅភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៨០ ទសវត្សរ៍ឆ្នាំហ្នឹង តើលោកបានដឹងទេបាទ?

[១១:៣៩:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ។ សំណួរបែបនេះគឺជាសំណួរឥតពាក់ព័ន្ធទេ។

**លោក អេនឌ្រូ អ៊ីនួហ្សុី៖**

ហើយខ្ញុំទទួចចង់ដឹងពីបញ្ហានេះ គឺវាមានបញ្ហាពាក់ព័ន្ធ ទាក់ទងទៅនឹងចំនួនមនុស្សស្លាប់ ដែលអាចនឹងប៉ះពាល់ទៅដល់--

**ប្រធានអង្គជំនុំ៖**

យើងមិនឲ្យលោកធ្វើអត្ថាធិប្បាយទេ យើងបានប្រាប់លោកហើយ។ លោកអាចតាំងសំណួរជាក់លាក់បាន។ បើយើងឲ្យសាក្សីឆ្លើយ គឺយើងនៅស្ងៀម ហើយយើងមិនឲ្យឆ្លើយទេ យើងប្រាប់ពីមូលហេតុដែលមិនបាច់ឲ្យសាក្សីឆ្លើយតប ដូចអំមិញអ៊ីចឹង។ តែលោកចងចាំថា យើងមិនឲ្យលោកធ្វើអត្ថាធិប្បាយអ្វីទេ។

**លោក អេនឌ្រូ អ៊ីនូហ្វី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចូលទៅដល់សំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំអាចនឹងសុំបំភ្លឺមូលហេតុដែលមិនអនុញ្ញាតឲ្យខ្ញុំសួរអំពី ក៥ ពីព្រោះថាបទឧក្រិដ្ឋហ្នឹង---

[១១:៤០:២៣]

**ប្រធានអង្គជំនុំ៖**

យើងបានបដិសេធហើយ យើងមិនឲ្យសាក្សីឆ្លើយតបទេ។ ពីព្រោះសំណួរមិនពាក់ព័ន្ធ។ សំណួរមិនពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់លើជនជាប់ចោទ។ សំណួរមិនពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់លើជនជាប់ចោទ!

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរសំណួរចុងក្រោយ។

**ស៖** សាក្សីនៅថ្ងៃអង្គារនៅពេលដែលលោកឆ្លើយអំពីបញ្ហាមួយចំនួនដែលកើតមានឡើងនៅកីឡដ្ឋានអូឡាំពិកនៅភ្នំពេញនោះ លោកបាននិយាយថា លោកមិនបានចូលរួមការប្រជុំនោះទេ ប៉ុន្តែលោកបានទៅអូឡាំពិកដើម្បីទៅមើលការសម្តែង ថាតើលោកបានទៅមើលល្ខោន ឬក៏ការសម្តែងដូចម្តេច? ថាតើដូចជាការសម្តែងនៅក្នុងសាលសវនាការនេះចំពោះអង្គជំនុំជម្រះសាលាដំបូងនេះ ឬក៏ខុសពីនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤២:២៨]

លោកបន្តសំណួរជៀសវាងលោកប្រើប្រាស់នូវអាកប្បកិរិយាប្រមាថដល់អង្គជំនុំជម្រះ។

**លោក អេនឌ្រូ អ៊ីនូហ្វី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមដើម្បីថាបើសិនជាអង្គជំនុំជម្រះបន្តធ្វើការលើប្រតិចារឹកយើងឃើញថា អាចនឹងទទួលបាននូវកិត្តិយសមិនល្អ។

**ប្រធានអង្គជំនុំ៖**

លោកឈប់សិន! អង្គុយចុះ! ចាំយើងពិភាក្សាគ្នាសិន។

[១១:៤៣:១៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៥:១៩]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធាន ខ្ញុំបញ្ចប់សំណួរប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

អត់ទេៗ អង្គុយចុះសិន! យើងអត់ទាន់អនុញ្ញាតឲ្យឯង -- លោកធ្វើការសួរ បន្តសួរទៀតទេ។ យើងពិភាក្សាសម្រេចករណីនេះជាមុនសិន។

[១១:៤៥:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៨:១៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីងើបឈរ!

ដោយលោកមេធាវីបានរំលោភ ដោយការបំពាន ប្រមាថដល់អង្គជំនុំជម្រះច្រើនលើកច្រើនសា ហើយអង្គជំនុំជម្រះបានព្រមានលោកមេធាវីច្រើនលើកច្រើនសាហើយ គឺនៅតែមិនកែប្រែ។ ថ្ងៃនេះសាជាថ្មីម្តងទៀត លោកបានព្រមាន អ៎! បានប្រមាថដល់អង្គជំនុំជម្រះ ដល់កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ បង្កការរាំងស្ទះនៅក្នុងកិច្ចដំណើរការនីតិវិធី រំលោភលើរឿងក្តី អង្គជំនុំជម្រះសម្រេចបណ្តេញលោកចេញពីកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលសម្រាប់ថ្ងៃនេះ នាពេលនេះ។ សូមលោកចាកចេញពីសាលសវនាការ!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

តើលោកមានប្រសាសន៍ថា ខ្ញុំត្រូវចេញពីសាលសវនាការមែនទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ត្រូវហើយ ចាកចេញពីសវនាការសម្រាប់ថ្ងៃនេះ! ដោយផ្អែកលើតាមវិធាន៣៨(១) នៃវិធានផ្ទៃក្នុងស្តីពីវិជ្ជាជីវៈរបស់មេធាវី។ សូមលោកចាកចេញ! លោកមិនមាន -- ចាប់ពីពេលនេះតទៅណ៎ា មិនឲ្យអនុញ្ញាតឲ្យលោកនិយាយអីទៀតទេ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំជឿថា ខ្ញុំត្រូវនៅការពារកូនក្តីខ្ញុំ។

**ប្រធានអង្គជំនុំ៖**

លោកចាកចេញ!

សាជាថ្មីម្តងទៀត សូមលោកមេធាវីចាកចេញពីបន្ទប់សវនាការនេះ ចាប់ពីពេលនេះតទៅ សម្រាប់ថ្ងៃនេះ។ ថ្ងៃថ្មីគឺអង្គជំនុំជម្រះនឹងពិចារណាផ្សេងទៀត។

អង្គជំនុំជម្រះបញ្ជាកងកម្លាំងសន្តិសុខ ដែលរក្សាសណ្តាប់ធ្នាប់នៅក្នុងបន្ទប់សវនាការនេះ នាំលោកមេធាវី អេនគ្រូ អ៊ីនូហ្ស៊ី ដែលជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចាកចេញពីបន្ទប់សវនាការនេះ។

[១១:៥១:២៣]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំរង់ចាំខាងសន្តិសុខជូនខ្ញុំទៅ។

*(សន្តិសុខនាំមេធាវីចាកចេញពីបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សុន អរុណ មានអីតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះទេ? សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

ខ្ញុំមានរៀបចំសំណួរខ្ញុំប្រហែលជា៤០ ទៅ៥០នាទី សម្រាប់សួរបន្តទៅនេះ។ ឥឡូវ ខ្ញុំឃើញពេលវេលាមានតែ៩នាទី ដល់ពេលសម្រាក តើអនុញ្ញាតឲ្យខ្ញុំធ្វើបានប៉ុន្មានយកប៉ុណ្ណឹង ឬយ៉ាង--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកបន្តធ្វើឲ្យអស់លទ្ធភាព ដែលអាចធ្វើទៅបាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរសាក្សី ផាន វ៉ាន។ ខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីការពារលោក នួន ជា បន្តពីលោក អ៊ីនូហ្ស៊ី អេនឌី អំមិញ។ ខ្ញុំចង់ដឹងពីលោក ពីប្រវត្តិរបស់លោកបន្តពីថ្ងៃមុនមកតាំងពីព្រះរាជអាជ្ញាហ្នឹង សួររហូតមកដល់ថ្ងៃនេះ ខ្ញុំនៅមិនទាន់ច្បាស់ថាតើលោកបានចូលទៅក្នុងចូលទៅរៀប --

ធ្វើការជាមួយនឹងបដិវត្តន៍របស់ខ្មែរក្រហម តាំងពីអាយុលោកប៉ុន្មាន? ហើយនៅឆ្នាំណា?

**លោក ផាន វ៉ាន់៖**

**ផ៖** បាទ ដូចខ្ញុំបានជម្រាបខាងដើមហើយ ខ្ញុំចូលតាំងពីតូច ចូលតាមឪពុកម្ដាយ។ នេះដូចខ្ញុំបានជម្រាបពីខាងដើមអ៊ីចឹងបាទពីម្សិល។

**ស៖** ត្រង់ហ្នឹង បានខ្ញុំមិនច្បាស់ថា អាយុប៉ុន្មាន? ហើយចូលពីឆ្នាំណា? លោកចាំទេ?

[១១:៥៤:២១]

**ផ៖** ចាំមិនបានទេបាទ ចូលតាំងពីតូចម្ល៉េះ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង ឪពុកម្ដាយរត់ចូលព្រៃតាំងពីខ្ញុំនៅតូចៗបាទ។

**ស៖** ចុះលោកបានធ្វើជានីរសារជាមួយនឹងឪពុកលោកតាំងពីអាយុប៉ុន្មានមក?

**ផ៖** ខ្ញុំអត់យល់សំណួររបស់លោកសួរ នីរសារនៅក្នុងបដិវត្តន៍ ឬក៏នីរសារឪពុកផ្ទាល់បាទ?

**ស៖** លោកបានជម្រាបតុលាការពីមុនមកថា លោកតាំងពីចូលលោកបដិវត្តន៍មកលោកបានធ្វើបម្រើឪពុកលោកក្នុងឋានៈ -- មុនដំបូងបំផុតក្នុងឋានៈជានីរសារ។ ខ្ញុំចង់បញ្ជាក់ត្រង់ហ្នឹង ថាតើពីឆ្នាំណាមកលោកបានបម្រើជានីរសារជាមួយឪពុកលោក?

**ផ៖** ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង ខ្ញុំចាំឆ្នាំអីអត់បានទេ តែក្រោយទៅពីក្រោមទៅ ទៅនៅ១០៥វិញហ្នឹងខ្ញុំទៅធ្វើនីរសារគាត់តែម្ដងបាទ មុនសង្គ្រាមបន្តិចបាទ។ មុនចប់សង្គ្រាម ខ្ញុំអត់ទោស។

**ស៖** មុនចប់សង្គ្រាមហ្នឹង មានន័យថា យ៉ាងម៉េចមុន១៩៧៥ ឬក៏១៩៧៩?

**ផ៖** មុនឆ្នាំ១៩៧៥ បាទ។

**ស៖** រួចពីធ្វើនីរសារលោកមានមុខងារធ្វើអ្វីទៀតបន្ទាប់មក?**ផ៖** អត់មានទេបាទ ធ្វើនីរសាររហូតទាល់តែឪពុកខ្ញុំស្លាប់។

[១១:៥៦:៤៣]

**ស៖** លោកបានឆ្លើយជម្រាបតុលាការកន្លងរួចមកថា ទំនាក់ទំនងរវាងលោកជាមួយនឹងអ្នកស្រី អៀង ធីរិទ្ធ លោកបានបើកឡានជូនលោកស្រី អៀង ធីរិទ្ធ ហើយពេលនុ៎ងលោក នួន ជា ៗបានទំនាក់ទំនងតាមទូរសារទៅមណ្ឌល១០៥ -- តំបន់១០៥ ច្រើនតែលោក នួន ជា និយាយអំពីសន្តិសុខ។ សូមលោកបញ្ជាក់អំពីពាក្យថា “សន្តិសុខ” ដែលលោក នួន ជា បានធ្វើការទំនាក់ទំនងរវាង លោក នួន ជា ជាមួយនឹងតំបន់១០៥ តើ “សន្តិសុខ”ហ្នឹងមានន័យថាយ៉ាងម៉េច? ហើយកិច្ចការហ្នឹងធ្វើយ៉ាងម៉េច?

**ឆ៖** ពាក្យថា "សន្តិសុខ" ហ្នឹងជំនាន់ហ្នឹង មានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរ ហើយនិងកងទ័ពយួននៅតាមព្រំដែន ហ្នឹងពាក្យថា "សន្តិសុខ" ហើយបាទ។

**ស៖** លោកចម្លើយរបស់លោកនេះ ខ្ញុំនៅតែយល់មិនច្បាស់ថាតើ "សន្តិសុខ" ដែលលោក នួន ជា មានធ្វើការទំនាក់ទំនងជាមួយ១០៥ ហ្នឹង ផ្តោះទៅលើការវ៉ៃគ្នារវាងទ័ពខ្មែរនិងទ័ពយួន។ សន្តិសុខហ្នឹងធ្វើអីខ្លះលោកមានដឹងទេធ្វើអីខ្លះសន្តិសុខ? ពាក្យដែលលោកប្រើពាក្យ "សន្តិសុខ" នោះធ្វើអីខ្លះ?

**ឆ៖** ជំនាន់ហ្នឹង ការអនុវត្តជាក់ស្តែងហ្នឹង វាទាល់សម្រាយទាល់និយាយគ្នាវែងបាទ បានយល់ព្រោះសន្តិសុខហ្នឹង វាមានច្រើន ដូចលោកមានប្រសាសន៍សួរអំមិញហ្នឹងឯង គឺថាសណ្តាប់ធ្នាប់ផ្សេងៗព្រោះសន្តិសុខ វាមានការបាញ់សម្លាប់គ្នា វ៉ៃគ្នារហូតហ្នឹងជំនាន់ហ្នឹងនោះ ហើយខ្លះទៅកម្លាំងខ្លះអត់ឯកភាពជាមួយនឹងរត់ចូលព្រៃក៏ច្រើនជំនាន់ហ្នឹង។ ដល់អ៊ីចឹង អាហ្នឹងនិយាយពីសន្តិសុខទាំងអស់បាទរួចឯនេះ ខាងលើហ្នឹងណែនាំពីរឿងហ្នឹងឯង។ សូមបញ្ជាក់ប៉ុណ្ណឹង បាទ ចង់ច្បាស់សួរអ៊ីក៏គាត់ដឹងដែរនេះចង់បញ្ជាក់ប៉ុណ្ណឹង ហើយទាំងប្រវត្តិខ្ញុំអីហ្នឹង គាត់ដឹងច្បាស់ហើយ អ៊ំណាក៏ស្គាល់ខ្ញុំច្បាស់ដែរ ទាំងឪពុកខ្ញុំ តាំងពីខ្ញុំ។ នេះឲ្យសួរគាត់បញ្ជាក់ឲ្យច្បាស់ទៅ ហ្នឹងប៉ុណ្ណឹងបាទ។

[១២:០០:០៦]

**ស៖** អរគុណ។ នៅក្នុងឯកសារដែលមាននៅក្នុងតុលាការ មានទូរលេខច្រើនណាស់ ដែលមានទាក់ទងគ្នារវាងតំបន់១០៥ មកមន្ទីរ៨៧០។ តំបន់១០៥ហ្នឹងមានតាំងពីឈ្មោះ ឆាន តាំងពីឈ្មោះផ្សេងៗចំនួនច្រើន ហើយសារទូរលេខហ្នឹងមានលេខ១១ លេខ៣៣ លេខ៣ លេខច្រើនតទៅទៀត។ ទូរលេខទាំងអស់នេះៗ តើលោកសន្មតថាទូរលេខរបស់១០៥ ដែលទាក់ទងមកខាងប្រាំបីរយ -- មកមន្ទីរ៨០៧អ៊ីចឹងទេ? ពីព្រោះអីទូរលេខទាំងអស់នេះ លោកបានឃើញលោកមាននៅតុមុខលោកប្រហែលជាមានហើយ។ ឥឡូវខ្ញុំឧទាហរណ៍មួយថា ដូចទូរលេខ លេខ៣, ទូរលេខ លេខ០០ និងទូរលេខ លេខ២ អាហ្នឹង មួយចំនួនមានទូរលេខច្រើនតទៅទៀត។ លោកដឹងថា ទូរលេខនេះជាទូរលេខពីចេញពី១០៥ មែនទេ ឬក៏តំបន់១០៥ ទេ ឬក៏ទូរលេខយ៉ាងម៉េច? សូមលោកបញ្ជាក់ជូនតុលាការ។

[១២:០២:០០]

**ឆ៖** ទូរលេខនេះ តាមខ្ញុំមើលទម្រង់ហ្នឹងវាពិតបាទ អត់មានខុសទេ។ ខ្ញុំបញ្ជាក់តាមជូនតុលាការអ៊ីចឹងបាទ។ ឯឈ្មោះ ខ្ញុំមិនបានដឹងទេ ព្រោះកាលហ្នឹងបងខ្ញុំគាត់អ្នកបកសារជំនួសខ្ញុំ ដែលខ្ញុំចេញហើយកាលហ្នឹង ខ្ញុំអត់មានទាក់ទិនជាមួយបកសារទូរលេខទេ។ ខ្ញុំចង់បញ្ជាក់អ៊ីចឹង ប៉ុន្តែខ្លឹមសារ

ហើយនិងទម្រង់បែបបទអីហ្នឹង វាពិតប្រាកដហើយបាទ។

**ស៖** លោកបញ្ជាក់ថា ទូរលេខទាំងអស់នេះ ទម្រង់បែបបទគឺប្រាកដជារបស់ ចេញពីតំបន់ ១០៥ មែន។ ចុះលោកនៅមុខលោកហ្នឹង លោកមានឃើញទូរលេខទាំងប៉ុន្មានហ្នឹង មានខាងក្រោមនេះ ក្រោមសន្លឹកទូរលេខហ្នឹង មានអក្សរ ហើយនិងមានមានរូបនាគក្បាលនាគនៅហ្នឹង ហើយមានដាក់ខ្មែរតេឡា? លោកយល់ថាម៉េចអាហ្នឹង?

**ឆ៖** អត់មានខ្មែរតេឡាទេរបស់ខ្ញុំបាទ។

**លោក សុន អរុណ៖**

សូមលោកប្រធានខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! សូមអញ្ជើញលោក អាង ឧត្តម។

**លោក អាង ឧត្តម៖**

សូមអធ្យាស្រ័យលោក សុន អរុណ។ សូមគោរព លោកប្រធាន លោក លោកស្រីចៅក្រមអង្គសវនាការទាំងមូល។

ខ្ញុំបានទទួលរបាយការណ៍ពី*ខេសមេណេជ្ជឺ* របស់ខ្ញុំនៅបន្ទប់រង់ចាំខាងក្រោមថា លោក អៀង សារី លែងតាមដានសវនាការបានហើយ ចាប់ពីម៉ោង១១:៤៩:៥១វិនាទី មកម្ល៉េះ។ ហើយលោកគ្រូពេទ្យបានរាយការណ៍ផ្ទាល់មាត់ថា ចង្វាក់បេះដូងរបស់គាត់កំពុងដើរញាប់លើសពីធម្មតា ហើយកំពុងតែរៀបរបាយការណ៍ជូនមកតុលាការ។ ខ្ញុំបាទ ស្នើសុំតុលាការមេត្តាផ្អាកសវនាការសិនរហូតដល់មានរបាយការណ៍ពីគ្រូពេទ្យថាតើត្រូវបន្ត ឬមិនបន្ត។ សូមអរគុណ។

[១២:០៤:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ ដល់សមល្មមនឹងសម្រាកដែរហើយ លោកមេធាវី សុន អរុណ ចាំរៀបចំឲ្យស្រួលបួលទៅនូវសំណួរដែលលោកសួរហ្នឹង ចាប់បន្តសួរនៅពេលសមស្រប។

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងពីរ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅវេលាម៉ោងពីរ នៅរសៀលនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹង

រដ្ឋប្បវេណី អាហ្វុងសូ ដេនីស តាមរយៈប្រព័ន្ធសោតទស្សន៍ ដែលធ្វើពីប្រទេសបារាំង ដើម្បីបញ្ចប់នូវសក្ខីកម្មរបសគាត់។

លោក ផាន់ វ៉ាន ការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោក ដែលអាចបន្តធ្វើនៅរសៀលនេះ និងនៅថ្ងៃស្អែកទី១៤ ខែធ្នូ ឆ្នាំ២០១២ ទៀត។ ហើយដោយនៅរសៀលនេះ ទំនងជាអាចមានពេលសល់ពេលអាចធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោកបាន។ ដូច្នេះ អង្គជំនុំជម្រះតម្រូវឲ្យលោកនៅមានវត្តមាននៅ អ.វ.ត.ក នេះ នៅបន្ទប់រង់ចាំឬក៏ទីកន្លែងសមស្របណាមួយសម្រាប់បម្រុងទុកនៅរសៀលនេះ។ អាចមានពេលសមស្របគឺយើងបន្តស្តាប់សក្ខីកម្មរបស់លោក ដើម្បីបង្កើនល្បឿនឲ្យបានឆាប់ចប់ និងលោកអាចមានឱកាសវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញ ដើម្បីប្រកបមុខរបររកស៊ីប្រក្រតីភាពឡើងវិញ។

ហើយក្នុងករណីមួយទៀត គឺអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្ម នៅថ្ងៃស្អែកថ្ងៃសុក្រ ទី១៤ ខែធ្នូ ឆ្នាំ២០១២ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយមេធាវីប្រឹក្សាសាក្សីដូចគ្នាគឺសូមឲ្យមានវត្តមាននៅទីនេះ ជាការបម្រុងទុក ហើយនិងស្អែកអញ្ជើញមកជាមួយនឹងសាក្សី ដើម្បីអមសាក្សីនៅក្នុងការផ្តល់ចម្លើយបន្ត។

សូមអញ្ជើញលោកមេធាវី!

[១២:០៦:៤៣]

**លោក សុន អរុណ៖**

ក្នុងនាមកូនក្តី លោក នួន ជា ខ្ញុំជាមេធាវីសូមស្នើឲ្យលោក នួន ជា នៅពេលថ្ងៃត្រង់ អ៊ំ! បន្ទាប់ពីពេលសម្រាកទៅ សូមសម្រាកនៅបន្ទប់ខាងក្រោម ដោយមានមូលហេតុសុខភាព ឈឺក្បាល ឈឺចង្កេះ និងផ្លង់អារម្មណ៍ និងស្តាប់សវនាការមិនបាន។ ម្ល៉ោះហើយ សូមលះបង់សិទ្ធិនៅបន្ទប់ខាងលើ និងតាមស្តាប់សវនាការនៅខាងក្រោម ហើយខ្ញុំនឹងដាក់ជូននូវលិខិតស្នើនេះនៅពេលឥឡូវ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការ នៅរសៀលថ្ងៃនេះដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយយូរតាមដានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះបាន។

សំណើសុំរបស់លោក នួន ជា មានលក្ខណៈសមស្រប អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យ លោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្លាមៗនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬមានផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។

[១២:០៨:២៦]

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ហើយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងពីររសៀល ហើយចំណែកបញ្ហាដទៃទៀតអង្គជំនុំជម្រះនឹងជូននៅពេល -- ជូនដំណឹងនៅពេលសមស្រប នៅពេលបានទទួលព័ត៌មានផ្សេងៗពីលោកគ្រូ លោកវេជ្ជបណ្ឌិត ដែលទទួលបន្ទុកពិនិត្យថែទាំសុខភាពជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៩ នាទី ដល់ម៉ោង ១៤:០២ នាទី)*

[១៤:០២:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដូចដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីនិងសាធារណជនរួចហើយថា នៅរសៀលនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី អាហ្វុងសូ តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង ដែលនឹងបន្តការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដោយភាគីមេធាវីការពារក្តី។

**ប្រធានអង្គជំនុំ៖**

សួស្តីលោកស្រី អាហ្វុងសូ?

**លោកស្រី ដេនីស អាហ្វុងសូ៖**

ជម្រាបសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះលោកស្រី។ សូមលោកស្រីជ្រាប។

[១៤:០៣:៣៤]

**លោកស្រី ដេនីស អាហ្វុងសូ៖**

យល់ព្រម ខ្ញុំត្រៀមខ្លួនរួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី អាហ្វុងសូ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ សួស្តីអស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ ជាពិសេសអរុណសួស្តីលោកស្រី អាហ្វុងសូ។

នៅពេលនេះ គឺខ្ញុំមើលរូបភាពលោកស្រីតាមរយៈអេក្រង់មិនឃើញនោះទេ លោកស្រី អាហ្វុងសូ។ ដូច្នេះលោកប្រធាន តើអាចបញ្ចាំងរូបភាពដើមបណ្តឹងរដ្ឋប្បវេណីនៅលើអេក្រង់បានទេ?

**ប្រធានអង្គជំនុំ៖**

ប្រព័ន្ធដែលយើងអនុវត្តកាលពីម្សិលមិញ គឺដូចគ្នា នៅពេលដែលគាត់ឆ្លើយយើងនឹងអាចមើលឃើញគាត់។

**លោក ហ្វាស្តើ ប៉ៅ៖**

ខ្ញុំយល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបង្អង់បន្តិច ដោយសារមានបញ្ហាបច្ចេកទេស ចាំអ្នកបច្ចេកទេសរៀបចំសិន។

[១៤:០៥:១៤]

*(សម្រាកវយៈពេលខ្លី)*

[១៤:០៧:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អាចបន្តការតាំងសំណួរបានហើយ។

**លោក ហ្វាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្វាស្តើ ប៉ៅ៖**

**ស៖** លោកស្រី អាហ្វុងសូ អរុណសួស្តីលោកស្រី។ ខ្ញុំឈ្មោះ ហ្វាស្តើ ប៉ៅ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ហើយខ្ញុំនឹងសួរសំណួរលោកស្រីមួយចំនួននៅក្នុងរសៀលនេះ។ ប៉ុន្តែខ្ញុំនឹងសួរសំណួរទៅកាន់លោកស្រី នៅក្នុងព្រឹកនេះ បើគិតទៅលើប្រទេសរបស់លោកស្រីនៅទីនោះ។ លោកស្រី អាហ្វុងសូ មុនពេលចាប់ផ្តើមនីតិវិធី មុនពេលដែលធ្វើការសាកល្បងសំឡេងបច្ចេកទេសនោះ លោកស្រីបានបញ្ជាក់ថា លោកស្រីមានអារម្មណ៍ភិតភ័យនៅក្នុងថ្ងៃនេះ មានអារម្មណ៍ភ័យព្រួយ។ ហើយលោកស្រីកុំមានការព្រួយបារម្ភអី ខ្ញុំនឹងសួរត្រង់ៗតែម្តងលើបទពិសោធន៍លោកស្រីធ្លាប់ឆ្លងកាត់។ ប្រសិនបើលោកស្រីយល់ឃើញថា សំណួររបស់ខ្ញុំនេះមានលក្ខណៈស្មុគស្មាញ ឬធ្វើឲ្យលោកស្រីរំជួលចិត្តពេកនោះ គឺសូមឲ្យលោកស្រីជម្រាបមកកាន់ខ្ញុំ ដើម្បីឲ្យខ្ញុំសួរសំណួររំលងទៅសំណួរមួយទៀត។ តើលោកស្រី អាហ្វុងសូ ស្តាប់ឮអ្វីដែលខ្ញុំនិយាយបានច្បាស់ដែរឬទេ? យល់ច្បាស់ដែរឬទេលោកស្រី?

[១៤:០៩:២៥]

**លោកស្រី ដេនីស អាហ្វុងសូ៖**

**ឆ៖** លោកមេធាវីខ្ញុំយល់ច្បាស់ហើយ អ្វីដែលលោកមេធាវីបាននិយាយ។

**ស៖** នៅក្នុងថ្ងៃនេះ ជាដំបូងខ្ញុំសូមសួរសំណួរមួយចំនួនទៅកាន់លោកស្រី ពាក់ព័ន្ធទៅនឹងស្ថានភាពកើតឡើងនៅទីក្រុងភ្នំពេញ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់មកគឺខ្ញុំនឹងសួរអំពីស្ថានភាពដែលលោកស្រីរស់នៅក្រោយពេលថ្ងៃខែឆ្នាំនោះនៅតាមទីជនបទ។ ជាដំបូង នៅក្នុងទីក្រុងភ្នំពេញនៅមុនឆ្នាំ១៩៧៥ ខែមេសា។ លោកស្រីបានផ្តល់សក្ខីកម្មថា ក្នុងអំឡុងសម័យ លន់ នល់ មានជនភៀសខ្លួនច្រើនណាស់រត់ចូលមកទីក្រុងភ្នំពេញ។ តើលោកស្រីអាចបញ្ជាក់ចំនួនប៉ាន់ស្មានទេ មានជនភៀសខ្លួនរត់ចូលមកទីក្រុងភ្នំពេញនោះ ប្រហែលចំនួនប៉ុន្មានដែរ?

**ឆ៖** លោកចោទសំណួរនេះ ៣២ឆ្នាំកន្លងផុតទៅហើយ អ៊ីចឹងតួលេខជាក់លាក់នោះ ខ្ញុំមិនអាចផ្តល់ជូនបានទេ ក៏ប៉ុន្តែអ្វីដែលខ្ញុំអាចឆ្លើយបាន ឬខ្ញុំសង្កេតឃើញនៅសម័យនោះ គឺថារាល់ថ្ងៃ យើងឃើញជនភៀសសឹកមកជាជួរៗ ហើយកាលណោះនៅភ្នំពេញមានប្រហែលជា ប្រជាជនប្រហែលជា ២លាននាក់ ហើយមានជនភៀសខ្លួនមកនៅពេលចុងក្រោយបំផុតនោះ គឺថាដល់ពេលក្រោយប្រហែលចំនួនប្រហែលជា៣លាននាក់ ក៏ប៉ុន្តែខ្ញុំពុំមានឱកាសក្នុងការរាប់ឲ្យបានជាក់លាក់នោះទេ។ នេះគ្រាន់តែជាចំនួនប៉ាន់ស្មានតែប៉ុណ្ណោះ ប្រហែលជា៣លាននាក់ លោកមេធាវី។

[១៤:១១:២៥]

**ស៖** ខ្ញុំយល់លើចំណុចហ្នឹង ក៏ប៉ុន្តែនៅពេលដែលលោកស្រីនៅទីក្រុងភ្នំពេញក្នុងអំឡុងពេលនោះ តើលោកស្រីមានធ្លាប់ឃើញស្ថានភាពរបស់ជនភៀសខ្លួននោះមានស្ថានភាពយ៉ាងម៉េចដែរនៅពេលដែលចូលមកដល់ទីក្រុងភ្នំពេញ?

**ឆ៖** អ្នកទាំងនោះ មកចូលភ្នំពេញសឹងតែដៃទទេ ហើយគេបាត់របស់របរអស់ហើយ។ ហើយបាត់បងប្អូននៅតាមភូមិគេដែលគេចាកចេញនោះទៀតផង។ ហើយពួកគាត់ជាអ្នករៀបរាប់អំពីទុក្ខវេទនារបស់ពួកគាត់ដល់ពួកយើង។

**ស៖** នៅពេលដែលពួកគេមានមកដល់ទីក្រុងភ្នំពេញនោះ តើពួកគេទៅរស់នៅទីណាដែរទៅ?

**ឆ៖** អ្នកខ្លះ គឺមានបងប្អូននៅភ្នំពេញ អ៊ីចឹងបងប្អូនគេទទួលឲ្យស្នាក់នៅ ហើយអ្នកខ្លះដែលពុំមានញាតិសន្តាននោះ អ៊ីចឹងគេរស់នៅតាមចិញ្ចើមថ្នល់ បោះជំរំតាមចិញ្ចើមថ្នល់។ អ៊ីចឹងខ្ញុំសូមនិយាយម្តងទៀតថា ខ្ញុំមិនចាំមិនអំពីលក្ខខណ្ឌជីវិតរបស់ពួកគេទាំងអស់គ្នាទេ ពីព្រោះថា ខ្លួនយើងផ្ទាល់នោះគឺថាយើងភិតភ័យនឹងស្ថានភាពពេលនោះណាស់ ដោយមានគ្រាប់ផ្លោងធ្លាក់ចូលមក ហើយមានការច្បាំងគ្នាយ៉ាងខ្លាំងក្លានៅជុំវិញភ្នំពេញ។ អ៊ីចឹងយើងទាំងអស់គ្នានោះតក់ស្លុតខ្លាំងណាស់នៅពេលនោះនោះ។

[១៤:១៣:១៨]

**ស៖** នៅពេលដែលលោកស្រីរៀបរាប់ថា អ្នកទាំងអស់នោះរស់នៅតាមចិញ្ចើមផ្លូវ តាមផ្លូវនោះ គឺតាមផ្លូវនៅក្នុងទីក្រុងភ្នំពេញ ឬក៏នៅតាមផ្លូវក្នុងតំបន់ណាមួយជាក់លាក់?

**ឆ៖** លោកមេធាវី ត្រង់ចំណុចនេះ ខ្ញុំមិនអាចនិយាយឲ្យបានច្បាស់លាស់លើសនេះបានទេ អ្វីដែលអាចឆ្លើយបានហ្នឹង គឺថាអ្វីដែលខ្ញុំរៀបរាប់អម្បាញ់មិញហើយ។ អស់ត្រឹមប៉ុណ្ណឹងហើយ លោកមេធាវី។

**ស៖** លោកស្រី អាហ្វុងសូ ជាការពិតណាស់ ខ្ញុំគ្រាន់តែចង់ឲ្យលោកស្រីផ្តល់សក្ខីកម្មនូវអ្វីដែលលោកស្រីបានមើលឃើញដោយផ្ទាល់ភ្នែកតែប៉ុណ្ណោះ។ ក្នុងអំឡុងសម័យ លន់ នល់ រយៈពេល៥ឆ្នាំ ខ្ញុំដឹងថា លោកស្រីបានផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយនៅក្នុងទីក្រុងភ្នំពេញពីពេលមួយទៅពេលមួយ ហើយប្រហែលជាលោកស្រីបានឃើញជនភៀសខ្លួនដែលស្នាក់នៅតាមចិញ្ចើមផ្លូវ។ ដូច្នេះ បើសិនឃើញអ៊ីចឹងមែននោះ តើលោកស្រីឃើញជនភៀសខ្លួននោះស្នាក់នៅតាមចិញ្ចើមផ្លូវនៅពាសពេញទីក្រុងនេះតែម្តង ឬក៏នៅស្នាក់នៅតាមចិញ្ចើមផ្លូវម្តុំៗតាមកន្លែងជាក់លាក់?

[១៤:១៤:៤៧]

**ឆ៖** ទាក់ទងទៅនឹងជនភៀសខ្លួនបោះជំរំនោះ ខ្ញុំមិនអាចនិយាយអ្វីបាននោះទេ ប៉ុន្តែអ្វីដែលខ្ញុំអាចនិយាយបានគឺថា យើងបានជួបយោធានាយទាហាន លន់ នល់ ហើយពួកគេមានក្រុមគ្រួសារ ដែលជាជនភៀសខ្លួន ហើយពួកយោធាទាំងអស់នោះ គេឲ្យបងប្អូនគេស្នាក់នៅ។ ហើយនៅតាមផ្លូវមួយចំនួនមហាវិថីមួយចំនួន ឧទាហរណ៍ដូចជាមហាវិថីមុនីវង្សអី មានអ្នកមកបោះជំរំនៅ បោះតង់។ ក៏ប៉ុន្តែខ្ញុំៗមិនអាចផ្តល់ព័ត៌មានលម្អិតលើស្ថានភាពនេះបានទេ ប៉ុន្តែជនភៀសខ្លួនភាគច្រើននោះ មានបងប្អូនគេទទួលឲ្យស្នាក់នៅភ្នំពេញ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញលោកស្រីក៏បានជម្រាបអំពីវិបត្តិម្ហូបអាហារ និងស្រូវអង្ករផងដែរ ដូច្នេះតើលោកស្រីអាចជម្រាបបន្ថែម អំពីតម្លៃស្រូវ អង្ករក្នុងអំឡុងសម័យ លន់ នល់ ដែរឬទេ?

[១៤:១៦:១០]

**ឆ៖** លោកមេធាវីទាក់ទងនឹងតម្លៃជាក់លាក់នោះ ខ្ញុំទាល់តែមើលសៀវភៅខ្ញុំ ឥឡូវនេះខ្ញុំអាយុ ៦៨ឆ្នាំហើយ ខ្ញុំរៀបរាប់តម្លៃ ពេលនោះខ្ញុំនៅចាំ ក៏ប៉ុន្តែឆ្លើយប្រាប់លោកភ្លាមៗឥឡូវនេះ ខ្ញុំមិនអាចផ្តល់

តម្លៃច្បាស់លាស់បានទេ។ ប៉ុន្តែក្នុងសៀវភៅខ្ញុំនោះ ខ្ញុំបានប្រាប់ពីតម្លៃយ៉ាងច្បាស់លាស់។ ក្នុងសៀវភៅខ្ញុំនោះប្រហែលជាអាចមានតម្លៃខ្លះខុសដែរ ប៉ុន្តែឥឡូវនេះសួរខ្ញុំភ្លាមៗ ឲ្យឆ្លើយភ្លាមៗនោះ ខ្ញុំមិនអាចឆ្លើយបានទេ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំដឹងនោះ គឺដឹងថាស្បៀងនោះឡើងថ្លៃ។ ហើយពាណិជ្ជករចិននោះ គេលក់ដោយលួចលាក់។ ឧទាហរណ៍ដូចជាទឹកដោះគោខាប់អីគេនោះជាដើមនោះ តម្លៃនោះឡើងថ្លៃមែនទែន។ ឥឡូវនេះបើសិនជាលោកចង់សួរសំណួរនេះមកខ្ញុំទាល់តែឲ្យខ្ញុំអានសៀវភៅខ្ញុំ។ អ៊ីចឹងខ្ញុំ ពេលដែលអានហ្នឹងខ្ញុំអាចផ្តល់តម្លៃច្បាស់លាស់បាន។ ហើយខ្ញុំអាចផ្តល់ជូនតាំងពីអត្រាប្រាក់ផង កាលនោះខ្ញុំទទួលលុយប្រាប់បៀវត្សរ៍ជាលុយហ្វ្រង់។ ហើយៗកាលនោះយើងប្តូរលុយហ្វ្រង់មករៀល លុយរៀលដើម្បីទិញម្ហូបអាហារជាដើមនោះ។

**ស៖** សូមអរគុណ។ ការរៀបរាប់នេះគឺមានលក្ខណៈលម្អិតជូនខ្ញុំរួចហើយ ដូច្នេះលោកស្រីមិនចាំពិនិត្យមើលសៀវភៅរបស់លោកស្រី ដើម្បីជម្រាបបន្ថែមនោះឡើយ។ ខ្ញុំសូមដកស្រង់នូវចំណុចមួយចេញពីសៀវភៅរបស់លោកស្រីត្រង់ប្រធានបទនេះ។ សៀវភៅរបស់លោកស្រីនេះត្រូវបានគេបង្ហាញលេខយោងកាលពីម្សិលមិញរួចហើយ។ ឯកសារនេះមានលេខ E9/32.2.29។ ERN គឺលេខ 00768324 ចំពោះ -- សម្រាប់អ្នកបកប្រែ ខ្ញុំនឹងដកស្រង់សម្តីនេះជាភាសាបារាំង។

[១៤:១៨:៣៨]

លោកស្រី អាហ្វុងសូ នៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីបានសរសេររៀបរាប់ -- "អ្នកស្រីនិយាយអំពីការឡើងថ្លៃស្បៀងអាហារ ដូចជា ស្ករ ឬក៏វត្ថុធាតុដើមមួយចំនួន ដែលគេប្រើសម្រាប់ធ្វើទឹកដោះគោខាប់។ ហើយឡើងថ្លៃ សាំងក៏ឡើងថ្លៃដែរ...។ល។" ខ្ញុំសូមបញ្ចប់ការដកស្រង់សម្តី។ ខ្ញុំសូមអធ្យាស្រ័យចំពោះការបញ្ចេញភាសាបារាំងរបស់ខ្ញុំ។ នៅក្នុងចំណុចនេះក្នុងសៀវភៅរបស់លោកស្រី លោកស្រីបានរៀបរាប់ថា "តម្លៃនោះកើនឡើងយ៉ាង -- ឡើងថ្លៃយ៉ាងគំហុកលើស្បៀងអាហារ"។ នេះជាចំណុចដែលសរសេរក្នុងសៀវភៅរបស់លោកស្រី ហើយយើងនឹងយកមកដេញដោលពិភាក្សាគ្នានៅក្នុងថ្ងៃនេះ។

លោកស្រី អាហ្វុងសូ តើលោកស្រីបានដឹងដែរឬទេថា ជនភៀសខ្លួនដែលមករស់នៅ ស្នាក់នៅទីក្រុងភ្នំពេញតាមចិញ្ចើមផ្លូវនោះ តើអ្នកទាំងអស់នោះមានប្រាក់គ្រប់គ្រាន់ដើម្បីទិញគ្រឿងផ្គត់ផ្គង់ខ្លួន អាហារ ស្បៀងដែរឬទេនៅក្នុងខែមេសា ឆ្នាំ៧៥នោះ?

[១៤:២០:០២]

**ឆ៖** លោកមេធាវីខ្ញុំសូមនិយាយឡើងវិញ។ ខ្ញុំសូមជម្រាបថា ខ្ញុំពុំមានពេលៗទំនេរដើម្បីទៅស្រាវជ្រាវថា ជនភៀសខ្លួនត្រូវបានឲ្យស្នាក់នៅដោយបងប្អូន ឬក៏មិត្តភក្តិ ឬក៏គេមានចំណីអាហារគ្រប់គ្រាន់នោះទេ។ ក៏ប៉ុន្តែនៅសម័យនោះ របបលន់ នល់ ដែលទទួលបានជំនួយពីអាមេរិកាំងនោះ គេមានមធ្យោបាយគ្រប់គ្រាន់ដើម្បីជួយជនភៀសខ្លួនទាំងអស់នោះ។ ក៏ប៉ុន្តែខ្លួនខ្ញុំផ្ទាល់ ខ្ញុំពុំមានពេលក្នុងការគិតគូរអំពីបញ្ហាទាំងអស់នោះទេ ក្រុមគ្រួសារខ្ញុំនោះវាជាបញ្ហាមួយគ្រប់គ្រាន់ចំពោះខ្ញុំទៅហើយ។

**ស៖** សូមអរគុណលោកស្រី អាហ្វុងសូ។ លោកស្រីបានឆ្លើយច្បាស់លាស់រួចមកហើយ។ ខ្ញុំបានស្តាប់ឮលោកស្រីឆ្លើយថា លោកស្រីមិនបានដឹងអំពីស្ថានភាពស្នាក់នៅរបស់អ្នកជនភៀសខ្លួនយ៉ាងម៉េចនោះទេ។ ដូច្នេះ ខ្ញុំសូមចូលសួរទៅដល់ប្រធានបទមួយទៀត គឺស្ថានភាពនៃការថែទាំសុខភាពនៅក្នុងទីក្រុងភ្នំពេញ។ តើជាការពិតដែរឬទេ លោកស្រី អាហ្វុងសូ ដែលថារដ្ឋាភិបាលបារាំងបានធ្វើមាតុភូមិនិវត្តវេជ្ជបណ្ឌិតរបស់ខ្លួនទៅប្រទេសវិញ នៅក្នុងអំឡុងពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនោះ?

[១៤:២២:០០]

**ឆ៖** គឺចាប់ពីខែមេសា ឆ្នាំ១៩៧៥ គឺថាមុនខ្មែរក្រហមចូលមកមួយខែ យន្តហោះទាហានមកប្រទេសកម្ពុជានៅដើមខែមីនា ហើយគ្រូពេទ្យ ឬគ្រួសារទាំងអស់នោះដែលចង់ត្រឡប់ទៅស្រុកវិញនោះអាចឡើងជិះយន្តហោះនោះបាន។ ហើយបន្ទាប់មកមានយន្តហោះទី២ មកដល់នៅពាក់កណ្តាលខែមីនាដើម្បីដឹកជញ្ជូនអ្នកផ្សេងទៀតទាំងអស់ទៅវិញ។ ហើយយន្តហោះទី៣ មកដល់មុនពេលរបប លន់ នល់រលំ។ ហើយអ្នកដែលជាគ្រូបង្រៀន ទាហាន យោធាអី ជាគ្រូពេទ្យអីទាំងអស់ត្រូវចាកចេញពីប្រទេស -- ពីទីក្រុងភ្នំពេញនៅពេលនោះឯង។ តើច្បាស់លាស់ហើយឬនៅលោកមេធាវី?

**ស៖** ខ្ញុំស្តាប់បានច្បាស់ហើយ។ តើលោកស្រីដឹងផងដែរឬទេ? គិលានុបដ្ឋាយិកាជាជនជាតិបារាំងនោះមានធ្វើមាតុភូមិនិវត្តទៅវិញដែរឬទេ?

**ឆ៖** បើខ្ញុំមិនដឹងថាមានគិលានុប្បដ្ឋាយិកាជនជាតិបារាំងនោះទេ។ កាលនោះខ្ញុំធ្វើការនៅផ្នែកវប្បធម៌ ខ្ញុំមិនមែនធ្វើការនៅក្រសួងសុខាភិបាលនោះទេ។ ខ្ញុំធ្វើការផ្នែកវប្បធម៌។ ហើយពេលនោះខ្ញុំឃើញគ្រូចាកចេញពីភ្នំពេញ។ ឥឡូវសួរខ្ញុំថាតើមានគិលានុបដ្ឋាយិកាចេញ ឬក៏អត់នោះខ្ញុំមិនដឹងទេ ក៏ប៉ុន្តែដឹងថា មានពេទ្យខ្មែរនៅប្រទេសកម្ពុជា ក៏ប៉ុន្តែអ្នកណាដែលចង់ចេញ គឺថាអាចចេញមុនពេលដែលរឹករវនោះមកដល់បាន។

[១៤:២៤:០៦]

**ស៖** សូមអរគុណ។ លោកស្រី អាហ្វុងសូ តើលោកស្រីបានដឹងទេ មានអ្វីកើតឡើងដែរចំពោះប្រជាជនវៀតណាមដែលរស់នៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងសម័យលន់ នល់ នោះ?

**ឆ៖** ប្រជាជនវៀតណាមនៅភ្នំពេញក្នុងរបប លន់ នល់ មួយផ្នែកត្រូវបញ្ជូនទៅប្រទេសវៀត-ណាមវិញ ហើយមានភាគច្រើនដែលត្រូវបានសម្លាប់រង្គាលនៅតាមផ្លូវ។ ត្រង់ចំណុចនេះ ខ្ញុំអាចនិយាយរៀបរាប់ជូនលោកបាន។ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំនៅវត្ត តាមវត្តខ្ញុំឃើញគេសម្លាប់វៀតណាម ហើយម្ដាយខ្ញុំក៏ជនជាតិវៀតណាមដែរ ហើយយើងភ័យណាស់កាលណោះ គឺថាភ័យខ្លាចគេសម្លាប់យើង។ ឥឡូវនេះខ្ញុំមិនបានតាមដានទេ គាត់ពេលដែលគេធ្វើដំណើរទៅស្រុកខ្មែរ -- អ៎! ស្រុកវៀតណាមវិញនោះ ខ្ញុំមិនបានតាមទៀតទេ។ ម្ដាយខ្ញុំស្ថិតនៅស្រុកខ្មែរជាមួយខ្ញុំ។ ខ្ញុំអាចនិយាយរៀបចំជូនលោកបានតែត្រឹមប៉ុណ្ណេះឯង លោកមេធាវី។

**ស៖** សូមអរគុណលោកស្រី អាហ្វុងសូ។ នៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីបានសរសេររៀបរាប់អំពីប្រធានបទមួយនេះ។ ដូច្នេះ ខ្ញុំសូមអានចំណុចនេះចេញពីសៀវភៅរបស់លោកស្រី គឺសៀវភៅដែលមានលេខ E -- លេខសម្គាល់ដែរដដែល។ លេខ ERN គឺ 00678322, ខ្ញុំដកស្រង់ជាភាសាបារាំងឲ្យអ្នកបកប្រែជួយបកប្រែ។

[១៤:២៦:២៨]

(អានភាសាបារាំង៖) "វៀតណាម ហើយនិង -- ដែលមានដើមកំណើតខ្មែរ ហើយនិងវៀត-ណាមទទួលរងនូវការសម្លាប់រង្គាល ដែលចេញបញ្ជាដោយ លន់ នល់ ដែលជាប្រតិបត្តិការបោសសម្អាតប្រល័យពូជសាសន៍ ដែលគួរឲ្យភ័យខ្លាច ហើយនិងឃោរឃៅបង្ហូរឈាមនៃប្រវត្តិសាស្ត្រនៃប្រវត្តិប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៧០-៧៥ ដែល បន្ទាប់មកទៀត មានការសម្លាប់ដ៏ឃោរឃៅពីពួកខ្មែរក្រហមទៀត។ ពី -- វៀតណាមទាំងអស់ត្រូវបានគេចាប់ ហើយនិងប្រមូលផ្ដុំនៅខាងជើងទីក្រុង ហើយដោយនិយាយថា បញ្ជូនទៅវៀតណាមវិញ ប៉ុន្តែតាមពិតមិនមែននោះទេ។ ហើយការណ៍គេធ្វើដូច្នេះ គឺថាធ្វើដោយភ្លាមៗ ដោយគ្មានព្រៀងទុកមុន។ ហើយនៅ --" (បញ្ចប់ការអានភាសាបារាំង)

ហើយនៅក្នុងចំណុចមួយទៀតនោះលោកស្រីបានបន្តសរសេរថា៖

[១៤:២៧:២៩]

(អានជាភាសាបារាំង៖) "ខ្ទមជំរំនោះ ស្ថិតនៅ ក្ដៅ ហើយមានៗជំងឺអាសន្នរោគ មានអីជាដើម

ដោយសារក្តៅខ្លាំង ហើយអត់មានអនាម័យ។ ហើយបន្ទាប់មកទៀតមានការកាប់សម្លាប់រង្គាលដោយគ្រោងទុកជាមុន ហើយគេដឹកវៀតណាមទាំងអស់នេះតាមទូកទៅវៀតណាម ហើយគេសម្លាប់វៀត-ណាមទាំងអស់នេះបោះចូលក្នុងទឹក ហើយស្ត្រីទាំងអស់ត្រូវបានចាប់រំលោភ ហើយលោកសង្ឃ ឬក៏យាយជីទាំងអស់នោះត្រូវបានគេធ្វើទុក្ខបុកម្នេញជាដើម ហើយវត្តអារាមត្រូវគេបំផ្លិចបំផ្លាញដុតចោល។ (បញ្ចប់ការអានជាភាសាបារាំង)។

[១៤:២៨:១៧]

ខ្ញុំសូមបញ្ចប់ការដកស្រង់ចេញពីសៀវភៅរបស់លោកស្រី ដើម្បីកុំឱ្យមានការច្របូកច្របល់យល់ច្រឡំទៅលើ ទៅក្នុងចំណុចក្នុងសៀវភៅរបស់លោកស្រី។ ការធ្វើទុក្ខបុកម្នេញ គឺបានកើតឡើងក្នុងសម័យ លន់ នល់ តាមការរៀបរាប់នៅក្នុងសៀវភៅរបស់លោកស្រី។ តើពិតជាអ៊ីចឹងដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវហើយលោកមេធាវី។ ក៏ប៉ុន្តែសូមកុំភ្លេចថារបប លន់ នល់ គឺជាពួកអ្នកស្នេហាជាតិ ហើយពួកអ្នកដែលប្រឆាំងនឹងវៀតណាម ហើយគេឆ្លៀតឱកាសនិយាយថានៅក្នុងសហគមន៍វៀតណាមមានពួកវៀតកុងភៀសខ្លួន។ ហើយអ៊ីចឹងហើយបានគេធ្វើការកាប់សម្លាប់រង្គាលទៅលើពួកវៀតណាមនេះ។ អ៊ីចឹងពួកខាងនេះ សម័យ លន់ នល់ ពួកហ្នឹងសុទ្ធតែអ្នកពួកជាអ្នកស្នេហាជាតិនិយម អ្នកជាតិនិយម។ ហើយៗជំងឺនៅតាមវត្តដែលខ្ញុំឃើញនោះ គឺថាឃើញអ៊ីចឹង។ ខ្ញុំធ្លាប់ទៅឃើញដោយផ្ទាល់តែម្តង នៅតាមសាលា តាមវត្តអីហ្នឹង មានសាលាចិនជាដើម។

**សៈ** សូមអរគុណ។ នៅក្នុងអត្ថបទដកស្រង់អម្បាញ់មិញ ដែលខ្ញុំទើបតែអានជូនលោកស្រី លោកស្រីក៏បានរៀបរាប់អំពីវត្តដែលត្រូវបានគេដុតបំផ្លាញចោល។ ដូច្នេះ តើលោកស្រីនេះពិតជាបានឃើញផ្ទាល់ភ្នែកចំពោះការដុតបំផ្លាញវត្តចោលដែរឬទេ?

[១៤:៣០:២០]

**ឆ៖** ម្តាយខ្ញុំមានមិត្តភក្តិពីរ ជាយាយជី ដែលនៅក្នុងវត្តៗ នៅក្នុងខេត្តកំពង់ស្ពឺ វត្តនោះនៅក្នុងខេត្តកំពង់ស្ពឺ ហើយវត្តនុំងមានមិត្តភក្តិម្តាយខ្ញុំរស់នៅទីនោះ ហើយវត្តនោះហើយដែលគេបំផ្លិចបំផ្លាញដុតចោល ហើយដែលយាយជីទាំងអស់នោះ ត្រូវបានគេសម្លាប់រង្គាល។ ហើយនៅភ្នំពេញវិញ វត្តនៅភ្នំពេញមិនត្រូវបានបំផ្លិចបំផ្លាញ ឬក៏មានមនុស្ស ដែលត្រូវបានគេប្រហារជីវិតនោះទេ។

**សៈ** តាមដែលលោកស្រីដឹង ការសម្លាប់ដូនជី គឺកើតឡើង គឺត្រូវបានគេធ្វើឡើងដោយទាហាន លន់ នល់។ តើអ៊ីចឹងត្រឹមត្រូវមែនដែរឬទេ?

**ឆ៖** ខ្ញុំគិតថា ត្រឹមត្រូវហើយ ពីព្រោះថា នៅពេលនោះនៅក្នុងប្រទេសមានទាហាន លន់ នល់ ដែលឈរជើង ខ្មែរក្រហមមិនទាន់មកដល់ មិនទាន់មកកាន់ដណ្ដើមអំណាចបានទេ។ លោកចង់ឲ្យខ្ញុំនិយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៤:៣១:៣៩]

**សៈ** សូមអរគុណលោកស្រី។ ខ្ញុំសូមបន្តទៅចំណុចបន្ទាប់គឺប្រធានបទនិយាយអំពីការជម្លៀសពីទីក្រុងភ្នំពេញ គឺខ្ញុំនិយាយអំពីការជម្លៀសដោយផ្ទាល់។ ខ្ញុំមានសំណួរតែពីរបីសំណួរប៉ុណ្ណោះ ទាក់ទងនឹងការជម្លៀសនេះ ប៉ុន្តែនៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីបានរៀបរាប់អំពីទីក្រុងត្រូវបានគេបែងចែកជាបួន។ ប្រសិនបើលោកស្រីមិនប្រកាន់ ខ្ញុំអាចអានឲ្យលោកស្រីស្ដាប់ ប៉ុន្តែខ្ញុំអាចសួរលោកស្រីដោយផ្ទាល់ តើលោកស្រីចាំដែរឬទេថាទីក្រុង ត្រូវបានគេកាត់បំបែកទៅជាបួនផ្នែក ឬក៏បួនផ្នែកនោះ តើលោកស្រីចាំដែរឬទេ?

**ឆ៖** អ្វីដែលខ្ញុំចាំច្បាស់នោះ គឺថា អ្នកដែលរស់នៅផ្នែកខាងត្បូង មិនអាចទៅផ្នែកខាងជើងនៃទីក្រុងភ្នំពេញបានទេ។ ហើយគឺថា មានគេដាក់បរាស់គ្រប់ទីកន្លែង អ្នកដែលនៅខាងលិចក្រុងភ្នំពេញនោះ ត្រូវបានគេជម្លៀសទៅខាងលិចតែម្ដង គាត់អត់បានមកជួបខ្ញុំទេ។ ខ្ញុំក៏មិនអាចទៅជួបបានដែរ ខ្ញុំចង់ទៅស្ថានទូតបារាំង ដែលនៅខាងជើងទីក្រុងភ្នំពេញ ក៏ទៅមិនអាចៗទៅបានដែរ ដោយសារមានរនាំងបាំងគ្រប់ទីកន្លែង ហើយគេជម្លៀសយើងទៅតាមផ្នែកដែលយើងនៅ។ ខ្ញុំនៅផ្នែកខាងត្បូង អ៊ីចឹងគេជម្លៀសខ្ញុំចេញទៅទិសខាងត្បូងតែម្ដង។ តើខ្ញុំច្បាស់ -- និយាយច្បាស់ទេប៉ុណ្ណឹង លោកមេធាវី?

[១៤:៣៣:៤៧]

**សៈ** សូមអរគុណលោកស្រី អាហ្វុងសូ។ ខ្ញុំជួយក្នុងការរំឭកដល់លោកស្រីក្នុងការចងចាំ ដោយអានន្ទូវសម្រង់ពីសៀវភៅរបស់លោកស្រី ដែលនិយាយអំពីការបែងចែកទីក្រុងជាផ្នែកផ្សេងៗគ្នា គឺមាននៅលេខ ERN 00678330 ហើយខ្ញុំសូមធ្វើការដកស្រង់ជាភាសាបារាំង៖

(អានជាភាសាបារាំង៖) "ទីក្រុងត្រូវបានបែងចែកជាបួនផ្នែក ដោយមានរនាំងទាហាន។ អ្នកដែលនៅខាងផ្នែកខាងជើងត្រូវគេជម្លៀសចេញទៅផ្នែកខាងជើង អ្នកនៅខាងលិច អ៊ំ! នៅខាងខាងកើតត្រូវជម្លៀសទៅខាងកើត ហើយយើងកាលនោះយើងនៅខាងផ្នែកខាងត្បូង នៃទីក្រុងភ្នំពេញ" (បញ្ចប់ការអានជាភាសាបារាំង)។ សូមបញ្ចប់ការដកស្រង់។

លោកស្រី អាហ្វុងសូ តើអ្វីដែលខ្ញុំអានហ្នឹង គឺវាស្របទៅនឹងអ្វីដែលលោកស្រីបាននិយាយ

ពាក់ព័ន្ធទៅនឹងការបែងចែកទីក្រុង ដោយការដាក់រនាំងបាំងផ្លូវជាដើមនោះ គឺវា -- ឥឡូវនេះ ខ្ញុំសូមសួរលោកស្រី តើអ្វីដែលលោកស្រីរៀបរាប់ក្នុងសៀវភៅហ្នឹង គឺវាពិតដូចនឹងអ្វីដែលលោកស្រីបានឃើញនៅពេលនោះដែរឬទេ?

**ឆ៖** ខ្ញុំអាចនិយាយប្រាប់លោករឿងមួយ។ នៅពេលដែលខ្ញុំមិនអាចទៅខាងជើង ផ្នែកខាងជើងនៃទីក្រុងភ្នំពេញបាន ហើយកាលណោះខ្ញុំនៅខាងត្បូង អ៊ីចឹងគេបញ្ជូនខ្ញុំទៅទិសខាងត្បូង ខ្ញុំចង់ទៅផ្នែកខាងលិចដើម្បីជួបម្ដាយខ្ញុំ ខ្ញុំមិនអាចទៅបាន។ ដូច្នេះតាមហេតុការណ៍នេះ ខ្ញុំទាញសន្និដ្ឋានថា ទីក្រុងត្រូវបែងចែកយ៉ាងដូច្នេះឯង។ ក៏ប៉ុន្តែខ្ញុំពុំអាចទៅមុខ ពុំអាចស្រាវជ្រាវឱ្យបានជាក់លាក់ត្រង់ចំណុចនេះនោះទេ។ នេះគ្រាន់តែជាការទាញតាមការសន្និដ្ឋានដោយផ្ទាល់ខ្លួនរបស់ខ្ញុំតែប៉ុណ្ណោះ។ ដោយសារតែម្ដាយមីងរបស់ប្ដីខ្ញុំ ដែលនៅផ្នែកខាងលិច ដូចម្ដាយខ្ញុំដែរ ហើយគាត់នោះក៏ត្រូវបានគេជម្លៀសទៅទិសខាងលិចដែរ។ ហើយគាត់នុំងហើយអ្នកប្រាប់ខ្ញុំសព្វថ្ងៃនេះ គាត់ប្រាប់ខ្ញុំថា គាត់ទៅខាងលិចនុំងឯង ទិសខាងលិចនុំងឯង។ គាត់នៅរស់នៅឡើយទេ គាត់រស់នៅទីក្រុងប៉ារីស។ ខ្ញុំជួបគាត់នៅប៉ារីស ហើយឥឡូវគាត់នេះគាត់ឈឺធ្ងន់ណាស់។

[១៤:៣៦:២៧]

**ស៖** សូមអរគុណលោកស្រី អាហ្វុងស្វូ។ លោកស្រីបានឆ្លើយយ៉ាងលម្អិតរួចទៅហើយ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅដល់ពេលវេលាដែលលោកស្រីស្នាក់នៅតាមទីជនបទ។ នៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីបាននិយាយអំពី តាម៉ាន។ ក្នុងសៀវភៅរបស់លោកស្រី លោកស្រីបានហៅគាត់ថា ជាមនុស្សដែលតឹងតែង តើលោកស្រីអាចពន្យល់ថា តើលោកស្រីមានន័យយ៉ាងម៉េចដែលហៅថា គាត់ជាមនុស្សដែលតឹងតែងម៉ឺងម៉ាត់បែបនេះ?

**ឆ៖** តាម៉ាន ហ្នឹងគាត់មកដល់ជំរំនោះពេល២ឆ្នាំ ក្រោយពេលដែលយើងមកដល់ភ្នំពេញ។ យើងបានស្គាល់គាត់នៅពេលមួយ គឺថានៅពេលដែលនៅជំរំ១ទី៣ ហើយនៅសម័យនោះ គឺគាត់ហ្នឹងហើយជាអ្នកចាប់ផ្ដើមបោសសម្អាត ហើយនៅពេលគាត់មកដល់ភូមិនុំង គាត់ជាអ្នកធ្វើការបោសសម្អាត។

[១៤:៣៧:៥៧]

ខ្ញុំអាចរៀបរាប់រឿងប្អូនដប់បាន តាជិន, តាសុង, តាឃិន, តាលីន, តាម៉ាន, មានតាសុខ, តាឌឿន, តាជា, តាសឿង, តាស៊ុយ ដែលនៅក្រោយគេនោះ នៅក្នុងឡូទី គឺហ្នឹងអ្នកដែលយកប្ដីរបស់អ្នកក្បត់ទាំងអស់យកទៅនោះ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពី តាម៉ាន តើ តាម៉ាន មានតួនាទីផ្លូវការជាអ្វីដែរ? តើនៅក្នុងភូមិរបស់លោកស្រីហ្នឹងគាត់មានតួនាទី ឬក៏មានឋានៈអ្វីដែរ?

**ឆ៖** ខ្ញុំសូមមើលកំណត់ត្រារបស់ខ្ញុំបន្តិច ព្រោះថា ៣០ឆ្នាំបានកន្លងផុតទៅហើយ ខ្ញុំមិនអាចផ្តល់ព័ត៌មានច្បាស់លាស់បានទេ។ ខ្ញុំសរសេររៀបរាប់នៅក្នុងសៀវភៅរបស់ខ្ញុំ។ លោកមេធាវី បើសិនជាលោកមានឯកសារនេះ នោះសូមលោកអាន បើមិនអ៊ីចឹងទេ សូមលោកអនុញ្ញាតឲ្យខ្ញុំអានកំណត់ត្រារបស់ខ្ញុំ។

**ស៖** លោកស្រី អាហ្វុងសូ មិនមានបញ្ហាអ្វីទេ។ ខ្ញុំយល់អំពីការចង់ចាំរបស់លោកស្រីពីអង្គហេតុ។ ខ្ញុំអាចអានជូនលោកស្រីស្តាប់ ដែលផ្នែកមួយដែលលោកស្រីថា តាម៉ាន គឺជាមនុស្សបែបណា។

[១៤:៣៩:៣៤]

ខ្ញុំសូមធ្វើការដកស្រង់ជាភាសាបារាំង គឺនៅត្រង់លេខ ERN 00678338, ខ្ញុំសូមធ្វើការដកស្រង់ "ចំពោះយើងនៅភូមិ តាជិន, តាលឹម--

**អ្នកបកប្រែ៖**

លោកប្រធាន ខ្ញុំស្តាប់គាត់អានអត់បានទេ ព្រោះគាត់អានបារាំង ហើយស្តាប់សំឡេងអត់បានលោកប្រធាន។ សូមឲ្យគាត់អានម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវីអានៗម្តងទៀត អំមិញស្តាប់ ខាងអ្នកបកប្រែស្តាប់អត់បានទេ គាត់អត់យល់ទេ។ ឥឡូវលោកអានជាភាសាបារាំង តើៗមានបញ្ហាពាក់ព័ន្ធទៅនឹងបច្ចេកទេសបកប្រែយ៉ាងម៉េចទៅ? អាចប្តូរយ៉ាងម៉េច ដើម្បីសម្រួលឲ្យគាត់ ព្រោះគាត់អានជាភាសាបារាំង ហើយអ្នកបកនោះបកជាភាសាអង់គ្លេស វា--

[១៤:៤០:៥២]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន បញ្ហាលំបាកគឺថាដោយសារតែក្នុងភាសាបារាំងនោះ គឺមានពាក្យខ្មែរដែលខ្ញុំអានតាមអក្សរ ដូច្នេះដើម្បីជួយដល់អ្នកបកប្រែ គឺនិយាយអំពីសហការ ហើយនិងយុត្តិសាស្ត្រ --គឺសហករណ៍ និងយោធា។

**អ្នកបកប្រែ៖**

ចង់និយាយអម្បាញ់មិញពាក្យ សហការណ៍ឡូទី តាមពិតឈ្មោះ “សហាករណ៍ឡូទី”។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ហើយបន្ទាប់មកលោកស្រីបាននិយាយថា “តាម៉ាន គឺជាមនុស្ស -- តាម៉ាន គឺជាយោធាដែលគ្មានចេះអាណិតអាសូរគេទេ”។ នេះគឺជាអ្វីដែលលោកស្រីចងចាំទាក់ទងទៅនឹង តាម៉ាន តើមែនដែរឬទេ?

**លោកស្រី ដេនីស អាហ្វុងសូ៖**

**ឆ៖** លោកមេធាវីត្រឹមត្រូវហើយ នេះគឺជាការចងចាំដ៏អាក្រក់របស់ខ្ញុំពី តាម៉ាន នេះនៅពេលដែលខ្ញុំទៅដល់ -- ពេលដែលគាត់ទៅដល់នោះគឺថា ចាប់ផ្តើមមានមនុស្សបាត់ខ្លួន ហើយនិងការដាក់ទណ្ឌកម្ម។ ឧទាហរណ៍មានគេលួចអី ឬក៏យើងឃ្លាតចាកពីបន្ទាត់មាគ៌ាអង្គការអ៊ីចឹង គឺយើងទទួលទណ្ឌកម្មមាន តាតេង, តាស្វាយ, តាក្រាក់ ហើយពួកទាំងអស់នេះ សុទ្ធតែគេដកចេញពីតំណែង។ ហើយពួកគេនោះ ពួកគេនេះពីមុនមកជាៗអ្នកគ្រប់គ្រងភូមិទាំងអស់នោះ។ នេះបើសិនជាការចងចាំរបស់ខ្ញុំនោះច្បាស់លាស់។

[១៤:៤២:៥៨]

**ស៖** ដូច្នេះខ្ញុំ -- វាជាការត្រឹមត្រូវដែលយើងនិយាយថា តាម៉ាន គឺជាមេដឹកនាំសហករណ៍ គឺជាមេសហករណ៍ ដែលលោកស្រីបានរៀបរាប់ តើអ៊ីចឹងមែនទេ?

**ឆ៖** ត្រូវហើយលោកមេធាវី ត្រូវហើយ។ ខ្ញុំសូមទោស ខ្ញុំស្មានតែលោកមេធាវីបន្តសំណួរតទៅទៀត។ គាត់ហ្នឹងជាប្រធានសហករណ៍ត្រូវហើយ។

**ស៖** ហើយនៅក្នុងសៀវភៅរបស់លោកស្រីផងដែរ គឺពីរទំព័រចុះក្រោម នៅត្រង់ទំព័រ 00678 385 លោកស្រីបានសរសេរ ហើយខ្ញុំដកស្រង់ជាភាសាបារាំង “នៅពេល តាម៉ាន ជាប្រធានសហករណ៍ការដាក់ទណ្ឌកម្មសម្លាប់នោះកាន់តែកើតមានឡើង កាន់តែកើនឡើង”។ តើវាជាការត្រឹមត្រូវដែរទេ នៅពេលដែល តាម៉ាន ក្លាយជាប្រធានសហករណ៍នោះ? គឺមនុស្សដែលត្រូវគេយកទៅសម្លាប់នោះ គឺមានចំនួនច្រើន គឺមានការកើនឡើងច្រើន គឺកើនឡើងច្រើនជាងពេលមុនទៅទៀតនោះ តើត្រឹមត្រូវដែរឬទេ?

[១៤:៤៤:៣៣]

**ឆ៖** លោកមេធាវី ខ្ញុំឆ្លើយទៅនឹងសំណួរមុនរបស់លោកអម្បាញ់មិញនេះអ៊ីចឹងហើយ គឺថា

ពេល តាម៉ាន ហ្នឹងមកដល់សហករណ៍ហ្នឹង មានការបាត់ខ្លួនជាច្រើន និងការប្រហារជីវិតជាច្រើន ឬក៏ការដាក់ទណ្ឌកម្មក៏ច្រើនជាងមុនដែរ។ ការធ្វើទារុណកម្មជាដើម។ តើចម្លើយរបស់ខ្ញុំនេះគ្រប់គ្រាន់ទេចំពោះលោក?

**ស៖** សូមអរគុណ។ គឺថាចម្លើយលោកស្រីគ្រប់គ្រាន់ហើយសម្រាប់ពេលនេះ។ លោកស្រីក៏បានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺឯកសារ D199/15 ហើយមានលេខ 00346936 ហើយលោកស្រីបានផ្តល់សក្ខីកម្មថា "គឺនិយាយអំពីមេស្រុក ដែលលោកស្រីនិយាយជាភាសាអង់គ្លេសថា៖ មេស្រុកដ៏អស្ចារ្យមួយនេះបានចាត់តាំង បានវាយតម្លៃថាខ្ញុំជាអ្នកលួចស្រូវអង្ករក៏ប៉ុន្តែគាត់បានដោះលែងខ្ញុំទៅវិញ។ ហើយអ្នកនៅក្រោមបង្គាប់របស់គាត់គឺមេភូមិ" សូមបញ្ចប់ការដកស្រង់។ តើលោកស្រីចាំដែរឬទេថា មេស្រុកដែលបានដោះលែងលោកស្រីនោះ តើលោកស្រីអាចចាំឈ្មោះគាត់ដែរឬទេ?

[១៤:៤៦:៣៦]

**ឆ៖** ខ្ញុំចាំច្បាស់ណាស់អំពីហេតុការណ៍នេះ ខ្ញុំមិនមែនលួចត្រឡាចទេ ខ្ញុំលួចត្រប់។ គេនាំខ្ញុំទៅទិសខាងលិច អ៊ីចឹងបានន័យថានាំទៅងាប់។ កាលនោះគេ បើសិនខ្ញុំរៀបរាប់ឲ្យលម្អិតនោះ កាលនោះខ្ញុំចាំ ទាហានពីរបីនាក់គេដឹកខ្ញុំតាមទូក ហើយនាំខ្ញុំទៅភូមិមួយទៀត។ ហើយនៅពេលនោះ ខ្ញុំពន្យល់ពីស្ថានភាពរបស់ខ្ញុំទៅមេភូមិ ហើយមានគណៈស្រុកគេជិះកង់មកដល់ ខ្ញុំគិតថា គណៈស្រុក នោះឈ្មោះតាយិន ហើយគាត់ក៏ចាប់ផ្តើមសួរខ្ញុំសុំអត្តសញ្ញាណរបស់ -- អត្តសញ្ញាណប័ណ្ណរបស់ខ្ញុំថា ខ្ញុំបានធ្វើអីហេតុអីបានខ្ញុំលួច? ខ្ញុំឆ្លើយនឹងសំណួរគាត់ទាំងអស់។ ខ្ញុំឆ្លើយថា "ខ្ញុំលួចដោយសារខ្ញុំឃ្លាន" ខ្ញុំថា "មិត្តខ្ញុំលួចព្រោះតែខ្ញុំឃ្លាន"។ គាត់ឆ្លើយមកវិញថា "យើងទាំងអស់គ្នា យើងក៏ឃ្លានដូចគ្នាដែរ ហេតុអីក៏យើងមិនលួច?" ហើយនៅពេលនោះនៅក្នុងខ្ទមមួយនៅក្នុងចង្ក្រានបាយនៃខ្ទមមួយ ប្រពន្ធគាត់ និងកូនចៅគាត់ កូនប្រធានភូមិនោះគេកំពុងតែហូតបាយត្រីសាច់អីគ្រប់គ្រាន់ ហើយពេលខ្ញុំនោះ ហៀរទឹកមាត់ឃើញគេ ខ្ញុំប្រាប់គេថាខ្ញុំឈប់លួចហើយ។ ហើយគេក្រោយមកសួរខ្ញុំ គេសួរថា "អ្នកឯងបារាំងអ៊ីចឹងអ្នកឯងសប្បាយចិត្តនៅទីនេះទេ? តើអ្នកចង់ទៅស្រុកបារាំងវិញទេ?" ខ្ញុំថា "អានេះអាស្រ័យលើអង្គការបើអង្គការចង់ឲ្យខ្ញុំទៅស្រុកខ្ញុំវិញ ខ្ញុំធ្វើតាម"។ គេសួរថា "តើការងារនៅទីនេះអ្នកឯងសប្បាយចិត្តនឹងធ្វើការទេ?" ខ្ញុំឆ្លើយថា "ខ្ញុំសប្បាយចិត្តនឹងធ្វើការនៅទីនេះណាស់"។ ខ្ញុំនិយាយប្រាប់គេនូវអ្វីដែលគេចង់ឮ ប្រសិនជាខ្ញុំឆ្លើយបញ្ច្រាសនោះប្រហែលជាឥឡូវនេះខ្ញុំគ្មានវត្តមានមកឆ្លើយរៀបរាប់រឿងនេះប្រាប់

លោកមេធាវីនោះទេ។ នេះជាស្ថានភាពខ្ញុំនៅពេលនោះលោកមេធាវី។

[១៤:៤៩:១៥]

**ស៖** ខ្ញុំយល់អំពីបញ្ហានេះលោកស្រី។ សូមអរគុណចំពោះការចែករំលែកនូវរឿងរ៉ាវរបស់លោកស្រីមកខ្ញុំ។ ផ្អែកតាមបទពិសោធន៍របស់លោកស្រី តើវាជាការពិតដែរឬទេដែលថាមនុស្សដូចជា តាម៉ាន នោះ ដែលជាប្រធានសហករណ៍ ហើយនិងមនុស្សដូចជា តាឃិន អាចធ្វើការសម្រេចអំពីបញ្ហាស្លាប់រស់របស់មនុស្ស ព្រោះដូចដែលគេបានសម្រេចចំពោះលោកស្រី ថាតើលោកស្រីត្រូវស្លាប់ ឬមួយក៏រស់ចំពោះអ្វីដែលលោកស្រីបានធ្វើ។ តើវាជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** លោក--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក អេម៉ានូអ៊ែល ហ្សាកូមី៖**

លោកប្រធាន ខ្ញុំសូមឲ្យសហភាតាខ្ញុំនេះបញ្ជាក់ពីរយៈពេលច្បាស់លាស់ ហើយនិងព្រឹត្តិការណ៍ដែលគាត់យោង។ ព្រោះថាយើង -- យូរហើយ យើងមិនបានកាត់ផ្តាច់គាត់ទេ ប៉ុន្តែគាត់និយាយអំពីភូមិឡូទី។ តង់នេះថា អង្គហេតុកើតមានឡើង កើតឡើងក្រោយឆ្នាំ៧៦ទេ ដូច្នេះមិនចូលនៅក្នុងវិសាលភាពនៃការជម្រះក្តីយើងនេះទេ។ ដូច្នេះខ្ញុំសូមឲ្យគាត់បញ្ជាក់បន្តិច ទាក់ទងនឹងចំណុចនេះលោកប្រធាន។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណ។ សូមអរគុណមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ទៅលើពេលវេលាដែលខ្ញុំអំមិញធ្វើការសាកសួរសំណួរពាក់ព័ន្ធទៅនឹងរយៈពេលដែលមានលក្ខណៈទូលំទូលាយ។ ប្រសិនបើលោកស្រី អាហ្វុងសូ អាចឆ្លើយបាន។ ខ្ញុំចង់និយាយអំពីពេលវេលាដែលគាត់ស្នាក់នៅជនបទ គឺបន្ទាប់ពីការជម្លៀសពីទីក្រុងភ្នំពេញតាមផ្លូវរហូតដល់ពាក់កណ្តាលឆ្នាំ៧៧។ នេះគឺជារយៈពេលដែលគាត់ស្នាក់នៅជនបទ ហើយនិងបានដឹង បានឮ អំពីការពិតជាក់ស្តែងនានានៃជីវភាពរស់នៅតាមទីជនបទ។

ខ្ញុំគ្រាន់តែចង់ឲ្យគាត់ផ្តល់នូវការរៀបរាប់អំពីបទពិសោធន៍របស់គាត់នៅពេលនោះ ហើយខ្ញុំយល់ថាដើមបណ្តឹងរដ្ឋប្បវេណីមិនបានឮសំណួររបស់ខ្ញុំ។ ដូច្នេះ ខ្ញុំរីករាយនឹងធ្វើការចោទសំណួរសាជាថ្មីឡើងវិញ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោកស្រី អាហ្សុងសូ តើវាជាបទពិសោធន៍របស់លោកស្រីផ្ទាល់ដែរឬទេ នៅពេលដែលលោកស្រីស្នាក់នៅតាមទីជនបទចន្លោះពីឆ្នាំ៧៥ រហូតទៅដល់ឆ្នាំ៧៧? ដែលនៅពេលនោះមនុស្សដូចជា តាយិន ហើយនិង តាម៉ាន មានសិទ្ធិសម្រេចអំពីអ្នកណាត្រូវរស់ អ្នកណាត្រូវស្លាប់។ តើវាជាការពិតដែរឬទេ?

[១៤:៥២:៥៣]

**លោកស្រី ដេនីស អាហ្សុងសូ៖**

**ឆ៖** លោកមេធាវី ដើម្បីឆ្លើយតបទៅនឹងសំណួររបស់គាត់ តាយិន នោះ ខ្ញុំឃើញគាត់ជួបគាត់តែម្តងទេ គឺថានៅពេលដែលខ្ញុំបានប្រព្រឹត្តកំហុសហ្នឹង។ ប៉ុន្តែ តាម៉ាន វិញ គឺថាគាត់នៅលើកោះនោះរហូត ជាមួយយើងរហូត។ តាម៉ាន នេះមានសិទ្ធិសម្រេចទាំងអស់ ហើយអ្វីដែលគាត់សម្រេចនោះ គឺថាតាំងនាមឲ្យអង្គការ។ គាត់ថាអង្គការចេញបញ្ជា អ្នកឯងមិនដើរតាមមាគ៌ាអង្គការ ដូចថាមិនត្រូវលួច មិនត្រូវកុហក មិនត្រូវធ្វើនេះ មិនត្រូវធ្វើនោះ។ បើសិនជាអ្នកឯងប្រាសចាកពីមាគ៌ានេះ អ្នកឯងនឹងបាត់ខ្លួន។ ខ្ញុំអាចរៀបរាប់ជូនលោកបានតែត្រឹមប៉ុណ្ណេះឯង។

**ស៖** សូមអរគុណ។ ចម្លើយរបស់លោកស្រី ធ្វើឲ្យខ្ញុំឈានទៅដល់សំណួរមួយទៀត។ កាលពីម្សិលមិញលោកស្រីនិយាយអំពីបញ្ហានេះដែរ ហើយខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងប្រធានបទមួយនេះ។ តើលោកស្រីអាចពន្យល់បានដែរឬទេ ថាតើនៅពេលនោះលោកស្រីយល់ឃើញយ៉ាងម៉េចដែរ ថាអង្គការហ្នឹងគឺជាអ្វីដែរ?

[១៤:៥៤:២០]

**ឆ៖** ខ្ញុំឮពាក្យអង្គការលើកទី១នោះ កាលនុ៎ងខ្ញុំមិនដឹងថាមានន័យថាម៉េចទេ ខ្ញុំមិនដឹងថាអង្គការជាអ្នកណានោះទេ។ កាលនោះ ខ្ញុំស្មានថាជាមនុស្សម្នាក់ដ៏ជាក់លាក់ ក៏ប៉ុន្តែបន្តិចម្តងៗនៅពេលខ្ញុំទុក្ខវេទនា ឬក៏ថាពេលដំណើរ -- ធ្វើដំណើរទៅឋាននរកនោះ ហើយដោយគេនិយាយរៀបរាប់ប្រាប់យើងទាំងអស់មកនោះ ពេលនោះហើយបានយើងយល់ថាអង្គការ គឺជាអង្គការ ឬក៏បក្ស។ មិនដឹងថាបកប្រែយ៉ាងម៉េចទេ សព្វថ្ងៃនេះនោះ។ ក៏ប៉ុន្តែអ្នកដែលជាប្រធានភូមិ ដែលដឹកនាំយើងកាលនោះ ដែលធ្វើបាបយើងនៅពេលនោះ អ្វីដែលគេនិយាយនោះសុទ្ធតែនិយាយជួសមុខឲ្យអង្គការទាំងអស់។ ពួកគេនៅគ្រប់គ្រងយើងនោះគឺថា គេប្រើតែពាក្យ “អង្គការ” ដែលថាឈ្មោះសម្ងាត់នោះ ហើយមិនដឹងថា

អ្នកណាទេជាអ្នកដឹកនាំអង្គការ អ៊ីចឹងកាលនោះយើងមិនដឹងទេ មិនដឹងថាអង្គការហ្នឹងជាអ្វីទេ។

[១៤:៥៥:៣០]

**ស៖** សូមអរគុណលោកស្រី។ កាលពីម្សិលមិញ លោកស្រីបានផ្តល់សក្ខីកម្មថា លោកស្រីក៏បានផ្តល់សក្ខីកម្មទៅដល់ការជំនុំជម្រះ នៅឆ្នាំ១៩៧៩ ផងដែរ ហើយលោកស្រីបានផ្តល់សក្ខីកម្មថា លោកស្រីត្រូវបានគេជំរុញឲ្យនិយាយការពិត។ តើលោកស្រីដឹងដែរឬទេថា ឯកសារនៃការជំនុំជម្រះនេះគឺមានបន្ត -- គឺនៅមានរហូតមកដល់ថ្ងៃនេះ រួមបញ្ចូលទាំងសក្ខីកម្មដែលលោកស្រីបានផ្តល់នៅពេលនោះដែរ គឺមានរក្សារហូតមកដល់ថ្ងៃនេះ។

**ឆ៖** រហូតដល់ពីរបីឆ្នាំមុននេះ ខ្ញុំមិនដឹងថា មានការកាត់ក្តីផងទេ គឺថាប៉ុន្មានឆ្នាំចុងក្រោយ -- ព្រោះខ្ញុំអត់ដឹងថា នៅសល់ឯកសារដែលកាត់ទោសនៅឆ្នាំ៧៩ នោះទេ។ ឯកសារដែលលោកប្រើនៅថ្ងៃនេះនោះ ខ្ញុំទើបតែបានទទួលបានតាមរយៈមេធាវីរបស់ខ្ញុំ គឺថា ជូល្យាន រីវ៉េ ថ្ងៃនេះតែប៉ុណ្ណោះ។ គឺថាគាត់ឲ្យឯកសារហ្នឹងខ្ញុំសប្តាហ៍មុន ប៉ុន្តែឥឡូវខ្ញុំមិនមានឯកសារហ្នឹងនៅក្នុងដៃនោះទេ ហើយការបកប្រែជាភាសាអង់គ្លេសក៏គ្មានដែរ។ ខ្ញុំឃើញថា ភាសាបារាំងនៅក្នុងឯកសារហ្នឹងមានកំហុសច្រើន មានកំហុសអក្ខរាវិរុទ្ធ វេយ្យាករណ៍ជាដើម។

**ស៖** តើលោកស្រីអាចប្រាប់បានដែរទេថា ពេលណាដែលលោកស្រីបានអានឯកសារទាំងអស់នោះ គឺឯកសារពាក់ព័ន្ធការជំនុំជម្រះជម្រះឆ្នាំ៧៩ នោះ?

**ឆ៖** លោកមេធាវី ខ្ញុំបានប្រាប់ហើយថា ទើបតែមួយសប្តាហ៍មុននេះទេដែលខ្ញុំបានមើលឯកសារហ្នឹង ខ្ញុំអត់មានពេលទៅស្រាវជ្រាវពីមុនទេ។ ពេលខ្ញុំមកដល់ប្រទេសបារាំង នៅចុងឆ្នាំ៧៩ នោះខ្ញុំបាត់បង់អ្វីអស់ហើយ ហើយខ្ញុំគ្មានពេលទៅត្រឡប់ទៅអតីតកាលវិញទេ ហើយខ្ញុំមិនបានទៅស្រាវជ្រាវនៅក្នុងបណ្ណសារនោះទេ។ ទើបតែសប្តាហ៍មុននេះទេ ដែលលោកមេធាវី ជូល្យាន រីវ៉េ បានផ្តល់ឯកសារនេះមួយច្បាប់មកឲ្យខ្ញុំ។

[១៤:៥៨:១៧]

**ស៖** សូមអរគុណ។ ខ្ញុំចង់អានជូនលោកស្រីនៅឃ្លាមួយនូវសក្ខីកម្មរបស់លោកស្រីនៅសវនាការនោះ ហើយខ្ញុំចង់សួរលោកស្រីដើម្បីឲ្យលោកស្រីបញ្ជាក់ឲ្យច្បាស់ថាតើនោះ គឺជាអ្វីដែលលោកស្រីបានប្រើសក្ខីកម្មនៅពេលនោះដែរឬក៏អត់? ព្រោះថាតាមភាសាបារាំង គឺ -- តាមអ្វីដែលលោកស្រីនិយាយគឺថាជាភាសាបារាំង គឺមានការខុសច្រើន។ ដូច្នេះ ខ្ញុំចង់ដកស្រង់ពីឯកសារ E3/2144R

ព្រោះថា -- ហើយសៀវភៅនោះ គឺគេហៅថា "ប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ការជំនុំជម្រះ ប៉ុល ពត និង អៀង សារី"។ ហើយឃ្លានោះគឺមានលេខ ERN 00190592 ហើយនៅទំព័រនោះផងដែរ លោកស្រីបានបញ្ជាក់ថា តាមឯកសារនេះ ខ្ញុំសូមដកស្រង់ "នៅពេលដែលយើងទៅដល់កោះមួយដែលយើងដឹង-- ទើបយើងដឹងថាអង្គការគឺជាអ្វី? អង្គការមានន័យថារដ្ឋាភិបាល។ មនុស្សទាំងអស់គ្នា គឺមានសិទ្ធិគោរពដើម្បីធ្វើការគ្រប់គ្រង ហើយអ្នកដឹកនាំអាចហៅថាជា "អង្គការ"។ ដូច្នេះ អង្គការគឺជាអ្វីៗទាំងអស់"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ តើវាជាការត្រឹមត្រូវដែរឬទេ ថានេះគឺជាអ្វីដែលលោកស្រីបានផ្តល់សក្ខីកម្ម នៅក្នុងឆ្នាំ១៩៧៩ ដែលថាមនុស្សគ្រប់គ្នាគឺមានសិទ្ធិក្នុងការតាំងខ្លួនថាជាអង្គការនោះ?

**ឆ៖** ត្រឹមត្រូវហើយលោកមេធាវី កាលណោះខ្ញុំនិយាយអ៊ីចឹងមែន។ ប៉ុន្តែប្រហែលជាមានកំហុសបកប្រែ ព្រោះថាពាក្យថា "អង្គការ" នេះមិនអាចបកប្រែថា "រដ្ឋាភិបាល"ទេ។ អាចថា បកប្រែថាជាពាក្យថា "*អ័រហ្គានីសាស្យុង*" ឬអង្គការនោះ ឬក៏បក្សជាដើម។ អ៊ីចឹងការបកប្រែពីខ្មែរទៅបារាំងនេះ ប្រហែលជាមិនត្រូវទេ។

[១៥:០០:៤៨]

**សៈ** ប្រសិនបើខ្ញុំសួរលោកស្រីនៅសំណួរដដែលប៉ុន្តែប្រើប្រាស់វិធីសាស្ត្រផ្សេង តើវាជាការពិតដែរឬទេដែលថា អ្នកដែលមានអំណាចនៅក្នុងភូមិអាចអះអាងថា ពួកគាត់និយាយតាងនាមឲ្យអង្គការ។ តើអាចដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកមេធាវី។ ខ្ញុំសូមនិយាយឡើងវិញដដែល អ្នកដែលប្រធានជំរំ ប្រធានភូមិទុំងសុទ្ធតែនិយាយជួសមុខឲ្យអង្គការ ហើយធ្វើសេចក្តីសម្រេចជំនួសអង្គការ ពេលដែលគេចង់ឲ្យយើងធ្វើការច្រើនជាងមុននោះ គេថាអង្គការអ្នកឲ្យធ្វើអ៊ីចឹង។ នៅពេលដែលគេឲ្យយើងទៅប្រមូលស្រូវដែលនៅសល់នោះគេថា "អង្គការត្រូវ ត្រូវការ" ពេលដែលគេចង់ឲ្យបញ្ជូនកូនយើងទៅធ្វើការនៅកន្លែងផ្សេង គេថា "អង្គការអ្នកឲ្យធ្វើអ៊ីចឹង"។ ហើយអ៊ីចឹងសូមពន្យល់ប្រាប់ខ្ញុំផងថា សព្វថ្ងៃនេះអង្គការនេះមានន័យយ៉ាងម៉េច? ហើយខ្ញុំនឹងក៏ចង់ដឹងដែរ ឥឡូវហ្នឹងថា អង្គការហ្នឹងជាអ្នកណា? ជាអង្គការ ជា *អ័រហ្គានីសាស្យុង* ឬក៏ជាអ្វីមួយ? អ៊ីចឹងសូមជួយ -- លោកមេធាវីជួយប្រាប់ខ្ញុំផង។

[១៥:០២:១២]

**សៈ** ខ្ញុំគិតថាខ្ញុំគួរតែអាចពន្យល់លោកស្រី ក៏ប៉ុន្តែមិនមែនជាតួនាទីរបស់ខ្ញុំត្រូវពន្យល់លោកស្រីនោះទេ ក៏ប៉ុន្តែយើងត្រូវផ្តោតនៅការជំនុំជម្រះនេះលើបញ្ហានេះឯង។ លោកស្រីបានពន្យល់អំពីសកម្ម-

ភាពរបស់ តាម៉ាន នៅក្នុងភូមិរបស់លោកស្រី។ ផ្អែកតាមបទពិសោធន៍របស់លោកស្រីធ្លាប់រស់នៅឆ្លងកាត់ក្នុងភូមិរបស់លោកស្រីជាមួយនឹង តាម៉ាន។ តើវាត្រឹមត្រូវដែរឬទេ ដែលយើងអាចនិយាយថាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅក្នុងទីក្រុងភ្នំពេញមិនដឹងថា តាម៉ាន នេះចេញបញ្ជាអ្វីឲ្យលោកស្រីនេះធ្វើការងារអ្វីខ្លះនោះទេ នៅក្នុងភូមិរបស់លោកស្រី នៅពេលដែល តាម៉ាន នេះនិយាយសំដៅថាអង្គការនោះ?

**ប្រធានអង្គជំនុំ៖**

ដើម្បីបណ្តឹងរដ្ឋប្បវេណីលោកស្រី អាហ្វុងសូ កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:០៣:៣០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សំណួរនេះហាក់ដូចជាហួសពីអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីអាចបញ្ជាក់បាន។ គាត់បានបញ្ជាក់តាំងពីដំបូងហើយថា គាត់មិនដែលឃើញអ្នកដែលតំណាងឲ្យអង្គការនៅថ្នាក់មជ្ឈិមនោះទេ ជាពិសេសគឺជនជាប់ចោទនោះ គាត់មិនដែលឃើញទេ។ ហើយបើសួរគាត់ថា តើ តាម៉ាន នេះអាចសម្រេច ហើយដោយពិគ្រោះយោបល់ជាមួយមជ្ឈិម ឬក៏យ៉ាងណានោះ គាត់មិនអាចដឹងបានទេ គាត់បានបញ្ជាក់តាំងពីម្សិលមិញរួចមកហើយ។ ហើយក្នុងសៀវភៅគាត់ក៏គាត់បានបញ្ជាក់ដែរ ថាមិនដឹងថាតើគេពិភាក្សាគ្នាយ៉ាងម៉េចទេ។ ការសួរបែបនេះ គឺធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះគាត់សន្និដ្ឋានដោយស្មានៗហើយ។ សូមអរគុណលោកប្រធាន។

[១៥:០៤:២០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ។ លោកសហព្រះរាជអាជ្ញាដែលបានលើកការកត់សម្គាល់របស់លោក។ ខ្ញុំមិនមែនសូមឲ្យលោកស្រី អាហ្វុងសូ ធ្វើការទាយស្មាននោះទេ។ ខ្ញុំគ្រាន់តែឲ្យគាត់ឆ្លើយបញ្ជាក់អ្វីដែលលោកស្រីធ្លាប់ឆ្លងកាត់ក្នុងការគ្រប់គ្រងរបស់ តាម៉ាន លើការងារប្រចាំថ្ងៃ ដែលនៅពេលនោះ តាម៉ាន នេះ ដាក់ទណ្ឌកម្មទៅលើប្រជាជន ហើយត្រូវបានចោទ គេចោទប្រកាន់ថា គាត់បានសម្លាប់ប្រជាជនផងដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរលោកស្រីតែប៉ុណ្ណោះ ថាតើ តាម៉ាន នេះមានអំណាចដោយខ្លួនឯងគ្រប់គ្រងពេញនៅក្នុងដៃ ឬក៏យ៉ាងម៉េច? ឬក៏សកម្មភាពរបស់ តាម៉ាន នេះមានការបង្គាប់បញ្ជាពីថ្នាក់

លើមក។ ដូច្នេះខ្ញុំគិតថា ដើមបណ្តឹងរដ្ឋប្បវេណីគួរតែផ្តល់ចម្លើយត្រង់ចំណុចនេះ។

[១៥:០៥:០៦]

ដោយសារតែពេលវេលាខ្លី ខ្ញុំសូមបន្តចូលទៅប្រធានបទមួយទៀត។ គឺប្រធានចុងក្រោយដែលខ្ញុំចង់សុំសួរនូវសំណួរមួយចំនួន។ គឺប្រធានបទពាក់ព័ន្ធទៅនឹងការជំនុំជម្រះ ឬក៏សាលាក្តីនៅក្នុងបង្កើតឡើងក្នុងឆ្នាំ១៩៧៩។ លោកស្រីបាននិយាយកាលពីម្សិលមិញថា "លោកស្រីមិនបានទទួលការណែនាំនោះទេ។ ការណែនាំមួយទៅដល់លោកស្រីនោះគឺឱ្យទុកព័ត៌មានថាប្តីរបស់លោកស្រី គឺជាជនកុម្មុយនីស្ត"។ គេអត់ឱ្យលោកស្រីនិយាយអំពីបញ្ហានេះទេ តើអ៊ីចឹងដែរឬទេ?

**ឆ៖** លោកមេធាវីនៅពេលដែលគិតមើលទៅ ខ្ញុំយល់ច្បាស់អំពីការសម្រេចនៅពេលនោះ។ គឺថាវាអាចមានផលប៉ះពាល់ទៅលើការជឿស៊ប់ទៅលើលទ្ធិកុម្មុយនីស្តរបស់លោក សេង។ ប្រសិនបើខ្ញុំផ្តល់ព័ត៌មានមួយចំនួននោះ គឺថា មានន័យថា ជាទូទៅនោះជនកុម្មុយនីស្តហ្នឹងនឹងត្រូវគេវិនិច្ឆ័យ គេនឹងត្រូវកាត់ក្តីហើយ ដូច្នេះហើយខ្ញុំគឺជាពិរុទ្ធជនទៅវិញ។ ប៉ុន្តែឥឡូវនេះ ខ្ញុំអនុវត្តទៅតាមអ្វីដែលគេប្រាប់ គឺថាគេប្រាប់ឱ្យខ្ញុំនោះ គឺជាជនជាតិវៀតណាម ជាអ្នកនិពន្ធជនជាតិវៀតណាម ដែលគេអ្នកប្រាប់ខ្ញុំ អ្នកសរសេរអត្ថបទមកប្រាប់ខ្ញុំផ្ទាល់តែម្តង ថាឱ្យខ្ញុំលាក់ថាប្តីខ្ញុំជាជនកុម្មុយនីស្ត តែគាត់ស្លាប់បាត់ហើយ។ គាត់ជាអ្នកនិពន្ធដ៏ល្បីជនជាតិវៀតណាម ឥឡូវនេះគាត់ស្លាប់ហើយ។ គឺថា ខ្ញុំយល់ពីស្ថានភាពនេះកាលពីពេលនោះៗ ខ្ញុំមិនសូវយល់ប៉ុន្មានទេ ប៉ុន្តែនៅពេលនេះ ពេលដែលពិចារណាមើលទៅ គឺខ្ញុំយល់ពីស្ថានភាព ហេតុអីបានគេប្រាប់ឱ្យខ្ញុំនិយាយកុហកបែបនេះនោះ។ តើលោកមេធាវីព័ត៌មានប៉ុណ្ណឹងអាចគ្រប់គ្រាន់ទេសម្រាប់លោក?

[១៥:០៧:៥៧]

**ស៖** ខ្ញុំគិតថា ខ្ញុំយល់បានតែបន្តិចតែប៉ុណ្ណោះ។ ដោយសារតែប្រធានបទនេះវាពាក់ព័ន្ធតិចតួច ដូច្នេះ ខ្ញុំនឹងសាកសួរបន្ថែមទៀត។ តើលោកស្រីបានចូលរួមការជំនុំជម្រះនាពេលនោះដែរឬទេ? ហើយលោកស្រីមានស្តាប់សក្ខីកម្មដែលផ្តល់ដោយសាក្សីផ្សេងទៀតដែរឬទេ?

**ឆ៖** លោកមេធាវី ខ្ញុំបានចូលរួម ខ្ញុំបានស្តាប់សក្ខីកម្មរបស់ជនរងគ្រោះផ្សេងទៀតដែលមានវត្តមាននៅក្នុងសវនាការ មានជនជាតិចាម មានស្ត្រី។ ហើយឥឡូវនេះលោកសួរខ្ញុំថាអ្នកណាជាជនរងគ្រោះនោះ លោកមេធាវីនៅក្នុងបណ្តាសារនោះ លោកមានឈ្មោះជនរងគ្រោះទាំងអស់ដែលផ្តល់សក្ខីកម្មនៅក្នុងសវនាការនៅពេលនោះហើយ។ ខ្ញុំមិនបានកត់ត្រាទុកទេនៅពេលនោះ។ ពេលនោះគឺថាខ្ញុំយំ

ខ្ញុំទ្រាំប៉ោយំ ពីព្រោះថាវាជាការលំបាក ជាការវេទនាណាស់នៅពេលដែលខ្ញុំស្តាប់សក្ខីកម្មទាំងអស់នោះ គឺថាខ្ញុំរន្ធត់ចិត្តមែនទែន ដូច្នេះខ្ញុំមិនបានមានពេលកត់ត្រាទុកនោះទេ។

[១៥:០៩:០៨]

**ស៖** សូមអរគុណលោកស្រី អាហ្វុងស្វូ ខ្ញុំមិនសួរអំពីខ្លឹមសារសក្ខីកម្មរបស់ជនរងគ្រោះនោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់ដកស្រង់ចំណុចមួយចំនួនចេញពីសៀវភៅរបស់លោកស្រីនៅត្រង់ ERN 00678421 ខ្ញុំដកស្រង់អានជាភាសាបារាំង។ "មេធាវីជនជាតិវៀតណាមក៏បានជួយដល់អ្នកដែលចង់សរសេរសក្ខីកម្មជាភាសាបារាំង ឬភាសាអង់គ្លេស"។ តើលោកស្រីចាំដែរឬទេថា មេធាវីជនជាតិវៀតណាមបានទៅជួយជនរងគ្រោះឲ្យសរសេរនូវសេចក្តីប្រកាស ឬសក្ខីកម្មរបស់ពួកគេនោះ?

**ឆ៖** លោកមេធាវីនៅខែសីហា ឆ្នាំ៧៥ យើងរស់នៅក្នុងសណ្ឋាគារមួយដើម្បីរៀបចំការកាត់សេចក្តី។ ចំពោះខ្ញុំ ខ្ញុំអត់ត្រូវការមេធាវីនោះទេ ពីព្រោះថាខ្ញុំមានកំណត់ត្រារបស់ខ្ញុំ ប៉ុន្តែខ្ញុំនឹកឃើញថាមានអ្នកមកពីស្រុកស្រែដែលគេមិនចេះអាន ចេះអក្សរនោះ គឺពួកគាត់ត្រូវការមេធាវីនៅពេលនោះមេធាវីដើម្បីជួយពួកគេ ប៉ុន្តែនៅពេលនោះខ្ញុំមិនបានចូលរួមក្នុងការពិភាក្សាគ្នានោះទេ។ ចំពោះខ្ញុំគឺមានតែអ្នកនិពន្ធជនជាតិវៀតណាមមួយប៉ុណ្ណោះដែលជួយខ្ញុំ។

[១៥:១១:០២]

**ស៖** សូមអរគុណ។ លោកស្រីបានផ្តល់សក្ខីកម្មកាលពីម្សិលមិញថា លោកស្រីមិនដែលធ្លាប់ឮមនុស្សឈ្មោះប៉ុល ពត ឬក៏ អៀង សារី នោះឡើយ។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំបានអាននូវកំណត់ហេតុនូវសក្ខីកម្មរបស់លោកស្រីនៅចំពោះមុខសាលាក្តីឆ្នាំ៧៩នោះ ឈ្មោះប៉ុល ពត, អៀង សារី នេះ ត្រូវបានលោកស្រីនេះលើកឡើងរៀបរាប់ជាញឹកញាប់។ តើលោកស្រីអាចជួយពន្យល់បានដែរឬទេ ហេតុអ្វីបានជានៅក្នុងសក្ខីកម្ម កំណត់ហេតុសក្ខីកម្មរបស់លោកស្រីនៅនាពេលនោះៗ បានលើកឡើងឈ្មោះជាញឹកញាប់។ បាទ ខ្ញុំសូមកែសំណួររបស់ខ្ញុំដូច្នេះវិញ។ ហេតុអ្វីបានជាលោកស្រីប្រើឈ្មោះ បុគ្គលឈ្មោះ អៀង សារី និង ប៉ុល ពត នៅក្នុងកំណត់ហេតុសក្ខីកម្មរបស់លោកស្រីនៅចំពោះមុខសាលាក្តីឆ្នាំ៧៩?

**ឆ៖** លោកមេធាវី ប៉ុល ពត, អៀង សារី គឺជាឈ្មោះដែលខ្ញុំមិនបានស្គាល់ឡើយ។ ទាល់តែពេលចេញពីជំរំឋាននរកបានខ្ញុំស្គាល់។ គឺមានមន្ត្រីពេទ្យវៀតណាមម្នាក់ដែលប្រាប់ខ្ញុំថា សួរខ្ញុំថា តើអ្នកណាជាអ្នកបង្កឲ្យមានផលវិបាកទាំងអស់នោះ? ហើយខ្ញុំឆ្លើយថា "ខ្ញុំអត់ដឹងទេ" ហើយពេលនោះគាត់ប្រាប់ខ្ញុំថា មានប៉ុល ពត, មានអៀង សារី ជាដើមដែលជាមេបង្កហេតុ។ ហើយចាប់ពីពេលដែលគាត់ប្រាប់

ខ្ញុំនោះហើយ ខ្ញុំយល់ថា គឺអ្នកទាំងពីរនេះហើយដែលជាអ្នកបង្កឲ្យមានទុក្ខសោកវេទនារបស់យើងទាំងអស់គ្នានោះ។ ហេតុដូច្នេះហើយបានជាខ្ញុំយកឈ្មោះគាត់ទាំងពីរនេះមកឆ្លើយនៅចំពោះមុខតុលាការ។ ហើយនៅខែមករា ឆ្នាំ១៩៧៩ នោះ គឺមានតែទាហានវៀតណាម ជាអ្នករំដោះខ្ញុំឲ្យចេញផុតពីឋាននរកនោះ។ បើសិនជាមិនជួយទាន់ពេលទេ ខ្ញុំមិនអាចមកទីនេះដើម្បីឆ្លើយជាមួយនឹងលោកមេធាវីបានទេ។

[១៥:១៣:២០]

**ស៖** ខ្ញុំស្តាប់បានច្បាស់ហើយ។ នៅក្នុងសៀវភៅដែល ដែលខ្ញុំទើបតែដកស្រង់សម្តី ERN 00190698 គឺមានសេចក្តីថ្លែងការណ៍មួយដែលបានលើកឡើងនៅពេលបញ្ចប់ការជំនុំជម្រះរបស់សាលាក្តីនោះ។ ខ្ញុំសូមដកស្រង់សម្តី "ក្រោយការជំនុំជម្រះរយៈពេល៥ថ្ងៃនោះ គឺយើងរកឃើញដោយជឿជាក់និងវិភាគដោយឥតមិនលម្អៀងថា សាលាក្តីនេះបានបង្ហាញនូវការពិត បទប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយ អៀង សារី និង ប៉ុល ពត នោះ គឺថាមិនអាចយកអ្វីមកជំទាស់បាន។ ដូច្នេះសាលាក្តីនេះ បានបង្ហាញថាប្រជាពលរដ្ឋកម្ពុជាគឺជាជនរងគ្រោះ ហើយគាត់ស្ថិតនៅក្រោមការឈឺចាប់នៃឧក្រិដ្ឋ-កម្មរបស់ ប៉ុល ពត, អៀង សារី និងក្រុមរបស់ពួកគេ"។ ខាងក្រោមនោះបន្តិចសេចក្តីថ្លែងការណ៍នោះបានរៀបរាប់ថា "សាលាក្តីប្រជាជនបដិវត្តន៍កម្ពុជា ដោយមានជំហររឹងមាំ និងអនុវត្តតាមនីតិវិធីត្រឹមត្រូវបានថ្កោលទោសប្រហារជីវិតដល់ អៀង សារី និង ប៉ុល ពត។ ដូច្នេះ ការធ្វើដូច្នេះគឺដើម្បីលើកកម្ពស់ប្រជាជនកម្ពុជានិងពង្រឹងតួនាទីនៃសាលាក្តីបដិវត្តន៍ប្រជាជនកម្ពុជា"។ សូមបញ្ចប់ការដកស្រង់។ នេះគឺជាសុន្ទរកថា សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយប្រធានឈ្មោះ ហេង សំរិន ហើយលោកបានលើកឡើងថា "ប្រជាពលរដ្ឋកម្ពុជាទាំងអស់ គឺជនរងគ្រោះ ហើយគឺជាសាក្សីឃើញនូវឧក្រិដ្ឋកម្មរបស់បន ប៉ុល ពត, អៀង សារី និងក្រុមរបស់ពួកវា"។ ហើយនៅក្នុងនោះក៏មានភ្ញៀវបរទេសផងដែរចូលរួម។ ដូច្នេះលោកស្រី ហ៊ុងសួ តើលោកស្រីមានបានចូលរួមស្តាប់នៅសុន្ទរកថា ឬក៏សេចក្តីថ្លែងការណ៍ របស់លោកប្រធាន ហេង សំរិន នាពេលនោះដែរឬទេ?

[១៥:១៥:៤៩]

**ឆ៖** លោកមេធាវី នៅពេលនោះខ្ញុំអត់មានវត្តមានទេ។ ដូច្នេះនៅពេលដែលលោកអានសុន្ទរកថានោះ ខ្ញុំអត់យល់ទេ ថាអ្នកណាជាអ្នកនិយាយ។ ឥឡូវនៅពេលដែលលោកអាននេះ ខ្ញុំយល់ ប៉ុន្តែខ្ញុំមិនមានវត្តមានទេនៅពេលនោះ។ ខ្ញុំ គេហៅឲ្យទៅផ្តល់សក្ខីកម្មតែមួយព្រឹកទេ។ ខ្ញុំមានវត្តមានតែមួយព្រឹកទេ ហើយខ្ញុំរៀបរាប់ពីរឿងរ៉ាវដែលខ្ញុំត្រូវរៀបរាប់ ហើយបន្ទាប់មកខ្ញុំចេញ ហើយបន្ទាប់មក ខ្ញុំមិនបាន

តាមដាននូវការកាត់ក្ដីរយៈពេល៥ថ្ងៃនោះទេ។ ដូច្នេះខ្ញុំមិនចាំទេថាអ្នកណាជាអ្នកនិយាយសុន្ទរកថានោះ។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំមិនសួរសំណួរលោកស្រី ពាក់ព័ន្ធនឹងប្រធានបទនេះទៀតទេ លោកស្រី អាហ្វុងសូ ខ្ញុំពុំមានសំណួរសួរលោកស្រីទៀតទេ។ ក្នុងនាមសហមេធាវីការពារក្ដីលោក នួន ជា រួមជាមួយនឹងលោក សុន អរុណ ជាមេធាវីជាតិនោះ ខ្ញុំសូមថ្លែងអំណរគុណចំពោះការផ្ដល់នូវចម្លើយរបស់លោកស្រី។ ជូនពរឲ្យលោកស្រីមានកម្លាំងពលំមាំមួននិងមានសំណាងល្អ។ ហើយខ្ញុំសូមផ្ដល់វេទិកាទៅដល់មេធាវីផ្សេងទៀត បើសិនបើគាត់ចង់សួរសំណួរ។

**លោកស្រី ដេនីស អាហ្វុងសូ៖**

សូមអរគុណច្រើនលោកមេធាវី។

[១៥:១៧:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ។

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន សូមគោរព លោក លោកស្រីចៅក្រម។ សួស្ដីសហព្រះរាជអាជ្ញា សួស្ដីសហភាគី សូមក្រាបថ្វាយបង្គំសម្ដេចព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ ហើយក៏សួស្ដីអ្នកស្រី អាហ្វុងសូ ដេនីស។ ខ្ញុំ អាង ឧត្ដម ហើយខាងស្ដាំខ្ញុំនេះគឺលោក ម៉ៃខល កាណាវាស។ យើងខ្ញុំជាសហមេធាវីការពារក្ដីលោក អៀង សារី។ នៅពេលនេះ យើងមិនមានសំណួរនឹងសួរលោកស្រីទេ។ តែយ៉ាងណាក៏ខ្ញុំសូមអរគុណលោកស្រីដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកា ជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោកស្រី ដេនីស អាហ្វុងសូ៖**

សូមអរគុណលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ក្នុងមានលោក ខៀវ សំផន ក្រុមយើងខ្ញុំអត់មានសំណួរតាំងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រី ហ្វុងសូ ឥឡូវនេះអង្គជំនុំជម្រះផ្តល់ឱកាសជូនលោកស្រីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

សូមអញ្ជើញ!

[១៥:១៩:០៩]

**លោកស្រី ដេនីស អាហ្វុងសូ៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំចង់ប្រកាសនៅថ្ងៃនេះថា ក្នុងរយៈពេលនោះ ខ្ញុំទទួលរងនូវការឈឺចាប់យ៉ាងខ្លាំង។ ជីវិតខ្ញុំហ្នឹងគឺថាធ្លាប់តែនៅក្នុងប្រទេស ដែលមានសន្តិភាពនោះបានធ្លាក់ចូលទៅក្នុងឋាននរក គឺឋាននរកជាប្រចាំថ្ងៃតែម្តង ហើយគេដកហូតយើងអ្វីៗគ្រប់បែបយ៉ាង គេបណ្តេញយើងចេញពីផ្ទះ គេរឹបអូស គេបំផ្លាញចោលនូវអ្វីៗដែលយើងបានកសាង។ ជីវិតខ្ញុំដែលរយៈពេល៣០ឆ្នាំនោះ ត្រូវបានបំផ្លាញខ្ទេចខ្ទីឲ្យក្លាយជាផេះផង់។

ខ្ញុំនៅតែមានព្យសនកម្ម មានព្យសនកម្មជាច្រើនមកលើខ្ញុំ។ យើងមិនមានការថែទាំងខាងផ្នែកពេទ្យ មិនមានគ្រូពេទ្យ យើងទទួលរងនូវការខ្វះខាតអាហារ មិនមានអនាម័យ។ ខ្ញុំកើតនូវជំងឺជាច្រើន ជំងឺដែលសំខាន់បំផុតសម្រាប់ខ្ញុំនោះគឺ ខ្ញុំបានកើតរបេង។ ប្រសិនបើកងទ័ពវៀតណាម មិនមកទាន់ទេនោះ ថាខ្ញុំស្លាប់បាត់ទៅហើយ គឺថាខ្ញុំត្រូវបានព្យាបាលនៅមន្ទីរពេទ្យសាំងអង់ទ័ន។ ខ្ញុំកើតជំងឺគ្រុនចាញ់ទៀត ជំងឺទាំងពីរនេះហើយគឺថា ខ្ញុំនៅតែមានស្លាកស្នាមជាប់ជានិច្ច ខ្ញុំនៅមានស្នាមនូវជំងឺគ្រុនចាញ់ ហើយជំងឺនេះ គឺថានៅ ដូចជានៅជាប់ខ្ញុំជាមួយនៅជាមួយខ្ញុំជាកិច្ច។ ហើយនៅពេលដែលយើងមានជំងឺគ្រុនញាក់ នៅពេលដែលគ្រុនចាញ់ហើយ គេទាញអូសយើងចេញពីផ្ទះ ឲ្យយើងទៅធ្វើការនៅក្នុងស្រែនៅក្រោមកំដៅថ្ងៃក្តៅហែងនោះ គឺថាខ្ញុំចង់សួរអស់លោកទៅមើល ថាតើលោកប្រធាន លោកមេធាវី លោក លោកស្រីចៅក្រមគិតទៅមើលតើខ្ញុំលំបាកវេទនាប៉ុនណា?

[១៥:២១:០០]

ខ្ញុំទទួលរងនូវការឈឺចាប់ ទាំងផ្នែករាងកាយ ទាំងផ្នែកផ្លូវចិត្ត ខ្ញុំមិនអាចរៀបរាប់នូវអ្វីដែលបានកើតឡើងឲ្យអស់នោះទេ។ ជាដំបូងនោះគឺ ការជម្លៀសគេបណ្ដេញយើងឲ្យចេញពីផ្ទះ គេមិនស្ដាប់យើងទេ គេឲ្យយើងចេញ បើថាមិនចេញទេគឺថា យើងនឹងមិនអាចនៅបានទៀតទេ។ នៅពេលដែលគេបណ្ដេញយើងចេញពីផ្ទះទៅដល់ស្រុកស្រែហើយ គេឲ្យយើងធ្វើការទម្ងន់ ហើយគេសើចចំអកយើងទៀត ព្រោះគេហៅខ្ញុំថា យាយបារាំង គេសើចចំអកចំពោះខ្ញុំ គេដកយកកូនពីខ្ញុំចេញ មិនឲ្យនៅជាមួយខ្ញុំ ហើយមិនប្រាប់ខ្ញុំថាយកទៅណាទៀត។ គេគ្រាន់តែប្រាប់ថា អង្គការនឹងមើលថែកូនរបស់អ្នកឯងហើយមិនមែនជាកូនអ្នកឯងទៀតទេ គឺជាកម្មសិទ្ធិរបស់អង្គការ មិនចាំបាច់ខ្វល់ពីកូនទេ។ ពួកវាមិនមែនជាកូនរបស់អ្នកឯងទៀតទេ ពីព្រោះថាពួកវាត្រូវបានគេបំពាក់បំប៉នមនោគមន៍វិជ្ជាអស់ហើយ។

[១៥:២២:២៦]

ហើយនៅពេលដែលកូនខ្ញុំជិតស្លាប់នោះ សុំបាយតែមួយកូនចាននោះ ហើយខ្ញុំមិនអាចផ្ដល់ឲ្យបាយទៅឲ្យកូនស្រីខ្ញុំនោះ ធ្វើឲ្យកូនខ្ញុំស្លាប់ដោយអត់បាយសូម្បីតែមួយកូនចាននោះ គឺខ្ញុំឈឺចាប់ខ្លាំងណាស់។ ខ្ញុំទទួលរងនូវព្យសនកម្មច្រើនណាស់ ហើយខ្ញុំអាចរៀបរាប់បានច្រើនទៀត។ អ្វីដែលពួកនោះបានធ្វើនោះ តើសព្វថ្ងៃនេះ គេបានដាក់ទោសពួកអ្នកដែលប្រព្រឹត្តអស់ហើយ ឬនៅ? សព្វថ្ងៃនេះគឺថា ខ្ញុំនៅតែមានអារម្មណ៍ឈឺចាប់ ប៉ុន្តែខ្ញុំត្រូវតែខំរស់នៅដើម្បីកូនរបស់ខ្ញុំ ខ្ញុំត្រូវតែប្រឹងរឹងមាំ រឹងប៉ឹងឲ្យមានសុខភាពល្អ។ ពួកគេបង្ខំឲ្យយើងធ្វើការ ហើយប្រសិនបើអស់លោកគិតមើលថាជាខ្ញុំវិញនោះ ថាតើត្រូវធ្វើយ៉ាងម៉េចដើម្បីចាកចេញពីស្ថានភាពបែបនេះនោះ? ហើយបើសួរខ្ញុំថាតើមានព្យសនកម្មអ្វីខ្លះនោះ គឺថាយើងគិតមើលទៅគឺថា ភាពសាហាវឃោរឃៅ ការធ្វើទារុណកម្ម ការវាយទាត់ធាក់ ហើយគ្រាន់តែយើងលួចស្ករត្នោតបន្តិចនោះ គេយើងយកទៅហាលថ្ងៃ ហើយឲ្យយើងមើលថា មេរៀនយ៉ាងម៉េចៗនោះគឺ គេធ្វើបាបយើង គេមិនគោរពសិទ្ធិមនុស្សទាល់តែសោះ។ គេសម្លាប់មនុស្សស្រេចតែចិត្ត។

[១៥:២៣:៥៧]

យើងមិនមែនជាមនុស្សទេ គេចាត់ទុកដូចជាសត្វធាតុ គឺគេលែងគិតយើងជាមនុស្សហើយ គេគិតថាយើងជាសត្វតែប៉ុណ្ណោះ។ ខ្ញុំអាចនិយាយ -- ខ្ញុំនៅតែនិយាយម្ដងហើយម្ដងទៀតថា នៅពេលនោះគឺថាគ្រោះអត់ឃ្លាននេះ គឺថាត្រូវបានរៀបចំត្រឹមត្រូវ គេគ្រោងផែនការ ដើម្បីធ្វើម៉េចឲ្យប្រជាជនអត់ឃ្លានស្លាប់ ឲ្យមានតែដៃទទេ ហើយគេបានប្រាប់ថា កុំ-- បើសិនជាអត់បាយនោះ ម៉េចក៏ពួកយើងមិនស្លាប់យើងក៏អត់បាយដែរ កុំចេះតែថាគេឲ្យយើងអត់បាយស្លាប់នោះ។ គេមិនបានថែទាំងព្យាបាល

យើងទេ ពេលយើងឈឺគ្មានថ្នាំសង្កូវឲ្យយើងព្យាបាលទេ គឺគេសម្លាប់យើង គេរៀបចំផែនការដើម្បីសម្លាប់យើងដោយការបង្អត់បាយយើងតែម្តង។

ដូច្នេះ ជារៀងរាល់ថ្ងៃនេះ ខ្ញុំសុបិនអាក្រក់រហូតនៅពេលយប់ គឺថាសុបិនមកលងខ្ញុំ ខ្ញុំមិនអាចឈានជើងចូលមកប្រទេសកម្ពុជាទៀតទេ។ ខ្ញុំស្រលាញ់កម្ពុជា ប៉ុន្តែខ្ញុំមិនអាចឈានជើងទេ អស់រយៈពេលជាង៣០ឆ្នាំមកហើយខ្ញុំមិនអាចលើកជើងឈានចូលទឹកដីកម្ពុជាទេ ពីព្រោះថាវាធ្វើឲ្យខ្ញុំនឹកឃើញនូវសុបិនអាក្រក់ទាំងឡាយដែលខ្ញុំបានឆ្លងកាត់ ដែលខ្ញុំបានទទួលរង។ ខ្ញុំក៏ដូចជាប្រជាជនកម្ពុជាដែរ គឺថាយើងមិនអាចទទួលរងនូវ -- ទ្រាំទ្រនូវអំពីទាំងអស់នេះបានទេ។ វាមានទំហំធំធេងណាស់ មិនមែនមានតែខ្ញុំម្នាក់ឯងទេ គឺថាមានមនុស្សរាប់លាននាក់ដែលទទួលរងនូវការឈឺចាប់ ពួកគេឈឺចាប់ទាំងអស់គ្នា។ ហើយថ្ងៃនេះបើសិនជាអ្នកណាអាចរៀបរាប់ការឈឺចាប់បានពួកគេនឹងមានការធូរស្រាលហើយ។

[១៥:២៥:៥៦]

ខ្ញុំមិនអាចកសាងជីវិតថ្មីបានទេ ដោយសារតែរឿងទាំងអស់នោះ។ ឥឡូវនេះ ខ្ញុំនៅសល់តែកូនប្រុសម្នាក់គត់ ហើយកូនប្រុសរបស់ខ្ញុំហ្នឹងក៏មានការតក់ស្លុតរន្ធត់ជាប់ជានិច្ច ពីព្រោះថាគេធ្វើទារុណកម្មវា។ ដូច្នេះវានៅតែរន្ធត់ នឹកឃើញរឿងនោះឡើងវាមានការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង។ ដូច្នេះអ្នកដែលបានប្រព្រឹត្តនៅអំពើទាំងអស់នោះ សូមឲ្យទទួលរងនូវការកាត់ទោសឲ្យបានយុត្តិធម៌បំផុតលោកប្រធាន។ សូមអរគុណលោកប្រធាន។ ហើយសូមអរគុណដល់អង្គតុលាការទាំងមូលផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណលោកស្រី អាហ្វុងសូ។ ឥឡូវនេះ ការស្តាប់សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅក្នុងរឿងក្តីនេះ។ លោកស្រី អាហ្វុងសូ អាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកស្រីវិញបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ មានសុខភាពល្អ មានសេចក្តីសុខសប្បាយ។ អង្គជំនុំក៏សូមអរគុណផងដែរ ដល់មេធាវី ជូល្យាន រីវ៉េ ។

[១៥:២៧:១៨]

កិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មលោកស្រី អាហ្វុងសូ បានចប់សព្វគ្រប់ហើយ។

**លោក ជូល្យាន រីវ៉េ៖**

សូមអរគុណលោកប្រធាន។

**លោកស្រី ដេនីស អាហ្វុងសូ៖**

សូមអរគុណលោកប្រធានច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ ជម្រាបលាបាទ។

**លោកស្រី ដេនីស អាហ្វុងសូ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ អ្នកបច្ចេកទេសខាងប្រព័ន្ធសោតទស្សន៍អាចផ្ដាច់ប្រព័ន្ធសោតទស្សន៍រវាងបន្ទប់សវនាការនេះជាមួយនឹងប្រទេសបារាំង ពីកន្លែងដែលលោកស្រី អាហ្វុងសូ ផ្ដល់សក្ខីកម្មបានហើយ។

បាទ ជាបន្តនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅភាគីនានា ដើម្បីអាចធ្វើការកត់សម្គាល់លើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អាហ្វុងសូ ប្រសិនបើភាគីមានបំណងធ្វើដូច្នេះ។

បាទ ទំនងជាមិនមានទេ។ អង្គជំនុំជម្រះជម្រាបភាគី និងសាធារណជនថា ជាបន្តនេះអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មសាក្សី២ ផាន វ៉ាន ហៅ ខាំ ផាន់ ដូចអង្គជំនុំជម្រះបានជម្រាបជូនកាលពីព្រឹកមិញដោយសារអង្គជំនុំជម្រះបានឃាត់ទុកគាត់បម្រុងទុក សម្រាប់បន្តការស្ដាប់សក្ខីកម្មរបស់គាត់ ក្នុងន័យពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការរបស់យើង។ ប៉ុន្តែឥឡូវនេះ ដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបួនខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ហើយនិងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបួនខ្វះដប់ប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៥:២៩ នាទី ដល់ម៉ោង ១៥:៤៦ នាទី)*

[១៥:៤៦:៤៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក សុន អរុណ៖**

សូមគោរពលោកប្រធានសាជាថ្មី។ ខ្ញុំនឹងបន្តសំណួររបស់ខ្ញុំកាលពីព្រឹកមិញ។

**សួរបន្តដោយលោក សុន អរុណ៖**

**ស៖** ហើយនិងសូមជម្រាបសួរលោក ខាំ ផាន់ សាជាថ្មី។ លោក ខាំ ផាន់ ឲ្យខ្ញុំហៅលោក ខាំ ផាន់ ឬលោក ផាន វ៉ាន?

**លោក ផាន វ៉ាន៖**

**ឆ៖** ផាន វ៉ាន ឈ្មោះផ្លូវការ ផាន វ៉ាន បាទ ។

**ស៖** លោក ផាន វ៉ាន ខ្ញុំសួរបន្តទៅទៀត។ ពីព្រឹកមិញខ្ញុំសួរបានពាក់កណ្តាល ប៉ុន្តែមិនអស់សំណួរ ឥឡូវខ្ញុំសួររំឭកសាជាថ្មីនូវសំណួររបស់ខ្ញុំព្រឹកមិញ។ នៅក្នុងទូរសាររបស់លោក នៅលេខ៤០ (សូមទោស) ខ្ញុំមុននឹងខ្ញុំអានទូរសារទាំងអស់នេះ ខ្ញុំនឹងសូមជូនតាម--

**លោក សុន អរុណ៖**

សូមលោកប្រធានអនុញ្ញាតឲ្យយកទូរសារចំនួនប្រាំពីរ ដែលខ្ញុំបម្រុងសួរព្រឹកមិញនេះជូនទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ប៉ុន្តែសូមលោកផ្តល់នូវអត្តសញ្ញាណឯកសារនីមួយៗផង។

**លោក សុន អរុណ៖**

ទូរសារទាំងនេះមានលេខទូរសារដូចតទៅ៖ លេខទូរសារ០០, លេខទូរសារលេខ២, លេខទូរសារលេខ៣, លេខទូរសារលេខ៣ម្តងទៀត ប៉ុន្តែន័យ -- អត្ថន័យខុសគ្នា, លេខទូរសារលេខ១០, លេខទូរសារលេខ២២ និងលេខទូរសារលេខ៣៣។

[១៥:៤៩:៤៦]

**ប្រធានអង្គជំនុំ៖**

អត្តសញ្ញាណឯកសារ គឺលេខដែលប្រើប្រាស់នៅក្នុងសំណុំរឿងលោកមេធាវី។

បើកក្បាលមីក្រូសិនលោក!

**លោក សុន អរុណ៖**

ឯកសារលេខ E3/1196 ទូរសារលេខ៣៣, លេខ E3/1195 ហ្នឹងទូរសារលេខ២២, ឯកសារលេខ E3/1194 អាហ្នឹងទូរសារលេខ ១០, ឯកសារលេខ E3/1189 ហ្នឹងទូរសារលេខ៣, ឯកសារលេខ E3/1193 ហ្នឹងទូរសារលេខ៣ ដែរ, ឯកសារលេខ E3/1192 ហ្នឹងទូរសារលេខ២, ឯកសារលេខ E3/1191 ទូរសារលេខ០០។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីការពារក្តី លោកយកជូនសាក្សីពិនិត្យ!

[១៥:៥២:០០]

**លោក សុន អរុណ៖**

ខ្ញុំអាចសួរលោកសាក្សីបានទេ ពេលនេះលោកសាក្សីអាចឆ្លើយបានទេឃើញឯកសារខ្ញុំនេះហើយ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដើម្បីសម្រួលកិច្ចការ កិច្ចដំណើរការនីតិវិធី លោកអាចចាប់ផ្តើមមួយម្តង មួយណាដែលលោកមានបំណងក្នុងការរៀបចំសំណួរសួរដេញដោលសាក្សី សូមលោកប្រាប់ទៅដើម្បីឲ្យមានរបៀបរៀបរយ។ ពុំដូច្នោះទេ ដល់ពេលឲ្យគាត់មើលទាំងប្រាំពីរ ដល់ពេលសួរមិនដឹងសួរមួយណាទេ ព្រោះមិនមែនជាការងាយក្នុងការចងចាំយល់បាននោះទេ។

**លោក សុន អរុណ៖**

ខ្ញុំចង់សួររួមទៅលើសាក្សី ពីព្រោះ ពីរឿងទម្រង់និងបែបបទនៃឯកសារនេះ មិនមែនសួរអត្ថន័យនៅក្នុងឯកសារនេះទេ សួររួមអំពីបែបបទ និងទម្រង់។ ដូចពីព្រឹកមិញខ្ញុំបានបង្ហើបបន្តិចប៉ុន្តែដោយសារដាច់មួយកំណាត់ដោយសារមានសញ្ញារូបនាគអ៊ីចឹងទៅ ដោយមានសរសេរអក្សរខ្មែរ ខ្មែរតេឡា អ៊ីចឹងៗទៅ អាហ្នឹងជាទម្រង់ និងបែបបទ ទាំងប្រាំពីរហ្នឹងដូចគ្នា។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[១៥:៥៣:២៨]

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកសាក្សីបានឃើញឯកសារហ្នឹងហើយ ខ្ញុំអាចសួរបានទេ?

**លោក ផាន វ៉ាន៖**

**ផ៖** សួរបានបាទ។

**ស៖** ខ្ញុំចង់ -- ខ្ញុំសួរថាលោកបានបកប្រែទូរសារនោះក្នុងរយៈពេលប៉ុន្មានខែ? ឬប៉ុន្មានឆ្នាំធ្វើការនុ៎ង?

**ផ៖** ខ្ញុំធ្វើការបកសារនុ៎ងមុនដាច់ភ្នំពេញ ហើយនិងក្រោយដាច់ភ្នំពេញបានមួយរយៈខ្លី ខ្ញុំបើកឡានរហូត។ ហើយក្រោយពីហ្នឹងបងស្រីខ្ញុំ គាត់អ្នកបន្តរហូត។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** លោកអាចនិយាយពាក្យច្បាស់លាស់មួយថា រយៈពេលប្រហែល -- មិនថាប្រហែលទេ រយៈពេលប៉ុន្មាន ប៉ុន្មានខែ? ប៉ុន្មានឆ្នាំ?

**ផ៖** ប្រហែល ២ឆ្នាំបាទ។

**ស៖** អរគុណ។ អ៊ីចឹងចុងក្រោយបំផុតនៃការងាររបស់លោក រឿងបកប្រែទូរសារនេះ ពេលចុងក្រោយបំផុតរបស់លោកនៅពេលណា? ឆ្នាំណា?

**ផ៖** ក្នុងឆ្នាំប្រហែលជិតៗចូល៧៦បាទ។

**ស៖** បន្ទាប់ពីនោះទៀត អ្នកណា -- បងស្រីរបស់លោកអ៊ីចឹង ហើយឬក៏អ្នកណាដែលធ្វើការបន្តពីលោក?

**ផ៖** បងស្រីរបស់ខ្ញុំបាទ។

**ស៖** បើអ៊ីចឹងនៅក្នុងឯកសារទាំងប្រាំពីរនេះ ដែលខ្ញុំបម្រុងសួរ ពីរឿងបែបបទនិងទម្រង់របស់ឯកសារនេះ លោកប្រហែលជាមិនបានធ្វើកិច្ចការហ្នឹងទេ។ លោក បើសិនជាលោកមិនបានធ្វើ អាហ្នឹងសូមលោកឆ្លើយថា អត់ដឹង។

**ផ៖** អត់ៗដឹងបាទ។

[១៥:៥៦:០៤]

**ស៖** អរគុណ។ មុននឹងបងស្រីមកកាន់ការបន្តពីលោក នៅធ្វើបកប្រែឯកសារនេះ ពេលដែលលោកធ្វើរយៈ២ឆ្នាំហ្នឹង ទម្រង់នៃការបកប្រែទូរសារទាំងប៉ុន្មានហ្នឹង មានទម្រង់របៀបអ៊ីចឹងទេ ឬក៏ខុសហ្នឹង?

**ឆ៖** ទម្រង់ដូចគ្នាបាទ របៀបរបប គឺរបៀបដូចគ្នាបាទ។

**ស៖** បើដូច្នេះ ខ្ញុំសួរថា ទូរសារពីលើមកមានលេខ មានអីអ៊ីចឹងមក ន័យអត្ថបទរបស់ទូរសារហ្នឹងមកចុះថ្ងៃខែ និងដាក់ឈ្មោះមនុស្សដែលផ្ញើ ហើយចម្លងជូន បងនួន, បងខៀវ អីអ៊ីចឹងទៅ។ ប៉ុន្តែខាងក្រោមហ្នឹង ឥឡូវឯកសារលោកមើលទៅហើយ ឃើញហើយខាងក្រោមហ្នឹងមានដាក់ តេឡា --ខ្មែរតេឡា ហើយអាសយដ្ឋានរបស់ខ្មែរតេឡាហ្នឹង មានជាអក្សរខ្មែរ និងអក្សរឡាតាំង។ ពីដើមមកមានធ្វើអ៊ីចឹងដែរ? ពីកាលសម័យលោក?

**ឆ៖** កាលសម័យនុំង តេឡា អត់មានទេបាទ។ មានតែឈ្មោះ ហើយចុះថ្ងៃខែ ឈ្មោះ អាហ្នឹងជាធម្មតាអ៊ីចឹងបាទ។ វាត្រូវតែមាន។

**ស៖** បើដូច្នោះ ទូរសារទាំងប្រាំពីរដែលខ្ញុំបង្ហាញលោកឥឡូវនេះ លោកទទួលស្គាល់ថាទូរសារហ្នឹង ជាទូរសារពិតប្រាកដដែលមាននៅក្នុងតំបន់១០៥ ដែលផ្ញើមកថ្នាក់លើទេ?

**ឆ៖** ខ្ញុំជឿថាពិតប្រាកដ បើតាមច្បាប់ដើមនោះ វាពិតប្រាកដ តាមទម្រង់សរសេរ និងអត្ថន័យខ្លឹមសារ ហើយរបៀបៗរបបជំនាន់ហ្នឹងអី វាទម្រង់អ៊ីចឹងបាទ។ ប៉ុន្តែវាខុសត្រង់ តេឡា ៗវាមិនដែលឮទេ ជំនាន់ហ្នឹងបាទ។

**ស៖** ខ្ញុំសួរថា លោកទទួលស្គាល់មកដល់ថ្ងៃនេះ ដែលបង្ហាញនៅតុលាការនេះ លោកថាទម្រង់ហ្នឹង បែបបទហ្នឹងលោកទទួលស្គាល់។ ចុះបំពោះពាក្យខ្មែរ "តេឡា" ហើយនិងមានអាសយដ្ឋានទាំងអស់ហ្នឹង លោកទទួលស្គាល់ដែរឬទេថា ហ្នឹងត្រឹមត្រូវឬអត់?

[១៥:៥៨:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ បាទមានបញ្ហាជាច្រើនពាក់ព័ន្ធទៅនឹងខ្សែគំនិតនៃសំណួររបស់មេធាវីការពារក្តី។ នៅព្រឹកនេះ មុនពេលឈប់សម្រាក សាក្សីបានឆ្លើយបញ្ជាក់ថា ច្បាស់ហើយថា គាត់

បញ្ជាក់អំពីយថាភាពនៃទូរលេខដោយផ្អែកទៅលើទម្រង់ ឬក៏ទ្រង់ទ្រាយនៃទូរលេខ។ ទី២ ការជជែកពិភាក្សាដើម្បីចង់ដឹងថាតើ "តេឡា" នេះយ៉ាងម៉េច អីយ៉ាងម៉េចនោះ ខ្ញុំគិតថាមេធាវីការពារក្ដីកំពុងតែនាំឲ្យសាក្សីភ័ន្តច្រឡំហើយ។ ពីព្រោះថានៅពេលដែលយើងបង្ហាញឯកសារជាច្រើនជូនសាក្សីនោះ ដូចដែលយើងបានបង្ហាញពីលើកមុនៗដែរនោះ គឺថាយើងបានពន្យល់ច្បាស់ហើយថា ឯកសារនោះគឺបានបញ្ជូនទៅមជ្ឈិម ដោយតំបន់១០៥ ហើយសាក្សីក៏បានបញ្ជាក់ពីចំណុចនេះដែរ។

[១៦:០០:០៥]

មេធាវីការពារក្ដីនាំឲ្យសាក្សីភ័ន្តច្រឡំ ពីព្រោះថាសំណៅដែលយើងរកនោះ មិនមែនជាសំណៅដើមដែលផ្ញើពីតំបន់១០៥ ទៅឲ្យមជ្ឈិមទេ គឺយើងឃើញថាឯកសារនោះ គឺទទួលនៅមជ្ឈិម។ ដូច្នេះយើងមានការពន្យល់អំពីវិធីសាស្ត្រនៃការផ្ញើសារ និងទទួលសាររួចមកហើយ គឺមានការវាយអង្គុលីលេខហើយមានការបកប្រែបំភ័ន្តអក្ខរៈ...។ល។ ដូច្នេះ វាមិនមានការឆ្ងល់អីទេ ពីព្រោះថាទូរលេខដែលបង្ហាញនៅថ្ងៃនេះ គឺថាសុទ្ធតែជាឯកសារដែលទទួលបានពីមជ្ឈិម។ ដូច្នេះ វាមិនមានលក្ខណៈដូចគ្នា ដែលជាទៅនឹងទូរលេខដែលផ្ញើចេញពីតំបន់១០៥ នោះទេ ពីព្រោះថាមានចម្លងជូនចុះឡើងៗ ហើយមានវាយអង្គុលីលេខនៅលើឯកសារនោះហ្នឹងបន្ថែមពីលើទៀត ហើយមានបន្ថែមក្បាលទំព័រតេឡាអីជាដើមនេះ មិនមែនជាឯកសារ -- មិនមែនជាក្រដាសដើមដែលប្រើដោយតំបន់១០៥ ដើម្បីផ្ញើទេ ព្រោះមានការចម្លងជូនទៅវិញទៅមក។ ដូច្នេះមេធាវីការពារក្ដី គួរតែឲ្យមានភាពច្បាស់លាស់ គឺថាទូរលេខនេះ យើងបានទទួលនៅភ្នំពេញ ហើយទទួលគឺថា យើងយកនៅពេលបានទទួលទេ មិនមែនផ្ញើចេញពីតំបន់មកនោះទេ ឯកសារនុ៎ងនោះ។

[១៦:០១:២៥]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅលោកព្រះរាជអាជ្ញាដោយខ្លី។ នេះជាការជាក់លាក់ច្បាស់លាស់ ភស្តុតាងដែលមិនអាចប្រកែកបាន ឯកសារនេះកំពុងតែប្រើនៅមុខតុលាការ ឥឡូវនេះ។ ហើយបើលោកព្រះរាជអាជ្ញាថាទេ លោកអត់ទទួលស្គាល់ទេ ឯកសារទាំងអស់នេះ ដែលផ្ញើពីតំបន់១០៥មកមជ្ឈិម ឬមកមន្ទីរ៨៧០ មិនមែនជាផ្លូវការ ឬយ៉ាងម៉េច? អាហ្នឹងសូមឲ្យសាមីខ្លួនដែលទទួលស្គាល់នេះ បញ្ជាក់ឲ្យច្បាស់ថាតើទទួលស្គាល់ឯកសារហ្នឹង ឬមិនទទួលស្គាល់? មែន ឬមិនមែន? បើមិនមែន ថាមិនមែនទៅអាហ្នឹងខ្ញុំឈប់សួរ។ ហើយបើព្រះរាជអាជ្ញាថា ទេអានេះវាជាផ្លូវការ វាទុកជាផ្លូវការទៀតហើយ។ បើអីចឹងមាន

ន័យថា ផ្លូវការរបស់ខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងតេឡាធ្វើការជាមួយគ្នា។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះទេ លោកមេធាវី បញ្ហាឯកសារដែលលោកដាក់មកគឺជា ទូរសារដែលគេទទួលនៅភ្នំពេញ ដែរៀបចំទៅជាអក្សរនៅឯភ្នំពេញ។ ចំណែកឯគាត់នេះ គាត់យល់ដឹងអំពីឯកសារដើម ការវ៉ៃទូរលេខនៅឯតំបន់១០៥។ អ៊ីចឹងឯកសារនេះ ប្រសិនបើលោកមានបំណងសួរគឺ គប្បីសួរអ្នកដែលធ្វើការងារខាងសារទូរលេខនៅឯភ្នំពេញ វាមានហេតុផលយ៉ាងម៉េចបានជាវាអ៊ីចឹងៗនោះ។ ចំណែកគាត់បានឆ្លើយរួចហើយអំពីទម្រង់ គឺវាសមស្របនឹងអ្វីដែលគាត់រៀន ដែលគាត់អនុវត្ត។ ប្រសិនបើលោកយក ចង់យកឯកសារដែលមានការពាក់ព័ន្ធនឹងសួរគាត់ លុះត្រាតែសួរគាត់ថា នៅភ្នំពេញហ្នឹងគាត់ធ្វើការនៅផ្នែកទទួលទូរសារពីតំបន់១០៥ ឬយ៉ាងណា? ពីព្រោះបើសិនជា សារហ្នឹងគាត់ទទួលនៅឯ១០៥ ហើយអំឡុងពេលគាត់ធ្វើការអាហ្នឹងបានត្រូវគាត់ដឹង អំពីបញ្ហាប្រភេទឯកសារហ្នឹង វាកើតឡើងយ៉ាងដូចម្ដេច អាចប្រើប្រាស់ឯកសារ និងក្រដាសពីណាមក។

វាមិនខុសអីពីនៅក្នុងសំណុំរឿងនៃការកត់ត្រានៅក្នុងសំណុំរឿងផ្សេងទៀត នៅក្នុងសំណុំរឿង ០០១ យកឯកសារស្រដៀងគ្នានេះទៅកត់ត្រា កត់ដែរទេ អានុំងរឿងមួយទៀត។ ប៉ុន្តែយើងគ្រាន់តែពន្យល់លោកថា ឯកសារនេះ ប្រសិនបើលោកមានការប៉ុនប៉ងសួរ គឺគប្បីសួរអ្នកដែលធ្វើការនៅភ្នំពេញ ពីព្រោះអ្នកទទួលព័ត៌មាននេះ គឺនៅភ្នំពេញទេ មិនមែននៅឯ១០៥ ទេ បើលោកមានសារដែលផ្ញើទៅ ១០៥ យកមកពាក់ព័ន្ធអាហ្នឹងទំនងជាអាចសួរដេញ -- រៀបសួរគាត់បាន។

[១៦:០៤:៣៤]

**លោក សុន អរុណ៖**

ខ្ញុំចង់បញ្ជាក់ពីគោលបំណងដែលខ្ញុំសួរទៅសាក្សី។ ជម្រាបលោកប្រធានថា អ៊ីចឹងហើយបានជាខ្ញុំសួរទៅសាក្សីថា លោកដែលឃើញឯកសាររបៀបនេះទេ? នេះរយៈពេលក្នុងឯកសារនេះ ជារយៈពេលមួយដែលលោកហ្នឹង លោកសាក្សីគាត់បានចេញផុតហើយ នៅសល់បងស្រីគាត់ ដែលវ៉ៃពី១០៥ មកភ្នំពេញ។ ហើយលោក អំមិញលោកសាក្សីបានថា បានទទួលឯកសារនេះលោកទទួលស្គាល់។ ហើយបានខ្ញុំសួរបន្ថែមថា បើទទួលស្គាល់ចុះអាលេខក្បាលនាគ ហើយនិងខ្មែរតេឡា ទាំងអស់ហ្នឹងយ៉ាងម៉េចបាទ?--

**ប្រធានអង្គជំនុំ៖**

អំមិញគាត់ទទួលស្គាល់តែទម្រង់ទេ។ លោកមេធាវីស្ដាប់ឲ្យយល់ គាត់ទទួលស្គាល់ទម្រង់ទេ របៀបសរសេរអ៊ីចឹងៗហ្នឹង គឺទម្រង់គេប្រើប្រាស់នៅសម័យនុំងមែន ប៉ុន្តែឯកសារនេះ គឺវាចុងខ្សែទេ ដែលអ្នកទទួលកត់ត្រា លេខទូរលេខនេះ។ អ្នកចុងខ្សែគឺនៅភ្នំពេញឯនេះទេ ទៅសួរអ្នកដែលដើមខ្សែ នុំងម៉េចដឹង វាទាល់តែទុកសួរសាក្សីណាដែលគាត់ជាអ្នកគ្រប់គ្រង ខាងផ្នែកទូរសារនៅភ្នំពេញបានវាសមស្រប។

លោកអាចសួរសំណួរផ្សេងទៀតបានហើយ។ សំណួរនេះ ដូចជាមិនអាចពាក់ព័ន្ធនឹងសាក្សី ដែលអាចឆ្លើយដឹងលើបញ្ហាស្លាកស្នាមនៅលើឯកសារ ដែលលោកមានបំណងសួរនោះបានទេ។

[១៦:០៦:០៧]

**លោក សុន អរុណ៖**

សូមអរគុណនូវការពន្យល់របស់លោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំបន្តសំណួរមួយទៅទៀត។ សឹងតែគ្រប់ទូរលេខ សារទូរលេខពីខាងតំបន់១០៥ បានប្រើសុទ្ធសឹងតែមានចម្លងជូន បងនួន។ តើលោកយល់ទេ ដែលលោកធ្លាប់បកប្រែឯកសារ ធ្លាប់វ៉ៃទូរសារ ២ឆ្នាំនុំង យល់ថាអត្ថន័យចម្លងជូន ហើយនិងនៅខាងលើនេះ ជូន ជូនទៅអ្នកណាអ៊ីចឹងទៅ ហើយដល់ក្រោមចម្លងជូនហ្នឹង មានន័យខុសគ្នាយ៉ាងម៉េច?

**លោក ផាន វ៉ាន់៖**

**ផ៖** ខ្ញុំអត់យល់ទេបាទ ពីព្រោះអ្នកបកសារទូរលេខនៅតំបន់ហ្នឹងដឹងតែពីបកបញ្ជូន ឲ្យអ្នកវ៉ៃអង្គុលីលេខតែប៉ុណ្ណឹងបាទ។ ហើយចម្លងជូនអ្នកណា អ្នកខាងគេទទួលខាងនេះ គេចម្លងជូនខាងណាខ្ញុំមិនបានដឹងទេ។

**ស៖** អរគុណ។ លោក ខាំ ផាន់ នៅពេលដែលលោកបើកឡានជូន ដឹកលោកស្រី អៀង ធីរិទ្ធ ហើយរឿងមួយទៀត ពេលដែលលោកធ្វើការនៅប-២០ រយៈពេលយូរដែរ លោកបានស្គាល់អ្នកធំ ថ្នាក់ដឹកនាំច្រើនដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម អីទាំងអស់ បើតាមលោកបាននិយាយជម្រាបតុលាការរួចហើយនោះ។ ក្នុងនោះខ្ញុំសួរថា តើលោកស្គាល់ នួន ជា ច្បាស់លាស់ទេ?

[១៦:០៨:២៩]

**ឆ៖** ស្គាល់បាទ។

**ស៖** លោកបានធ្លាប់និយាយអីជាមួយគាត់ និយាយលេង ឬនិយាយការងារអីជាមួយគាត់ផ្ទាល់ទេ?

**ឆ៖** ធ្លាប់បាទ។

**ស៖** លោកស្គាល់ ខ្ញុំសួរលោកថា លោក នួន ជា ជាមនុស្សមានចរិតយ៉ាងម៉េច? ជាមនុស្សមានចរិតឃោរឃៅ កាចសាហាវ មិនដឹងខុស មិនដឹងត្រូវ គ្មានឧត្តមគតិបម្រើជាតិ ឬក៏ជាមនុស្សស្លូតត្រង់ ធ្វើអ្វីដោយមានការពិចារណា រកខុសរកត្រូវ មានឧត្តមគតិសម្រាប់ជាតិ?

**ឆ៖** ខ្ញុំស្គាល់គាត់ច្បាស់ ក្រោយដែលវៀតណាមចូលស្រុករត់មកនៅព្រៃ។ ដូចខ្ញុំជម្រាបអាសយដ្ឋានដំបូងអ៊ីចឹងបាទ។

[១៦:០៩:៤៣]

**ស៖** ខ្ញុំសូមលោកឆ្លើយនូវចម្លើយខ្ញុំ។ ខ្ញុំសួរថា តើគាត់ជាមនុស្សមានចរិតកិរិយាយ៉ាងម៉េច?

**ឆ៖** សូមសួរសំណួរម្តងទៀតបាទ។

**ស៖** អរគុណណាស់ បើអ៊ីចឹង ខ្ញុំនឹងសួរម្តងទៀត។ លោកអំមិញបានឆ្លើយប្រាប់ខ្ញុំថា លោកបានស្គាល់លោក នួន ជា ច្បាស់លាស់ បាននិយាយជាផ្លូវការ ឬនិយាយលេងជាមួយគាត់ញឹកញាប់។ ខ្ញុំសួរថា តើលោកស្គាល់លោក នួន ជា ក្នុងឋានៈជាមនុស្សធ្វើការក្រោមបង្គាប់គាត់ ហើយប៉ុន្តែលោកមាន -- លោកថ្នាក់ដឹកនាំ -- តើលោកមានចរិតឃោរឃៅកាចសាហាវ ដាក់គុកមនុស្សដោយគ្មានខុស ដឹងខុស ដឹងត្រូវ ឬក៏ជាមនុស្សស្លូតត្រង់ ឬមនុស្សដែលមានចរិតល្អ មានឧត្តមគតិល្អ ធ្វើអ្វីមានយុត្តិធម៌និងស្រឡាញ់ជាតិ ស្នេហាជាតិ ដូចជាអ្នកដឹកនាំដទៃអ៊ីចឹងដែរ?

[១៦:១០:៥២]

**ឆ៖** ដូចខ្ញុំបញ្ជាក់អំមិញហើយ ខ្ញុំស្គាល់គាត់ក្រោយពីរត់ចូលព្រៃតស៊ូពី៧៩ មកដល់ ៩៧បាទ។ ប៉ុន្តែចរិតគាត់ដូចលោកមេធាវីសួរហ្នឹង ខ្ញុំអត់យល់និយមន័យជាតិរបស់គាត់។ តើគាត់កំណត់ជាតិហ្នឹងជាខ្មែរដែលនិយាយភាសាខ្មែរទាំងអស់ទូទាំងពិភពលោក ដែលនិយាយភាសាខ្មែរ ជនជាតិខ្មែរនៅ ឬគាត់កំណត់ជាតិតែក្រុមគាត់។ នេះខ្ញុំចង់បញ្ជាក់ឲ្យគាត់ដឹងប៉ុណ្ណឹងទេ។ ពីព្រោះកន្លងមក តាមខ្ញុំខ្លួនឯងផ្ទាល់នេះប្រឡូកក្នុងចលនាហ្នឹងឃើញថា គាត់អត់ស្នេហាជាតិទេ គាត់ស្នេហាបុគ្គល តែក្រុមគាត់តាមគំនិត

របស់គាត់។ នរណាខុសពីគំនិតរបស់គាត់ ថា "ក្បត់"។ ដល់ហើយគាត់ចេះតែប្រាប់ថា ជាតិប្រជាជនៗម្នាក់ៗឆ្លល់។ សូមបញ្ជាក់ជូនតុលាការប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ ពីព្រឹកមិញលោកបានឆ្លើយទៅសហមេធាវីខ្ញុំថា "ពេលយួនចូលនោះ ពេលនោះឈ្មោះ សារុន កាន់អំណាច ហើយមានបាត់មនុស្សកាន់តែច្រើនឡើងៗ"។ ខ្ញុំសួរថា តើលោកដឹងទេថាមនុស្សបាត់ច្រើន តើលោកដឹងច្បាស់ ឬពួគេពីដទៃប្រាប់ថា បាត់ខ្លួនច្រើននោះ តើបាត់ដោយស្លាប់ដោយភៀសខ្លួនទៅកន្លែងដទៃផ្សេងទៀត ឬបាត់ដោយរបៀបណា បើតាមលោកដឹងច្បាស់លាស់ សូមលោកសាក្សីមេត្តាជម្រាបតុលាការ ឬអ្វីដែលលោកដឹងពិតប្រាកដ ឬក៏លោកបានឃើញដោយផ្ទាល់ភ្នែក?

[១៦:១៣:០៥]

**ឆ៖** ចំពោះសំណួរហ្នឹងគឺថា ខ្ញុំដឹង ប៉ុន្តែអត់ឃើញពិតប្រាកដ។ ដល់អ៊ីចឹងត្រង់ថា ហេតុអីបានដឹង? ដឹងដោយសារសួរ។ សួរគេ ហៅមកធ្វើការបាត់អស់រលីង ពួកហ្នឹងតាមមើល៍ គេស្ពេះ -- "សម្ពេះ" គេប្រើពាក្យអ៊ីចឹង។ មិត្តភក្តិហ្នឹងគេប្រើពាក្យថា "គេសម្ពេះចោលបាត់ហើយអ្នកនេះអ្នកនោះ" សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** បើអ៊ីចឹងលោកឮថា បាត់ខ្លួនហ្នឹង គេសម្លាប់អីហ្នឹង ឮតាមគេប្រាប់អ៊ីចឹងណ៎ះ?

**ឆ៖** ខ្ញុំសួរគេបាទ។ ហើយមនុស្សហ្នឹងបាត់មែន អត់ឃើញ។

**ស៖** ពេលៗដែលលោកបានឆ្លើយជូនចំពោះចៅក្រមពីម្សិលថា "លោក នួន ជា បានផ្ញើទូរសារឲ្យឪពុកលោកជាមួយនឹង ខាំ ភូន មករៀន មកធ្វើសិក្សា ការសិក្សានៅភ្នំពេញ។ លុះមកដល់ភ្នំពេញឪពុកលោកជាមួយនឹង ខាំ ភូន ក៏ស្លាប់"។ ខ្ញុំសួរថា តើលោកដឹងទេទូរសារដែលលោក នួន ជា ផ្ញើមកឪពុកលោកហ្នឹង លោកបានទទួលផ្ទាល់ដៃ ឬក៏អ្នកណាទទួលពេលនុ៎ង?

**ឆ៖** ពេលនោះ បងខ្ញុំគាត់អ្នកធ្វើការ បងខ្ញុំអ្នកទទួល។

**ស៖** អរគុណ។ លោកបានឃើញទូរសារហ្នឹងទេ?

**ឆ៖** អត់ឃើញទេបាទ។

[១៦:១៥:១២]

**ស៖** បើលោកមិនបានឃើញទូរសារទេ លោកនិយាយហ្នឹងនិយាយព្រាវ ឬក៏និយាយដោយយ៉ាងម៉េចក្នុងគំនិតយ៉ាងម៉េច?

**ឆ៖** អត់ព្រាវទេបាទ ព្រោះឪពុកខ្ញុំប្រាប់ថា "បងទី២ ហៅមកធ្វើការ ឲ្យរៀបចំអីវ៉ាន់ស្អែកយន្តហោះមកយក" ថាអ៊ីចឹង។ ខ្ញុំមានតួនាទីរៀបចំអីវ៉ែអីវ៉ាន់ អ៊ីចឹងទៅ។ ហើយគាត់ណែនាំថា កុំឲ្យដាក់កាំភ្លើងដាក់អីមក ថាតែប៉ុណ្ណឹងទេ។ ស្អែកឡើងយន្តហោះគេមកយកទៅ។

**ស៖** ពេលដែលឪពុកលោក តាឡាំង គាត់មកភ្នំពេញលើកដំបូងគាត់មកម្នាក់ឯង ឬក៏មកជាមួយអ្នកណា?

**ឆ៖** ខ្ញុំចាំអត់បានទេបាទ។

**ស៖** នៅក្នុងការសម្ភាសរបស់លោកជាមួយនឹងចៅក្រមស៊ើបអង្កេតក្នុងឯកសារលេខ E3/58 ERN ខ្មែរ 00239937, អង់គ្លេស 00250089 ហើយបារាំង 00288915។ ក្នុងឃ្លាហ្នឹងលោកបានឆ្លើយជម្រាបទៅចៅក្រមស៊ើបអង្កេតថា "ក្រៅពីនេះ នួន ជា បានផ្ញើសារអង្គុលីលេខ" ត្រឹមត្រូវទេអាហ្នឹង ពាក្យហ្នឹង? សារអង្គុលីលេខ ឬក៏ទូរលេខ? "មកឲ្យថ្នាក់តំបន់ ដូចជា តាសុភា សមាជិកតំបន់ទទួលខាងយោធា ឬយោធាតំបន់ ឬឪពុករបស់ខ្ញុំនិងអ្នកផ្សេងៗទៀតទៅរៀនសូត្រនៅភ្នំពេញ។ ឪពុករបស់ខ្ញុំ និងតា ខាំ ភួន អនុតំបន់ត្រូវសម្លាប់តែម្តងនៅពេលហៅទៅរៀនសូត្រលើកក្រោយ"។ ខ្ញុំត្រង់នេះខ្ញុំចង់បញ្ជាក់ថា លោកបានបញ្ជាក់ថាពេលមកភ្នំពេញនោះដោយមានទូរសាររបស់លោក នួន ជា, ឪពុកលោក តាឡាំង ហ្នឹង ជាមួយតា ខាំ ភួន ជាមួយនឹងលោកសាក្សីផ្ទាល់ និងម្នាក់ទៀតនៅក្នុងឯកសារបន្ទាប់ហ្នឹងឈ្មោះ ដឹង ជាអង្គរក្សរបស់ឪពុករបស់លោកសាក្សីមកជាមួយ។ ឥឡូវខ្ញុំសូមបញ្ជាក់សាជាថ្មីថា ពេលហ្នឹងសូមឲ្យលោកឆ្លើយបើតាមលោកចាំច្បាស់លាស់ លោកឪពុករបស់លោក ខាំភួន មកម្នាក់ឯង ឬក៏មានមកជាមួយ ខាំ ភួន ឬក៏មានគ្នាដូចជាសាក្សីហ្នឹងជាដើម?

[១៦:១៨:៥៨]

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ហើយថាមកគ្នាបួននាក់ មានអ៊ំ ខាំ ភួន, ឪពុកខ្ញុំ, នីរសារគាត់ម្នាក់ឈ្មោះ ដឿង មិនមែន ដឹង ទេបាទ។

**ស៖** អ៊ីចឹងពេលដែលតា នួន ជា គាត់ធ្វើលិខិតឲ្យ ទូរសារឲ្យឪពុកលោកមកហ្នឹង គឺថាមកទាំងបួននាក់ មិនមែនមកតែ តាឡាំង ម្នាក់ឯងទេអ៊ីចឹង? ខ្ញុំចង់បញ្ជាក់ត្រង់ហ្នឹងឲ្យច្បាស់ បើលោកនឹកឃើញយ៉ាងម៉េចប្តែកសូមលោកបញ្ជាក់ឲ្យច្បាស់កន្លែងហ្នឹង។

**ឆ៖** បាទ តែបួននាក់ហ្នឹងទេបាទ។ ប៉ុន្តែក្នុងសារទូរលេខហ្នឹង ធម្មតាកម្មាភិបាលហ្នឹង គេតែពីរនាក់ទេ ប៉ុន្តែនីរសារហ្នឹងពីរនាក់។

**ស៖** ទូរសារដែលលោក នួន ជា ផ្ញើទៅឲ្យឪពុកលោកនុ៎ង លោកបានបញ្ជាក់ពីមុនថា លោកមិនបានទទួល ហើយមិនបានឃើញទេ ប៉ុន្តែពេលដែលមកជាមួយឪពុកលោក គឺលោកបានមកជាមួយ។ ចង់សួរថា អ្នកណាដែលទទួលទូរសារដែលតា នួន ជា ផ្ញើទៅនុ៎ង?

**ឆ៖** ដូចខ្ញុំបញ្ជាក់លោកចៅក្រមហើយថា បងខ្ញុំអ្នកទទួលបាទ។ ដូចបញ្ជាក់ប៉ុន្មានដងហើយរឿងហ្នឹង។ ជាធម្មតា ដូចខ្ញុំអត្ថាធិប្បាយឲ្យយល់អំមិញ ធម្មតាខាងហៅនោះ គេមិនដឹងឈ្មោះនីរសារទេ គេហៅតែមេពីរនាក់ទេ។ តែមកនោះ មកគ្នាបួននាក់។ ចង់បញ្ជាក់ឲ្យច្បាស់អ៊ីចឹង។

[១៦:២១:២៧]

**លោក សុន អរុណ៖**

ខ្ញុំអត់មានសំណួរអីតទៅទៀតទេលោកប្រធាន។ សូមអរគុណ ហើយអរគុណលោក ខាំ ផាន់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សួស្តីលោក ផាន វ៉ាន! ខ្ញុំ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់លោកនៅពេលនេះ។ ឃើញថាពេលវេលាក៏ជិតដល់ដែរ ប៉ុន្តែខ្ញុំប្រហែលជាបន្តសំណួរនៅពេលថ្ងៃស្អែកទៀត បើសិនជាមិនអាចចប់នៅពេលនេះ។

ដំបូងខ្ញុំសូមសួរលោកទាក់ទងទៅនឹងលោក ខៀវ សំផន ហើយលោកបានឆ្លើយរួចហើយថា លោកធ្លាប់ស្គាល់គាត់។ ខ្ញុំចង់សួរថា តើលោកស្គាល់ជាលើកទី១ លើកដំបូងហ្នឹងនៅពេលណាដែរ?

**លោក ផាន វ៉ាន៖**

**ឆ៖** ខ្ញុំឃើញគាត់ស្គាល់គាត់តាំងពីនៅប-២០ ខ្ញុំនៅតូចៗម្ល៉េះបាទ។

**ស៖** លោកចាំឆ្នាំទេ កាលនុ៎ងឆ្នាំប៉ុន្មាន?

**ឆ៖** ខ្ញុំចាំឆ្នាំអត់បានទេ ព្រោះថាច្រើនឆ្នាំហើយសួរ បើថាលោកមេធាវីចង់ច្បាស់អ៊ំខ្លួនឯងក៏ច្បាស់ដែរបាទ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំនៅទីនេះ ខ្ញុំសួរលោក ហើយសូមឲ្យលោកជួយសហការឆ្លើយនូវសំណួររបស់ខ្ញុំ។ បើសិនជាលោកមានចម្ងល់អីផ្សេងទៀត លោក ឧទាហរណ៍ថាស្តាប់មិនច្បាស់ លោកអាចសួរខ្ញុំបានណា៎។ ខ្ញុំអាចសួរលោកថែមទៀតថា ពេលនោះក្នុងឋានៈលោកជាអ្វីដែរ នៅពេលដែលលោកស្គាល់លោក ខៀវ សំផន ដំបូងនោះ?

**ផៈ** ខ្ញុំនៅកុមារនៅឡើយបាទ នៅតូចៗ។

[១៦:២៤:១៤]

**សៈ** អាយុលោកប៉ុន្មានឆ្នាំដែរពេលហ្នឹង?

**ផៈ** ចាំអាយុអត់បានដែរ ខ្ញុំបាទ។

**សៈ** លោកដឹងថា លោក ខៀវ សំផន មានមុខងារជាអីទេនៅពេលនុ៎ង?

**ផៈ** អត់ដឹងទេបាទ ដឹងថាហៅ "អ៊ំៗ"អ៊ីចឹងបាទ តាំងពីក្មេង។

**សៈ** ចុះមានអ្នកណាណែនាំឲ្យលោកស្គាល់លោក ខៀវ សំផន ទេ ឬមួយក៏វាជារឿងចៃដន្យណាមួយ សូមលោកជួយបញ្ជាក់។ កាលៈទេសៈដែលនាំឲ្យលោកស្គាល់លោក ខៀវ សំផន។

**ផៈ** កាលៈទេសៈកាលហ្នឹង ឪពុកខ្ញុំឲ្យមករៀននៅខាងក្រោមនេះបាទ។

**សៈ** មករៀននៅឯណានៅខាងក្រោម លោកអាចបញ្ជាក់ឲ្យច្បាស់បានទេ?

**ផៈ** នៅប-២០ ដូចបានជម្រាបខាងលើ។

[១៦:២៥:៥០]

**សៈ** លោករៀនអ្វីដែរពេលហ្នឹង?

**ផៈ** រៀនអក្សរផង រៀនបកសារអង្គុលីលេខហ្នឹងបាទ។

**សៈ** លោករៀនភាសាខ្មែរ ឬមួយភាសាអ្វី?

**ផៈ** រៀនភាសាខ្មែរបាទ។

**សៈ** ចុះបញ្ហាបកសារអង្គុលីលេខហ្នឹង លោកសំដៅលើអ្វីដែរ?

**ផៈ** បកឯកសារ ដែលផ្ញើតាមសារទូរលេខហ្នឹងបាទ តាមវិទ្យុទាក់ទងហ្នឹង។

**សៈ** លោកចាំថា អ្នកណាជាអ្នកបង្រៀនលោកទេ នៅពេលហ្នឹង?

**ផៈ** ដូចខ្ញុំបានជម្រាបជូនខាងលើហ្នឹងហើយបាទ។ មានកាលជំនាន់ហ្នឹង មីងស៊ីម បាទ។ ឈ្មោះ ស៊ីម បើតាមខ្ញុំចាំអត់ភ្លេច។

**សៈ** តែម្នាក់គាត់ហ្នឹងទេ មានអ្នកផ្សេងទៀតទេ?

**ធៈ** ចាំបានតែម្នាក់ហ្នឹងបាទ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងមន្ទីរក-១៧ លោកអាចបញ្ជាក់បានទេថា មន្ទីរក-១៧ ហ្នឹងជាអ្វីដែរ?

[១៦:២៨:១២]

**ធៈ** ជំនាន់ហ្នឹងគេហៅមន្ទីរនីរសារបាទ។ ជាទូទៅគេដឹងថា មន្ទីរនីរសារក-១៧ អ៊ីចឹង។

**សៈ** លោកធ្វើការនៅកន្លែងហ្នឹងប៉ុន្មានឆ្នាំដែរ? ហើយចាប់ពីឆ្នាំណាដល់ឆ្នាំណា បើអាចបញ្ជាក់បាន។

**ធៈ** លោកសួរក-១៧, ១០៥ ឬក-១៧ នៅភ្នំពេញខ្ញុំចង់សួរបញ្ជាក់ ព្រោះខ្ញុំនៅក-១៧, ១០៥ បាទ។

**សៈ** បាទសូមអរគុណ។ ខ្ញុំចង់សួរក-១៧, ១០៥ នៅតំបន់១០៥ ហ្នឹងបាទ។

**ធៈ** នៅ១០៥ គេហៅមន្ទីរតំបន់ អាហ្នឹងកន្លែងតំបន់ បើថារៀបដូចយើងឥឡូវវា ដូចនៅខេត្តថ្មីអ៊ីចឹង រៀបចំកន្លែងមន្ទីរខេត្តបើថាឥឡូវបាទ។

**សៈ** លោកអាចបញ្ជាក់ពីរចនាសម្ព័ន្ធក-១៧ នៅ១០៥ នោះបានទេ?

**ធៈ** ខ្ញុំចាំមិនបានអស់ទេ ព្រោះអង្កាល់ហ្នឹងខ្ញុំនៅក្មេងពេក ការចងចាំវាភ្លេចខ្លះ។ រចនាសម្ព័ន្ធអត់យល់ពីការរៀបចំដែរបាទ។

**សៈ** លោកអាចបញ្ជាក់ពីពេលវេលា ពីឆ្នាំ ឬក៏ខែ ដែលលោកចូលទៅដំបូង ហើយនិងពេលលោកចេញមកវិញ ឈប់ធ្វើការនៅក-១៧ ឬក៏ឈប់នៅក-១៧ ហ្នឹង លោកអាចបញ្ជាក់បានទេ?

**ធៈ** ក-១៧ហ្នឹងរៀបចំមុនៗដាច់ភ្នំពេញប្រហែលជា១ឆ្នាំបាទ។ រៀបចំកន្លែងខេត្តហ្នឹង រហូតខ្ញុំនៅរហូតដល់ៗឪពុកខ្ញុំស្លាប់។

**សៈ** អ៊ីចឹងមានន័យថា លោកនៅទីនោះពីឆ្នាំ៧៤ រហូតដល់៧៧ តើខ្ញុំនិយាយនឹងត្រឹមត្រូវទេ?

**ធៈ** បាទ ត្រឹមត្រូវ ខ្ទង់ប៉ុណ្ណឹង។

[១៦:៣១:៣៦]

**ប្រធានអង្គជំនុំ**

បាទ ឥឡូវដល់ពេលសម្រាកហើយ។ អរគុណលោកមេធាវី។

បាទ ដល់ពេលសម្រាកហើយ។

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយខ្លីទេ ដោយសារពេលវេលា។ ខ្ញុំគ្រាន់តែចង់ជម្រាបជូនអង្គជំនុំជម្រះថា ថ្ងៃនេះជាថ្ងៃចុងក្រោយហើយដែលខ្ញុំចូលរួមនៅទីនេះ។ ខ្ញុំចូលខ្លួនដំបូងហ្នឹងគឺប្រហែលជា២ឆ្នាំមុន ជាឆ្នាំដែលខ្ញុំចងចាំ។ ក្នុងនាមជាមេធាវីនៅទីនេះ ខ្ញុំសូមបញ្ជាក់ថា សាលាក្តីនេះអាចកាន់តែធ្វើឲ្យបានច្រើនទៀត ដើម្បីពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា នៅក្នុងពេលបច្ចុប្បន្ន និងការទទួលខុសត្រូវចំពោះអ្នកដែលនៅក្នុងតួនាទី។ ហើយអង្គជំនុំជម្រះនោះ គួរតែធ្វើការងារឲ្យបានច្រើនលើឯករាជ្យភាពរបស់តុលាការនេះ នៅក្នុងប្រទេសកម្ពុជា។

[១៦:៣២:៤៣]

នេះ គឺជាកេរដំណែលមួយដែលអង្គជំនុំជម្រះនឹងបន្សល់ទុក គឺអង្គជំនុំជម្រះសាលាដំបូងជាអ្នកមានឆន្ទានុសិទ្ធិធ្វើការទាំងអស់នេះ។ ដូច្នេះវាមិនយឺតពេលទេ ដែលអង្គជំនុំជម្រះអាចបំពេញការងារទាំងអស់នេះបាន។ ខ្ញុំសូមថ្លែងអំណរគុណអង្គជំនុំជម្រះ និងភាគីទាំងអស់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំយល់ថា មិនមែនជាការត្រឹមត្រូវទេ ដែលធ្វើសេចក្តីថ្លែងការណ៍បែបនេះ នៅទីនេះ ហើយជាការធ្វើសេចក្តីថ្លែងការណ៍មួយបែបស្រាល ក៏ប៉ុន្តែវាមានការប៉ះពាល់ទៅដល់កេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះនេះដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកបន្តធ្វើសេចក្តីថ្លែងអ្វីទៀតទេ លោក ហ្សាស្តើ ប៉ៅ។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ

ទី១៤ ខែធ្នូ ឆ្នាំ២០១២ ចាប់ពីផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្ដី និងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-665 ដែលនឹងផ្ដើមសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីឯទៀតនៃរឿងក្ដី សូមភាគី និងសាធារណជនជ្រាប។

[១៦:៣៤:២៣]

លោក ផាន វ៉ាន ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅព្រឹកថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែក គឺថ្ងៃ១៤ ខែធ្នូ ឆ្នាំ២០១២ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយមន្ត្រី -- អ៎! មេធាវីប្រឹក្សាសាក្សីក៏សូមអញ្ជើញចូលរួមដូចគ្នា នៅក្នុងអំឡុងពេលនៃដំណើរការស្ដាប់សក្ខីកម្មសាក្សីរូបនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។ បាទ មេធាវីប្រឹក្សាសាក្សីសូមអញ្ជើញចូលរួមដូចគ្នានឹងពេលវេលាដែលសាក្សីត្រូវផ្ដល់សក្ខីកម្ម។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួន។

ដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនដែលនៅពីក្រោមសាលសវនាការនេះដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៣៥ នាទី)*